# អំពើឈ្លានពានរបស់យួន មកលើកម្ពុជា

ដោយ សោម-សេកកុមារ



រក្សាសិទ្ធិការផ្សាយ

# នយោបាយរបស់សីហនុជាមួយប្រទេសកុម្មុយនិស្ត និងសកម្មភាពរបស់យៀកកុងក្នុងរាជាណាចក្រកម្ពុជា ឆ្នាំ១៩៦៣-១៩៧០

នៅឆ្នាំ១៩៦២, នៅចំពោះមុខសមាជិកនៃបក្សកុម្មុយនិស្តសូវៀត, គ្រុត-ឆេហ្វ បានប្រកាសគាំទ្រដោយឥតលក្ខខ័ណ្ឌ ដល់ការតស៊ូរបស់ហាណូយដើម្បីបង្រួបបង្រួមវៀតណាមទាំងពីរ ។ តាំងពីឆ្នាំ១៩៥៤, ប្រធានាធិបតីអាមេរិកាំង អាយហ្សិនហាវើ បានប្រមើលទុកថា បើឥណ្ឌូចិនធ្លាក់ក្នុងដៃរបស់កុម្មុយនិស្ត, អាស៊ីអាគ្នេយ៍ទាំងមូលនឹងធ្លាប់បន្តបន្ទាប់ទៅជាមួយគ្នា ។ ដោយបារម្ភដល់ស្ថានភាពនេះ, នៅឆ្នាំ១៩៦៣, ប្រធានាធិបតីកេណ្ណឺឌី បានបន្ថែមទីប្រឹក្សាយោធាអាមេរិកាំង១,៦០០ នាក់ទៀតទៅយួនខាងត្បូង ។

នៅឆ្នាំ១៩៦៣, ស្តេចសីហនុបានសន្និដ្ឋានថា សហរដ្ឋអាមេរិកមិនអាចយកឈ្នះនៅយួនខាងត្បូងបានទេ ហើយថាគាត់នឹងត្រូវសម្របខ្លួនជាមួយហាណូយដោយរំពឹងទៅលើចិន ដើម្បីទុកឲ្យមើលការគាបសង្កត់របស់ហាណូយទៅអនាគត ។ លើសពីនេះទៀត សៀមនិងយួនខាងត្បូង, ដោយប្រឆាំងជាមួយគំនិតលំអៀងរបស់សីហនុទៅរកពួកកុម្មុយនិស្ត បានបដិសេធសំណើររបស់សីហនុ សំរាប់កិច្ចព្រមព្រៀងជាអន្តរជាតិមួយ ដែលនឹងក៏រិតតាមពិធីការ ឲ្យប្រទេសជិតខាងរបស់កម្ពុជានិងមហាអំណាចទាំងឡាយ គោរពដល់អព្យាក្រឹតនិងបូរណភាពដែនដីរបស់កម្ពុជា, នៅពេលដែលប៉េកាំងនិងហាណូយយល់ព្រមដល់សំណើរនេះ ។ នៅខែសីហា១៩៦៣, សីហនុបានផ្តាច់ចំណងទូតពីព្រៃនគរ ហើយបន្តិចក្រោយរដ្ឋប្រហារប្រឆាំងង៉ោ-ឌិនយៀម នៅថ្ងៃទី១សីហា១៩៦៣, សីហនុបានបញ្ចប់រាល់កម្មវិធីសំរាប់ជំនួយសង្គ្រោះពីអាមេរិកាំងនៅកម្ពុជា ។ នៅខែធ្នូ១៩៦៣, សីហនុបានចុះហត្ថលេខាជាលើកទី១ លើកិច្ចព្រមព្រៀងខាងផ្គត់ផ្គង់ផ្នែកយោធាពីចិន ។

នរោត្តម-សីហនុ, ទោះជាដោយសារភាពឆាប់ខឹងដល់កំពូលរបស់គាត់ បានមានះក្នុងបំណងដើម្បីរក្សាមិត្តភាពជាមួយពួកចិនកុម្មុយនិស្ត ក្នុងនាមនៃអព្យាក្រឹតភាពរបស់គាត់ ។ សីហនុក៏បានស្វែងរកមិត្តភាពដូចគ្នាដែរ ជាមួយសហភាពសូវៀត ប៉ុន្តែក្នុងប៉ុន្មានឆ្នាំនោះអាកប្បកិរិយារបស់គាត់ចំពោះក្រុងម៉ូស្គូត្រូវវិវត្ត។ ក្នុងនាមជាសហប្រធាននៃសន្និសិទនាក្រុងហ្សឺណែវនៅឆ្នាំ១៩៥៤ស្តីពីឥណ្ឌូចិន និងឆ្នាំ១៩៦២ស្តីពីលាវ, សហភាពសូវៀតជាដៃគូទុកចិត្តចំពោះក្រសែភ្នែករបស់សីហនុ ។ ជា

ដំបូង ជំនួយរបស់សហភាពសូវៀតចំពោះកម្ពុជា មានសារៈសំខាន់ទាំងលើវិស័យសេដ្ឋកិច្ច ទាំងយោធា, ដូចជាការកសាងសកលវិទ្យាល័យបច្ចេកទេស, ការទំនុកបំរុងក្នុងសំណង់ទំនប់វារី-អគ្គីសនី និងមន្ទីរពេទ្យ ព្រមទាំងការផ្ដល់យន្តហោះមីហ្គ និងគ្រឿងសម្ភារៈ ដេ.សេ.អា. ជាដើម ។

នៅឆ្នាំ១៩៦៤, នៅពេលដែលសីហនុស្វែងរកការរួមប្រជុំជាសន្និសិទអន្តរជាតិមួយនៅក្រុងហ្សឺណែវ ដើម្បីធានាដល់បូរណភាពនៃដែនដីខ្មែរ និងអព្យាក្រឹតភាពរបស់គាត់, នៅថ្ងៃទី៩មេសា, សីហនុបានយល់ព្រមផ្ដល់កិច្ចសម្ភាសន៍មួយ ទៅអ្នកឆ្លើយឆ្លងសារព័ត៌មាន ឡាប្រាវដា ដែលនៅឱកាសនោះគាត់បានបញ្ជាក់ថា ៖

«យើងផ្ញើសេចក្ដីសង្ឃឹមដ៏ធំធេង ជាមួយសហភាពសូវៀត ហើយទីបំផុតយើងជឿជាក់ថា នឹងបានទទួលការកោះប្រជុំជាសន្និសិទនៅក្រុងហ្សឺណែវ ។ យើងសូមសំដែងកត្តញ្ញូធម៌ដល់សហភាពសូវៀត ចំពោះមុខនាទីជាអ្នកការពារប្រជាជាតិក្នុងប្រទេសតូចតាច» ។

សំនៀងនេះបានប្រែប្រួលយ៉ាងគំហុក នាសរទរដូវនៃឆ្នាំ១៩៦៥ ក្នុងគ្រាដែលវិវាទនៅប្រទេសយួនបានកើនសន្ទុះខ្លាំង ដោយការទម្លាក់គ្រាប់បែកនៃកងអាកាសចរណ៍អាមេរិកាំងលើយួនខាងជើង ។ នៅសម័យនោះ, សីហនុចាប់ផ្ដើមធ្វើទស្សនកិច្ចជាផ្លូវការនៅប្រទេសកុម្មុយនិស្ត អាស៊ី និងអឺរ៉ុប ។ សីហនុបានចាប់ផ្ដើមពីប៉េកាំង ដែលពីទីនោះគាត់នឹងបន្តដំណើរទៅព្យុងយ៉ាង ហើយបន្ទាប់មក ជាទីដែលគាត់ត្រូវបានអញ្ជើញសំរាប់ថ្ងៃទី៧វិច្ឆិកា១៩៦៥ ។

នៅថ្ងៃទី៨តុលា១៩៦៥, ឯកអគ្គរដ្ឋទូតសហភាពសូវៀតប្រចាំព្យុងយ៉ាង បានផ្ដល់ពត៌មានទៅសីហនុថា «មេដឹកនាំសូវៀតជាប់រវល់ខ្លាំងពេក ពុំអាចមានលទ្ធភាពដើម្បីទទួលគាត់បាននៅខែវិច្ឆិកា» ។ កំណត់ដែលត្រូវបានប្រគល់ទៅសីហនុបញ្ជាក់ថា ទស្សនកិច្ចជាផ្លូវការនេះនឹងត្រូវលើកទៅកាលបរិច្ឆេទក្រោយ ដែលនឹងត្រូវសន្មត់យកតាមផ្លូវទូត ។ ម្យ៉ាងទៀត, អ្នកការទូតសូវៀតបានបន្ថែមថា ប្រសិនជាសីហនុប្រាថ្នា, គាត់អាចឆ្លងកាត់សហភាពសូវៀត នាឱកាសទស្សនកិច្ចនៅអឺរ៉ុបខាងកើត ។ កំហឹងរបស់សីហនុ ពុំអាចត្រូវពណ៌នាបាន ។ សីហនុបានប្រកាសឲ្យដឹងថា ក្នុងស្ថានភាពនេះ គាត់នឹងត្រឡប់មកភ្នំពេញវិញ ហើយថា«ទស្សនកិច្ចរបស់គាត់ក្នុងប្រទេសជាមិត្តនៅអឺរ៉ុបខាងកើត នឹងត្រូវពន្យឺតពេល» ។ ក្រោយមក, ទស្សនកិច្ចនេះត្រូវបានទុកជាមោឃៈ ។

ហេតុអ្វីបានជាសហភាពសូវៀតដោះសារយ៉ាងសោះអង្គើយដូច្នេះចំពោះសីហនុ ដែលជាបុគ្គលត្រូវទទួលកិច្ចស្វាគមន៍ ?

មុនពេលទៅដល់កូរ៉េខាងជើង, ក្នុងសុន្ទរកថាចុងក្រោយ ដែលគាត់បានថ្លែង

នៅប៉េកាំង ក្រោយពីបានអួតសរសើរជាថ្មីម្តងទៀតអំពីមិត្តភាពខ្មែរ-ចិន, មានឃ្លានេះថា ៖ «មានមហាអំណាច ដែលនិយាយថាខ្លួនប្រឆាំងនឹងចក្រពត្តិនិយម និងជាមិត្តរបស់យៀកណាម, ហើយប្រាប់ឲ្យធ្វើការចរចាដោយគ្មានលក្ខខណ្ឌគ្រោងទុករវាងអាមេរិកាំងជាអ្នកឈ្លានពាន និងយៀកណាមជាអ្នកទទួលអំពើឈ្លានពាន ។ គេមិនអាចដាក់ចោរនិងអ្នកដែលត្រូវគេលួច ក្នុងឋានៈស្មើគ្នាទេ» ។ គេមិនអាចសំគាល់សហភាពសូវៀតឲ្យច្បាស់ជាងនេះទៀត ដោយមិនចង្អុលឈ្មោះផងទេ ។ ម៉្យាងទៀត, ឃ្លានេះ, ដែលត្រូវបានប្រកាសក្នុងពិធីជប់លៀងមួយជាកិត្តិយសដល់សីហនុ, ត្រូវបានយកទៅចុះផ្សាយតាមទិន្នានុប្បវត្តិ ហើយចេញផ្សាយជាថ្មីទៀតក្នុងសប្តាហ៍ទិន្នានុប្បវត្តិ «ប៉េកាំង-អ៊ិហ្វ័រមេហ្សិន» នៅថ្ងៃទី១៨តុលា១៩៦៥, ប្រហែលដើម្បីផ្តាច់សីហនុពីភាគីសូវៀត ។

បន្ទាប់ពីអ្វីដែលគាត់បានហៅនៅពេលក្រោយថា «ការផ្តើនបំបាក់មុខនៅព្យុងយ៉ាង», សីហនុបានប្រព្រឹត្តកំហុសមួយទៀតក្នុងពេលត្រឡប់មកប្រទេសចិនប្រជាមានិតវិញ ។ ក្នុងថ្ងៃទី១០តុលា១៩៦៥, នៅខាប៉ីន, ដែល លីវ-ចាវជី និងសេនាប្រមុខ ចេន-ឃី បានធ្វើដំណើរជាពិសេសពីប៉េកាំងដើម្បីទៅទទួលគាត់, ក្នុងឱកាសជប់លៀងនៅពេលមកដល់ ដែលរៀបចំឡើងដោយ លី-ហ្ស៊ានវូ ចៅហ្វាយខេត្ត ហេឡុងគៀង, សីហនុបានប្រកាសនៅចំពោះមុខម្ចាស់ផ្ទះចិនថា ៖ «បើមហាអំណាចទាំងឡាយ ដែលថាស្រឡាញ់សន្តិភាព បានប្រកាសយកដូចប្រទេសចិននូវអាកប្បកិរិយាម៉ឺងម៉ាត់ ប្រឆាំងចក្រពត្តិនិយមអាមេរិកាំង, ហើយបើមហាអំណាចទាំងនោះ បានបន្តដូចប្រទេសចិន នូវនយោបាយគាំទ្រយ៉ាងម៉ឺងម៉ាត់ដល់យៀកណាមនិងកម្ពុជា ព្រមទាំងដល់ការតស៊ូរបស់ប្រជាជាតិទាំងឡាយក្នុងពិភពលោក នោះប្រហែលពួកឈ្មោះសង្គ្រាមអាមេរិកាំង នឹងដកខ្លួនពីប្រទេសទាំងឡាយ ដែលពួកគេបានសាបព្រួសអសន្តិសុខនិងសង្គ្រាម តាំងពីយូររួចហើយ» ។ បន្ទាប់មក, សីហនុបានកត់សំគាល់ថា ៖ «មហាអំណាចជាច្រើនដែលថាប្រឆាំងចក្រពត្តិនិយមមិនបានដឹកនាំដូចប្រទេសចិន នូវការតស៊ូដោយគ្មានសំរុះសំរួលប្រឆាំងចក្រពត្តិនិយមទេ, ហើយមិនអាចជួយប្រជាជាតិទាំងឡាយ ឲ្យមានសន្តិភាព ឲ្យទទួលបាន ឬរក្សាឯករាជភាពនៅក្នុងបូរណភាពដែនដី, ឲ្យឈ្នះលើការជិះជាន់, លើការគំរាមកំហែងពីចក្រពត្តិនិយមអាមេរិកាំងជាឈ្មួញសង្គ្រាមទេ» ។ ហើយគាត់បានបន្ថែមថា «មហាអំណាចទាំងនេះ មិនដែលបានគិតដល់វត្ថុជាទីប្រាថ្នានៃប្រជាជនដែលរងគ្រោះ, ដូចជាប្រជាជនយៀកណាម, ដែលតាមពិត ដំណោះស្រាយមិនបានជួយដល់ប្រជាជននេះទេ, ប៉ុន្តែបានជួយសំរួលដល់ការបន្តនូវអំពើឈ្លានពានពីអាមេរិកាំង ប្រឆាំងប្រជាជនយៀកណាមទៅវិញ» ។

ពេលមកដល់ភ្នំពេញវិញ, នៅថ្ងៃទី១៧តុលា១៩៦៥, ស្តេចសីហនុបានធ្វើ«សេចក្តីរាយការណ៍មួយទៅកាន់ប្រជាជាតិ» មានរយៈពេលជាងបួនម៉ោង ដោយបញ្ជាក់ថាបានសំរេចត្រឹមតែបញ្ហាតិចតួច «ដែលអាចធ្វើឲ្យខកចិត្ត, តិចឬច្រើន, ដល់សហភាពសូវៀត, ថ្វីបើពាក្យសូវៀតពុំត្រូវបានពោលដល់សោះឡើយ» ។ ប៉ុន្តែសីហនុបាន ផ្តល់ទៅអ្នកស្តាប់នូវ«យោបល់បីបែបរបស់សមាជិកនៃគណប្រតិភូមួយចំនួន» ដែលអាចឲ្យយល់អំពីអាកប្បកិរិយារបស់សហភាពសូវៀត ៖

១- «មុនសុន្ទរកថារបស់ខ្ញុំករុណានៅប៉េកាំងនិងព្យុងយ៉ាង, ពួករុស្ស៊ីជឿជាក់ថា នៅមានភ័ព្វល្អដើម្បីបន្ធូរជំហររបស់យើង ស្តីអំពីយៀកណាមនិងការតស៊ូប្រឆាំងចក្រពត្តិនិយម ដោយចង់គំរាមក្នុងការផ្តល់ជំនួយជាដើម ។ បន្ទាប់ពីសុន្ទរកថាទាំងនេះ, ពួករុស្ស៊ីយល់ថា ក្តីសង្ឃឹមរបស់គេត្រូវបរាជ័យ ដូច្នេះរុស្ស៊ីផ្តាច់ស្ពាន» ។

២- «យើងជាជនរងគ្រោះនៃការលុបលាង នូវដំណើរអាក់អន់ចិត្ត ដែលសហភាពសូវៀតបានជួបប្រទះ ក្នុងទំនាក់ទំនងជាមួយចិនប្រជាមានិត ដែលជាមិត្តទី១របស់យើង ។ ដោយចាត់ទុកយើងថា កាន់ជើងចិន, ពួកសូវៀតសំរេចចិត្តសន្មត់យើងជាអ្នកប្រឆាំងរុស្ស៊ី» ។

៣- «ទាំងនេះគ្រាន់តែជាការសំដែងនូវគំនិត ខាងប្រកាន់ពូជសាសន៍ប៉ណ្ណោះ ។ ពួករុស្ស៊ីខិតទៅជិតអាមេរិកាំង ពីព្រោះដូចពួកគេដែរ, អាមេរិកាំងជាសាសន៍ស។ ចំពោះរុស្ស៊ី, គ្រោះថ្នាក់លឿងជាបឋមគឺចិន, ហើយអ្នកទាំងឡាយដែលជាមិត្តរបស់ចិន ជាសត្រូវរបស់ពួកគេ» ។

ពីរបីថ្ងៃក្រោយមក, សីហនុបានប៉ុនប៉ងធ្វើសេចក្តីរាយការណ៍នេះជូនប្រជាជាតិ ឲ្យបោះជំហានទៅក្រោយ ដោយប្រកាសនៅចំពោះមុខមេបញ្ជាការយោធាសំខាន់ៗនៅក្នុងរាជវាំងថា ៖ «យើងមិនមែនជាប្រជាជាតិអកត្តញ្ញូ ដែលគេអាចនិយាយបានថាឧប្បត្តិហេតុរបៀបនៅព្យុងយ៉ាង ជាកត្តាគ្រប់គ្រាន់ ដើម្បធ្វើឲ្យប្រជាជាតិយើង ភ្លេចអស់រាល់អំពើល្អដែលយើងបានទទួលទេ ។ ហើយយើងនៅតែរក្សាកត្តញ្ញូធម៌ចំពោះប្រជាជនសូវៀត ដ៏អង់អាចនិងឧត្តុងឧត្តម ។ ប៉ុន្តែ, ប្រសិនជាទំនាក់ទំនងរបស់យើងត្រូវចុះខិនថយ រហូតដល់ចំណុចនៃការបាត់បង់នូវផលប្រយោជន៍របស់យើង ដែលយើងបានទទួលជាជំនួយពីសហភាពសូវៀតមកទល់ពេលនេះ, ប្រជាជននិងកងទ័ពរបស់យើងអាចធ្វើពលិកម្ម ដោយស្ម័គ្រចិត្តហើយអត់ទ្រាំ ព្រោះតែមិនឲ្យបាត់បង់ឯករាជភាព, សេចក្តីថ្លៃថ្នូរ និងកិត្តិនាមរបស់ខ្លួន ។ ខ្ញុំករុណានឹងប្រាប់ទៅមូស្គូនិងប៉េកាំង ឲ្យជ្រើសរើសរវាងការធ្វើកម្ពុជាឲ្យទៅជាកុម្មុយនិស្តនិងការទុកកម្ពុជាឲ្យនៅអព្យាក្រឹត, គឺអ្វីដែលជាដំណោះស្រាយប្រសើរបំផុតសំរាប់ពួកគេ» ។

ក្រោយរដ្ឋប្រហារ នៅថ្ងៃទី១៨មិនា១៩៧០, មូស្គូពុំដែលបានទទួលស្គាល់រដ្ឋាភិបាលក្រៅស្រុករបស់សីហនុនៅប៉េកាំងទេ ហើយស្ថានទូតរបស់សហភាពសូវៀតប្រចាំភ្នំពេញនៅបើកដដែល, ដែលត្រូវបានដឹកនាំដោយក្រុមភារធារី ។ ដោយត្រូវបានសម្ភាសន៍ ពីវិទ្យុស្វីស-រ៉ូម៉ង់ នៅខែធ្នូ១៩៧០, សីហនុបានថ្លែងថា ៖ «ជាដំបូង, ខ្ញុំករុណាគិតថា សូវៀតនឹងគាំទ្រខ្ញុំ, ប៉ុន្តែ នៅពេលខ្ញុំធ្លាក់ចេញពីអំណាច, សូវៀតបោះបង់ខ្ញុំចោល» ។ ពេលក្រោយមកទៀត, នៅថ្ងៃទី១៣មេសា១៩៧១, ឯប៉េកាំង, សីហនុបានបង្ហាញឲ្យឃើញភាពល្វីងជូរចត់របស់គាត់ ស្ដីពីអាកប្បកិរិយានៃរដ្ឋាភិបាលសូវៀត ៖ « រុស្សីគិតថាខ្ញុំជាអាយ៉ងរបស់ចិន ។ សូម្បីបុត្ររបស់ខ្ញុំករុណា, និស្សិតនៅមូស្គូត្រូវវាយប្រតប់ ជាមួយមិត្តភក្តិទាំងឡាយ ដែលបានចាត់ទុកខ្ញុំជាស្ដេចដែលប្រើអំណាចផ្ដាច់ការ ។ ឥឡូវ, រដ្ឋាភិបាលសូវៀតនិងអាល្លឺម៉ង់ខាងកើតផ្ដល់អាហារូបករណ៍ទៅពួកនិស្សិតហ្វាស៊ីស ដែលត្រូវបានបញ្ជូនដោយលន់-នល់ ។ រុស្សីមិនចូលចិត្តពួកអង្គម្ចាស់ទេ, គេស្រឡាញ់អ្នកសាធារណរដ្ឋ, ទោះបីនៅក្នុងកណ្ដាប់ដៃរបស់ចក្រពត្តិនិយម ដូចនៅភ្នំពេញក៏ដោយ» ។

នៅឆ្នាំ១៩៦៥, ដោយការពារខ្លួនពីលក្ខណៈជា«អាយ៉ងនៅក្នុងកណ្ដាប់ដៃរបស់ចិន», បន្ទាប់ពីបានវាយប្រហារជាញឹកញាប់, យោងតាមសំនៀងរបស់គាត់ «យួនវាតទីនិយម» ពីគ្រាមុន, សីហនុបានចូលរួមជាមួយទស្សនកថាចិន «សង្គ្រាមរំដោះប្រជាជន»យូរអង្វែង របស់ប្រជាជនឥណ្ឌូចិន ។ ដោយភ្លេចគិតថា, ជាច្រើនគ្រា, គាត់បានចាត់ទុកយួនតាមផ្លូវការ ជា«អ្នកលេបទឹកដីខ្មែរ», សីហនុមិនបានរារែកទេដើម្បីប្រកាសថា ៖ «បើព្រេងវាសនាតម្រូវឲ្យ ខ្ញុំករុណាកើតមកជាជនជាតិយៀកណាមនោះ, ខ្ញុំនឹងធ្វើជាយៀកកុងតាំងពីនៅកូនខ្ចី» ។

ប្រយោគដ៏មានអត្ថន័យធ្ងន់ធ្ងរសំរាប់អនាគតកាលនេះ មិនត្រឹមតែត្រូវបានប្រកាស និងថតទុកនាឱកាសសម្ភាសន៍ ដែលសីហនុបានផ្ដល់ទៅក្រុមវិទ្យុទូរទស្សន៍អាមេរិកាំង អេ.ប៊ី.ស៊ី. ប៉ុណ្ណោះទេ គឺសីហនុបានដាក់ឲ្យចុះផ្សាយឡើងវិញក្នុងលេខទី១នៃទស្សនាវដ្ដីនយោបាយ «សង្គមរាស្ត្រនិយម» ដែលខ្លួនគាត់ជានាយក, នៅខែសីហា១៩៦៥ ។

សីហនុមិនបានរង់ចាំរហូតដល់សេចក្ដីប្រកាសនេះ, ដែលស្ទើរតែជាផ្លូវការ, ដើម្បីបង្ហាញពីអ្វីដែលជាអត្ថន័យចំពោះ «អព្យាក្រឹតភាពខ្មែរ» សំរាប់រូបគាត់ នៅចំពោះមុខពួកកុម្មុយនិស្តយួនទេ ។ ចាប់ពីឆ្នាំ១៩៥៥ គាត់បានបណ្ដោយឲ្យពួកជឿនលឿននិយមយួន ភៀសខ្លួនមកកម្ពុជា ។ នៅឆ្នាំ១៩៦៣, មេដឹកនាំ«រណសិរ្សរំដោះយួនខាងត្បូង» និងមិនមែនថ្នាក់ក្រោម បានមកស្នាក់នៅក្រុងភ្នំពេញ ឬតាមស្ថានីយ៍សំរាប់លំហែរប្រមាត់សមុទ្រ ដែលមានរមនិយភាពជាងព្រៃម៉ាគីស៍ ។ ដូចជា

ករណីរបស់ ត្រាន់-ប៊ូគៀម, សមាជិកសភានៃរណសិរ្សរំដោះយួនខាងត្បូង, ហើ-យនៅជំនាន់នោះ ជាប្រធាននៃគណៈកម្មការខាងទំនាក់ទំនងក្រៅប្រទេស ឬជារដ្ឋមន្ត្រីនៃក្រសួងការបរទេសរបស់«រណសិរ្ស»យៀកកុង ។

កើតនៅឆ្នាំ១៩២០ ឯកងថី, ត្រាន់-ប៊ូគៀម ជាប្រធាននៃសហភាពនិស្សិតរំដោះ និងជាសមាជិកនៃគណៈកម្មាធិការមជ្ឈឹមរបស់គណបក្សប្រជាធិបតេយ្យ ។ ក្នុងឋានៈនេះ, នៅឆ្នាំ១៩៤៦, គៀមជាប្រតិភូរបស់បក្សក្នុងគណៈកម្មាធិការមជ្ឈឹម «លៀនវៀត» ហើយព្រមជាមួយគ្នា ជាអនុប្រធានផ្នែកសេដ្ឋកិច្ចនៃរដ្ឋាភិបាលបណ្តោះអា-សន្នរបស់ហូ-ជីមិញ ។ រហូតដល់កិច្ចព្រមព្រៀងក្រុងហ្សឺណែវ, ត្រាន់-ប៊ូគៀមបានដឹកនាំទ័ពព្រៃយៀកមិញ, បានប្រមូលផ្តុំនិស្សិត ហើយបានធ្វើទំនាក់ទំនងជាច្រើន ជាមួយដៃជើងហូ-ជីមិញ ។ នៅឆ្នាំ១៩៥៩, គៀម បានសំរេចចិត្តទៅហាណូយ ប៉ុន្តែបានត្រឡប់ដោយសម្ងាត់មកយួនខាងត្បូងវិញ នៅឆ្នាំ១៩៦០ ។ ត្រាន់-ប៊ូគៀម ត្រូវបានចាត់ទុកជា «ជនក្រហម» ដោយមិត្តចាស់ៗ ។ បន្ទាប់ពីបានដឹកនាំគណប្រតិភូនៃរណសិរ្សរំដោះយួនខាងត្បូង ក្នុងកិច្ចការនាក្រុងប៉ារីសនៅឆ្នាំ១៩៦៩ ត្រាន់-



ត្រាន់-ប៊ូគៀម និង នរោត្តម-សីហនុ

ប៉ូគៀមបានក្លាយជារដ្ឋមន្ត្រីនៅក្នុងការដឹកនាំនៃ«រដ្ឋាភិបាលបដិវត្តន៍បណ្ដោះអាសន្ន» របស់យៀកកុង ។

នៅខែកក្កដា១៩៦៣, ក្នុងភូមិគ្រឹះមួយនៅទីក្រុងកែប ប្របតាមឆ្នេរសមុទ្រនៃឈូងសមុទ្រសៀម, ត្រាន់-ប៉ូគៀម បានទទួលអ្នកសារពត៌មានជាបារាំង ហ្ស៊ែកហ្ស៍ ហ្សាហ៊្វា ដែលគៀមបានផ្ដល់ការសម្ភាសន៍មួយ ដែលសារពត៌មាន ឡឺម៉ុង បានយកមកចុះផ្សាយនៅថ្ងៃទី២៨សីហា១៩៦៣, ហើយនៅឱកាសនោះ គៀមសំដែងដោយស្មោះត្រង់ចិត្ត នូវសេចក្ដីសង្ឃឹមសំរាប់អនាគតនៃយួនខាងត្បូង ។

គេបានឃើញត្រាន់-ប៉ូគៀមផងដែរ នៅក្រុងភ្នំពេញក្នុងឆ្នាំ១៩៦៥ ប៉ុន្តែម្ដងនេះតាមផ្លូវការ ក្នុងនាមជាបុគ្គលិកទី២នៃគណប្រតិភូរបស់រណសិរ្សរំដោះយៀកកុង នាឱកាសសន្និសិទនៃប្រជាជនឥណ្ឌូចិន ដែលរៀបចំឡើងដោយស្ដេចសីហនុ។ ត្រាន់-ប៉ូគៀមបានអមដំណើរ មេដឹកនាំនៃគណប្រតិភូ វិញ-តាន់ផាត, ជាអនុប្រធាននិងជាអគ្គលេខាធិការនៃរណសិរ្សរំដោះយៀកកុង ដែលនៅពេលនោះជាប្រធាននៃរដ្ឋាភិបាលបដិវត្តន៍បណ្ដោះអាសន្នយៀកកុង ។ ដោយសារត្រាន់-ប៉ូគៀមបានទទួលអ្នកសារពត៌មាន២-៣នាក់នៅក្នុងបន្ទប់ដែលគៀមស្នាក់នៅឯសណ្ឋាគារមនោរម្យ ក្នុងក្រុងភ្នំពេញ, គៀមបានកត់សំគាល់ថា វិញ-តាន់ផាត ត្រូវបានការពារហ្មត់ចត់ ដោយ«ជើងខ្លាំងពីរបីនាក់នៃក្រសួងសន្តិសុខខ្មែរ» ។ ក្រុមអង្គរក្សទាំងនេះ ត្រូវបានចាត់តាំងសំរាប់សេចក្ដីត្រូវការរបស់ពួកមេដឹកនាំនៃរណសិរ្សរំដោះជាតិយៀកកុង និងគណប្រតិភូកុម្មុយនិស្តដទៃទៀត តាមបញ្ជាផ្ទាល់ពីសីហនុ ។

ប្រមុខរដ្ឋខ្មែរពេលនោះ បានទទួលមេដឹកនាំផ្សេងទៀត របស់រណសិរ្សរំដោះជាតិយៀកកុងជាច្រើនលើក, «សាស្ត្រាចារ្យ» ង្វៀង-វ៉ាន់ហៀវ, ជាអង្គទូតគោចរដែលជា«អ្នកផ្ដល់ពត៌មានសម្ងាត់»របស់ប្រាហ្គ, បេសកកម្មមួយក្នុងចំណោមបេសកកម្មទូតដំបូងទាំងឡាយរបស់អង្គការនេះ ។ ក្នុងពេល ង្វៀង-វ៉ាន់ហៀវ មកតាំងតំណាងអចិន្ត្រៃយ៍នៅភ្នំពេញ ក្នុងថ្ងៃទី១៩ កក្កដា ១៩៦៦, សីហនុបានពន្យល់ជាបន្ទាន់ ទោះជាផ្ទុយនឹងពិធីការ នូវលក្ខន្តិកៈសំរាប់ទូត ។ អំណើះតទៅ, រណសិរ្សរំដោះជាតិយៀកកុង មានអភ័យឯកសិទ្ធិសំរាប់ស្ថានទូត ។ ភាពមិនអាចប៉ះពាល់បានក្នុងការឆ្លើយឆ្លងគ្នា ជាវត្ថុកម្រក្នុងរបបសីហនុ ដែលខុទ្ទកាល័យងងឹតមួយមានដំណើរការជានិច្ច- ទំនាក់ទំនងវិទ្យុ-ទូរលេខជាមួយរដ្ឋាភិបាលយៀកកុង ដោយរដ្ឋាភិបាលបដិវត្តន៍បណ្ដោះអាសន្នយៀកកុង នៅពុំទាន់មានរដ្ឋធានី, គេយល់អំពីការប្រើប្រាស់ដែលរណសិរ្សរំដោះជាតិយៀកកុងចាត់ចែង តាមរយៈស្ថានិយផ្សាយនៅភ្នំពេញ ។ល។ សីហនុមិនបានរុញរាទេ ក្នុងការចាត់ទុក ង្វៀង-វ៉ាន់ហៀវ ជា«អង្គទូតខ្ពង់ខ្ពស់ ដែលត្រេកត្រអាលដោយទំនុកទុកចិត្ត និងការលើកតម្លៃពីយើង» ។

សីហនុ, ដោយអនុវត្តជាថ្មីម្ដងទៀតនូវ « ការសង្កត់បញ្ជាក់ដំណើរការ ដោយ

ត្រួតពិនិត្យការវិវត្តន៍», បានបោះជំហានជាលើកដំបូងទៅរកយៀកកុង, ដែលបានប្រកាសជាផ្លូវការ អំពីការសំរេចចិត្តរបស់គេ «ដើម្បីទទួលស្គាល់ និងគោរពព្រំដែនបច្ចុប្បន្នរបស់ខ្មែរ» តែនៅត្រឹមពេលជិតមួយឆ្នាំបន្ទាប់មក, ក្នុងថ្ងៃទី៦ មិថុនា ១៩៦៧ តាមរយៈលិខិតរបស់ ង្វៀង-ហ៊ឺ ថ, ជាប្រធានសភារបស់គណៈកម្មាធិការមជ្ឈឹមក្នុងរណសិរ្សរំដោះជាតិយៀកកុង ។ ពីរឆ្នាំក្រោយមក, សីហនុទទួលស្គាល់រដ្ឋាភិបាលបដិវត្តន៍បណ្ដោះអាសន្នយៀកកុងតាមផ្លូវការ ដែលជាការប្រឆាំងទាំងស្រុងជាមួយរដ្ឋាភិបាលស្របច្បាប់នៅយួនខាងត្បូង, ហើយនៅថ្ងៃទី១៦ មិថុនា ១៩៦៩, ង្វៀង-វ៉ាន់ហៀវ ប្រគល់សារតាំងទៅសីហនុ ក្នុងឋានៈខ្លួនជាឯកអគ្គរដ្ឋទូតយៀកកុង ។ ដោយបន្តតាមអ្វីដែលគាត់ហៅថា នយោបាយ«អព្យាក្រិត»របស់គាត់, សីហនុបានទទួលសារតាំងពី ង្វៀង-ថុង, ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាធិបតេយ្យយួនខាងជើងនៅកម្ពុជា ។

សីហនុពុំមែនមិនដឹងទេថា តាំងពីច្រើនឆ្នាំមកហើយ កងកម្លាំងយួនខាងជើងនិងយៀកកុងបានមកតាំងនៅតាមផ្នែកទាំងឡាយ ដែលមិនសូវសំបូរប្រជាជនក្នុងរាជាណាចក្រ, នៅខេត្តនានាខាងភូមិភាគឦសាន ។ នៅខណៈដែលគាត់បានទទួលស្គាល់រដ្ឋាភិបាលឧទ្ទាម គឺរដ្ឋាភិបាលបដិវត្តន៍បណ្ដោះអាសន្នយៀកកុង, សីហនុជំទាស់, ព្រមពេលគ្នានិងជាលើកទីមួយ, ដល់ការកាន់កាប់នៅលើផ្នែកមួយចំនួននៃខេត្តទាំងឡាយរបស់ខ្មែរ ដោយពួកកុម្មុយនិស្តយួន ។ ក្នុងសន្និសិទសារព័ត៌មានរបស់គាត់ នៅថ្ងៃទី១១ មិថុនា ១៩៦៩ សីហនុបានអះអាងថា ក្នុងខេត្តរតនគីរីដែល



ស្ដេចសីហនុកំពុងបង្ហាញផែនទីជំរកយៀកកុងនៅលើទឹកដីខ្មែរដល់ពួកអ្នកកាសែត (ថ្ងៃទី២៨ មិនា ១៩៦៩)

ជាប់នឹងយួនខាងត្បូង, ពួកយៀកកុងនិងយួនខាងជើង «បានមកតាំងនៅជាស្រេចតាមភូមិទាំងឡាយក្នុងតំបន់នានា ដែលស្ថិតនៅឆ្ងាយពីផ្លូវគមនាគមន៍, ប៉ុន្តែសំបូរដោយជីវជាតិ ហើយស្រោចស្រពដោយទន្លេ, ស្ទឹង, ព្រែកជាច្រើន ។ ពួកកុម្មុយនិស្តយួនបានតែងតាំង «អភិបាល»មួយសំរាប់ពួកគេ «ដែលមានមនុស្សប្រហែល ៦០នាក់ ប្រដាប់ដោយកាំភ្លើងស្វ័យប្រវត្តិចិន និងគ្រាប់បែក នៅក្រោមបញ្ជារបស់ពួកគេ», ដែលឆ្លងកាត់ «មួយខែម្តង តាមភូមិដើម្បីឃោសនានៅទីនោះ» ។ ក្នុងឱកាសសន្និសិទសារពត៌មាននេះ សីហនុចាប់ផ្តើមបើកកកាយអំពីរបបភេរវកម្មដែលសាបព្រួស ដោយពួកកុម្មុយនិស្តយួននិងពួកភ្នាក់ងាររបស់គេ ដែលរស់នៅតាមភ្នំក្នុងតំបន់ទាំងនេះ «អ្នកភូមិទាំងឡាយដែលស្មោះត្រង់ជាមួយរាជរដ្ឋាភិបាលខ្មែរត្រូវបានសម្លាប់ចោលតាមប្រព័ន្ធច្បាស់លាស់ ។ ដើម្បីសម្លាប់ជនទាំងនេះ មុនដំបូងគេចងដៃជើង រួចមកកចងរឹតកដោយខ្សែ ឬគាបកដោយដំបងឫស្សី» ។

កងទ័ពនៃរាជរដ្ឋាភិបាល, ដោយគ្មានគ្រឿងអាវុធគ្រប់គ្រាន់, មិនអាចកំចាត់បានទេ នូវអំពើឈ្លានពាននេះ, ដែលស្ថិតនៅក្រោមកិច្ចការពារសំងាត់ពីប្រមុខរដ្ឋខ្មែរ ។ មិនតែប៉ុណ្ណោះ, ចាប់ពីឆ្នាំ១៩៦៦, តាមបញ្ជាពីសីហនុ, រាជរដ្ឋាភិបាលបានអនុញ្ញាតលក់ទៅឲ្យយៀកកុង នូវអង្ករ៨០,០០០តោន គិតជាប្រាក់ដុល្លារ ។ លើសពីអង្ករមានការរត់ពន្ធគោ ក្របី ជ្រូក ក្រណាត់ កង់រថយន្ត សញ្ញាអង្ករ ជាមួយយៀកកុង ។ ការលក់ដូរទាំងនេះត្រូវបានគិតជាប្រាក់រៀលខ្មែរ ឬជាដុល្លារហុងកុង ។ សន្សឹមៗដែលការរត់ពន្ធទាំងនេះកាន់តែរីកដាលបន្តិចម្តងៗ, មួយផ្នែកនៃទឹកប្រាក់ដ៏ធំធេងបានធ្លាក់ក្នុងកណ្តាប់ដៃរបស់ឈ្មួញចិននិងយៀកកុង ដែលក្លាយទៅជាមធ្យោបាយមួយសំរាប់ពួកនេះ ក្នុងការធ្វើសម្ពាធលើរាជរដ្ឋាភិបាល ។

សីហនុគ្មានអនុភាពដើម្បីរើបំរះ, ព្រោះគាត់ពុំមែនមិនដឹងទេថា ក្រសួងតម្រួតទាំងមូលស្ថិតនៅក្រោមការកាន់កាប់របស់អ៊ុំ-ម៉ាណូរិន ដែលត្រូវជាបងប្រុសរបស់ជាយានៃប្រមុខរដ្ឋខ្មែរ ។ ម្យ៉ាងទៀតផ្សារលក់ទំនិញទាំងនេះ មានដំណើរការតាមសំដីផ្ទាល់មាត់ ដូចគ្នានឹង ការអនុវត្តន៍បែបនេះនៅតំបន់អាស៊ីជាមួយ«អាហារ័ណនីហារ័ណ», ជាក្រុមហ៊ុនសេដ្ឋកិច្ចចំរុះ មានបន្ទុកលើរាល់ប្រតិបត្តិការ«នាំចេញ-នាំចូល» ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៦៣ ក្នុងឱកាសធ្វើជាតូបនិយកម្មសេដ្ឋកិច្ច បន្ទាប់ពីការទាត់ចោលនូវជំនួយអាមេរិកាំង ។ នៅឆ្នាំ១៩៦៦, ក្រុមហ៊ុនត្រូវចូលក្នុងរដ្ឋបនិយកម្ម ។

គឺចាប់ពីកាលបរិច្ឆេទនេះ ដែលការរត់ពន្ធទៅឲ្យយៀកកុង បានឡើងដល់កំរិតទូលំទូលាយបំផុត ដោយមិនរួមបញ្ចូលត្រឹមតែការផ្តល់នូវផលិតផលជាស្បៀងអាហារ និងសំលៀកបំពាក់ប៉ុណ្ណោះទេ ប៉ុន្តែកាន់តែធ្ងន់ខ្លាំង គឺការបញ្ជូនជាគ្រឿងអាវុធ និងសម្ភារ:ចំបាំង ។ ចាប់ពីខែធ្នូ១៩៦៦ទៅដល់ខែមេសា១៩៦៩, គ្រឿងអាវុធនិងយុទ្ធោបករណ៍ទម្ងន់២១តោន ដែលត្រូវសំដៅទៅពួកកុម្មុយនិស្តយួន បានមក

ដល់កំពង់ផែនៅកំពង់សោម ហើយត្រូវបានបញ្ជូនទៅតំបន់ទល់ដែនខ្មែរ-យួន ជាទីដែលកងកម្លាំងយៀកកុងនិងយួនខាងជើងតាំងនៅ ។ តាមធម្មតាការដឹកជញ្ជូនគ្រឿងអាវុធពីកំពុងផែហៃហ្វុង ដោយកាត់តាមប្រទេសខ្មែរនិងលាវ មកកាន់ទីតាំងទាំងឡាយរបស់យៀកកុងនៅយួនខាងត្បូង ត្រូវមានចម្ងាយ២,៨០០គ.ម. ។ ក្នុងដំណើរដ៏លំបាកតាមផ្លូវលំហូ-ជីមិញ ដែលប្រព្រឹត្តទៅបានតែនៅក្រៅរដូវភ្លៀង រថយន្តបន្ទុក១៣,៨០០គ្រឿង ដែលដឹកគ្រឿងអាវុធនិងសម្ភារៈសឹក បានមកពីសូវៀត ចិន និងប្រទេសកុម្មុយនិស្តផ្សេងទៀត សំរាប់ផ្តល់ទៅឲ្យយៀកកុងនៅយួនខាងត្បូង ត្រូវបានកំទេចដោយកងអាកាសចរណ៍អាមេរិកាំង ។ ប៉ុន្តែ, ចម្ងាយផ្លូវពីកំពង់ផែកំពង់សោមទៅព្រំដែនខ្មែរ-យួន មានតែជាង៥០០គ.ម.ប៉ុណ្ណោះ ហើយប្រកបដោយសន្តិសុខគ្រប់គ្រាន់ ។ ការលក់គ្រឿងអាវុធ ក៏បានបានទទួលការចូលរួមដូចគ្នាជាមួយការរត់ពន្ធអង្ករ និងផលិតផលផ្សេងៗ ពីសំណាក់សមាជិករបស់ក្រុមគ្រួសារផ្ទាល់នៃជាយារបស់ប្រមុខរដ្ឋខ្មែរ ។

ខ្លួនខ្ញុំផ្ទាល់នៅចងចាំពាក្យពេចន៍ក្នុងសង្គមថារបស់សីហនុនៅឆ្នាំ១៩៦៤ថា ៖ « បើចក្រពត្តិនិយមអាមេរិកាំងហ៊ានធ្វើសង្គ្រាម, ខ្មែរហ៊ានចំណោញ» ។ ប៉ុន្តែ, អនិច្ចានៅដំណាច់ឆ្នាំ១៩៦៤ ក្នុងហិបប្រាក់ជាតិមានសល់តែ១៤០លានរៀលប៉ុណ្ណោះ ក្នុងចំណោមទឹកប្រាក់ដែលត្រូវមានដល់៧,០០០លានរៀល សំរាប់ចំណាយក្នុងប្រទេ-ស គឺត្រឹមតែ២% ។ ធ្ងន់ធ្ងរជាងនេះទៅទៀត រាជរដ្ឋាភិបាលបានប្រកាសប្តូរក្រដាស់ប្រាក់៥០០រៀលថ្មី ពីព្រោះក្រដាស់ប្រាក់៥០០រៀលចាស់ ឬក្រដាស់ផាងត្រាវ ត្រូវបានយៀកកុងបោះពុម្ពដោយក្លែងបន្លំ ដើម្បីយកមកទិញផលិតផល ធនធានរបស់ខ្មែរ សំរាប់ធ្វើសង្គ្រាមនៅយួនខាងត្បូង ។ ជាលើកទី២ហើយ ដែលយួនប្រើស្ទៀតនេះ ។ ក្នុងភាពយន្តឯកសារ «ឥណ្ឌូចិនបារាំង» វូ-កុកធឹក, ដែលនៅឆ្នាំ១៩៤៦ ជាសមាជិកនៃគណៈកម្មាធិការតស៊ូយៀកមិញ ហើយនៅឆ្នាំ១៩៥៥ ជារដ្ឋមន្ត្រីនៃរដ្ឋាភិបាលបៅដាយ, និយាយអួតអាងទាំងញញឹមថា ៖ «ខ្ញុំដឹងថា ហូ-ជីមិញ បានប្រុងប្រៀបសង្គ្រាមតស៊ូជាមួយបារាំង ។ ខ្ញុំមានមិត្តភក្តិនៅក្នុងផ្នែករដ្ឋបាលហិរញ្ញវត្ថុនៃក្រសួងហិរញ្ញវត្ថុរបស់ហូ-ជីមិញ ។ គេបានចាប់ផ្តើមបោះពុម្ពក្រដាស់ប្រាក់ដែលមានរូបហូ-ជីមិញ, រួចហើយគេជំរុញឲ្យប្រជាជនយួនទាំងអស់ទូទាំងប្រទេសចាយវាយបញ្ចូលគ្នា ជាមួយក្រដាស់ប្រាក់ «ព្យាស» របស់«ធនាគារឥណ្ឌូចិនបារាំង» ដែលសំរាប់ចាយវាយក្នុងប្រទេសខ្មែរ លាវ និងយួន ។ លោកដឹងទេថា ក្រដាស់ប្រាក់ហូ-ជីមិញគ្មានតំលៃនៅលើផ្សារប្តូរប្រាក់អន្តរជាតិមែន ប៉ុន្តែក្រដាស់ប្រាក់ «ព្យាស»នៃឥណ្ឌូចិនបារាំង ត្រូវបានធានាអះអាងដោយអាថ្នាធរនៃអាណាណិគមបារាំង ។ ដូច្នេះ គេមានឱកាសសំរាប់ធ្វើសង្គ្រាម ទិញគ្រឿងអាវុធ និងចេញប្រាក់បៀវត្សឲ្យអ្នករដ្ឋការនៅហាណូយ» ។ អ្វីៗទាំងនេះបានកន្លងផុតទៅហើយ ហើយត្រូវបញ្ចប់ត្រឹមពាក្យសារភាពរបស់សីហនុ ដែលត្រូវបានយកមកផ្សព្វផ្សាយ តាមវិទ្យុ

សម្លេងអាស៊ីនៅក្រុងប៉ារីសក្នុងឆ្នាំ១៩៨៩ថា ៖ «ខ្ញុំករុណាបានជួយយួនយ៉ាងសំបើម ក្នុងនាមអ្នកស្នេហាជាតិនៅជិតខាងគ្នា» ។

ក្នុងខែកក្កដា១៩៦៩, នៅភ្នំពេញ, បន្ទាប់ពីបានទទួល វិញ-តាន់ផាត ជាផ្លូវការតាមឋានៈជាប្រធាននៃរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្នយៀកកុង, សីហនុ ពីរខែក្រោយមកបានចុះហត្ថលេខាជាមួយរដ្ឋាភិបាលនៃក្រុងហាណូយ និងរដ្ឋាភិបាលយៀកកុង សំរាប់រណសិរ្សនៅយួនខាងត្បូង លើ«កិច្ចព្រមព្រៀងពាណិជ្ជកម្មនិងការបង់ប្រាក់» ។ កិច្ចព្រមព្រៀងនេះ ដែលជាការធានាអះអាង ត្រូវបានសំរេចឡើងត្រឹមតែ ដើម្បីលាក់បាំងការបញ្ជូនគ្រឿងអាវុធទៅឲ្យយៀកកុងនិងយួនខាងជើងប៉ុណ្ណោះ ដែលពលទាហានពី៤០,០០០ទៅ៥០,០០០នាក់ បានមកតាំងទីជាស្រេចក្នុងដែនដីខ្មែរ ។ ត្រង់ចំណុចនេះហើយ ដែលពាក្យស្នើររបស់ សាឡុត-សរ នៅក្រុងហាណូយក្នុងឆ្នាំ១៩៦៥-១៩៦៦ ដើម្បីទទួលការអនុញ្ញាតសំរាប់ការតស៊ូផ្នែកអាវុធប្រឆាំងសីហនុនៅកម្ពុជា ត្រូវបានបដិសេធពីមេដឹកនាំយួន ហើយមេដឹកនាំគណប្រតិភូយួន ឡេ-យង់ បានពន្យល់ទាំង សាឡុត-សរ ទាំងខ្មែរយៀកមិញនៅហាណូយថា ៖ «ឲ្យផ្អាកការតស៊ូបដិវត្តន៍សិន ហើយរង់ចាំដល់យៀកណាមទទួលបានជ័យជំនះនៅយួនខាងត្បូង, ពេលនោះជោគជ័យនៃបដិវត្តន៍នៅកម្ពុជានឹងកើតមានដោយស្វ័យប្រវត្តិ» (បញ្ជីខ្មៅរបស់ប៉ុល-ពត, ទំព័រទី៣៨) ។ ប៉ុន្តែក្រោយមក, គំរោងរបស់យួនត្រូវប្រែប្រួល ដោយសាររដ្ឋប្រហារនៅឆ្នាំ១៩៧០ ហើយមកទល់ពេលនេះ មតិខ្មែរខ្លះយល់ស្របតាមសេចក្តីអះអាងរបស់សីហនុថា ៖ «វិនាសកម្មនៅកម្ពុជា កើតមានត្រឹមតែដោយសាររដ្ឋប្រហារនៅឆ្នាំ១៩៧០» ។

នៅពីក្រោយឡប់ឡែនៃអព្យាក្រិតភាពរបស់គាត់, សីហនុបានបញ្ឆោត «កូនចៅជាទីស្នេហា»របស់គាត់ ដែលជនរួមជាតិស្លូតត្រង់ទាំងនេះប្រាថ្នាដោយស្មោះដើម្បីស្ថិតនៅជាអព្យាក្រិតពិតប្រាកដ ។ ចំណុចនេះជាបុព្វហេតុមួយ ក្នុងចំណោមបុព្វហេតុធ្ងន់ធ្ងរទាំងឡាយ ដែលបានបង្កជាការបែកបាក់ រវាងស្តេចសីហនុនិងប្រជារាស្ត្រខ្មែរ ។ វិលវល់ក្នុងនយោបាយ និងជោគជាំដោយអភិមានះរបស់គាត់, សីហនុពុំបានដឹងខ្លួនទេ ហើយជាបរាជ័យរបស់គាត់ ។ បរាជ័យដែលខ្លួនគាត់ផ្ទាល់ជាអ្នករៀបចំដោយមិនដឹងខ្លួនតាំងពីយូរឆ្នាំមក ។ សីហនុមិនបានដឹងសោះថា ហាណូយចង់បំបាត់រាជាធិបតេយ្យខ្មែរ តាំងពីថ្ងៃទី៩សីហា១៩៤៥ ដោយបញ្ជូឲ្យខ្មែរយៀកមិញ៧នាក់ទៅធ្វើពលប្រហារនៅក្នុងរាជវាំង ។ សីហនុបានចាត់ទុកថា ចិនជាមិត្តទីមួយ ដែលអាចបង្រ្កាបយួន, ពេលណាយួនឈ្លានពានខ្មែរ, ហើយចាត់ទុកយួនជាមិត្តទីពីរ ដែលអាចបង្រ្កាបខ្មែរកុម្មុយនិស្ត, ពេលណាខ្មែរកុម្មុយនិស្តចង់រំលំរាជាធិបតេយ្យ, ដោយសង្ឃឹមជានិច្ចថា យួនហាណូយជាចៅហ្វាយរបស់ខ្មែរកុម្មុយនិស្ត ហើយយួនត្រូវការរូបគាត់ជាងខ្មែរទាំងនោះ ។ (ផ្អែកតាមដានពត៌មាន តាមវិទ្យុសម្លេងនៅបរទេស អាស៊ី-ប៉ាស៊ីហ្វិក, ថ្ងៃទី១១មេសា១៩៦៨) ។ ដោយជឿជាក់យ៉ា

ងអស់ពីចិត្តថា កុម្មុយនិស្តនៅអាស៊ីនឹងបានជ័យជំនះនៅទីបំផុត, សីហនុបានចំពេញរាល់អ្វីៗដើម្បីទទួលបានការសណ្តោសប្រណី ពីមេកុម្មុយនិស្តទាំងនេះទៅអនាគត ។

ប៉ុន្តែ, មួយឆ្នាំមុនសន្និសិទកំពូលរបស់ប្រជាជននៅឥណ្ឌូចិន, សីហនុគេចមិនផុតពីការសារភាព អំពីវត្តមានរបស់យៀកកុងនិងយួនខាងជើងក្នុងកម្ពុជា ។ នៅថ្ងៃទី៦មិនា១៩៦៩, ក្នុងឱកាសសន្និសិទសារពត៌មានមួយ, សីហនុបានបើកកកាយ«គ្រោះធំក្នុងអនាគតខ្លី និងតាមកំណាត់» ដែលបណ្តាលមកពី«ការជ្រៀតចូលនៃពួកកុម្មុយនិស្តយួន» ។ នាសម័យសន្និសិទសារពត៌មាននេះ, សីហនុចង្អុលបង្ហាញតាមផែនទីរបស់សេនាធិការដ្ឋាន អំពីតំបន់ទាំងឡាយក្នុងប្រទេស «ដែលពួកយួនតាំងនៅច្រើន ថែមទាំងកាន់កាប់យ៉ាងមាំទាំតាមភូមិភាគខ្លះ» ។ សីហនុបញ្ជាក់ថា ៖ តាមតំបន់មួយចំនួន «ដំណើរឆ្លងកាត់ត្រូវបានហាមឃាត់ ហើយគេត្រូវផ្អាកដំណើរព្រោះពួកយៀកកុងនិងយៀកណាមខាងជើងនៅទីនោះច្រើន» ។

ពេញមួយឆ្នាំ១៩៦៩, ប្រតិបត្តិការទាំងឡាយត្រូវបានបំពេញដោយកងទ័ពខ្មែរប្រឆាំងពួកកុម្មុយនិស្តយួន, បញ្ជីរាយរាប់ពីការពើបប្រយុទ្ធគ្នា ត្រូវបានចេញផ្សាយទៀងទាត់ ជាមួយបញ្ជីរៀបរាប់ពីការខូចបង់ ។ ស្តីអំពីអ្នកទោសនៃរណសិរ្សរំដោះជាតិយៀកកុង ដែលត្រូវចាប់បានជាឈ្លើយ សីហនុបានប្រគល់ជូនស្ថានទូតនៃរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្នយៀកកុងនៅភ្នំពេញ ។ គឺអនុលេខាធិការនៃគណ:បេសកកម្មទូតនេះ, ង្វៀង-បាឌុង ឬសហសេវិករបស់គេ ង្វៀង-ហ្វាំងគិញ ដែលបានចុះហត្ថលេខាទទួលភារ:ជារៀងរាល់លើក បានសារភាពថា អ្នកទោស



ពួកយៀកកុង-យៀកណាមខាងជើងទាំងអស់នេះ បានត្រូវស្តេចសីហនុបញ្ជូនប្រគល់ទៅឲ្យស្ថានទូតយួនយៀកកុងវិញ (ថ្ងៃទី២៩ កក្កដា ១៩៦៩)

យៀកកុង មានសុខភាពល្អ ហើយបានសំដែងការដឹងគុណចំពោះសប្បុរសធម៌ និងក្ដីសណ្ដោសរបស់សីហនុ ។ នៅថ្ងៃទី៨កក្កដា១៩៦៩, អ្នកទោសយៀកកុង២០នាក់ត្រូវបានដោះលែង, នៅថ្ងៃទី២៩ យៀកកុង៥៣នាក់ទៀតដែលត្រូវបានចាប់ខ្លួន ពីខែវិច្ឆិកា១៩៦៨ ត្រូវបានដោះលែងទៀត, នៅថ្ងៃទី៣១តុលា១៩៦៩ យៀកកុង៩១នាក់ដែលមាន៣៨នាក់ជាភេទស្រីត្រូវបានប្រគល់ទៅរដ្ឋាភិបាលបដិវត្តន៍បណ្ដោះអាសន្នយៀកកុងវិញ, នៅថ្ងៃទី១៨វិច្ឆិកា មានការដោះលែងយៀកកុង២២នាក់, នៅថ្ងៃទី១២ធ្នូ ៖ ១១នាក់, នៅថ្ងៃទី២៦ធ្នូ ៖ ៨នាក់, ហើយទីបំផុត នៅថ្ងៃទី២៧មករា១៩៧០ យៀកកុង១៦នាក់ បានចាកចេញពីជំរំឃុំឃាំងរបស់ខ្មែរ ។



PROCES VERBAL DE REMISE DES CINQUANTE TROIS
DETENUS MEMBRES DU F.N.L. DU SUD VIETNAM

L'an Mil Neuf Cent Soixante Neuf, le Mardi Vingt Neuf Juillet, à 11 heures, a eu lieu au Ministère des Affaires Etrangères entre M. BORUR NOUTH KIM SAN, Sous-Directeur des Affaires Politiques du Ministère des Affaires Etrangères du Gouvernement Royal du Cambodge et M. NGUYEN BA DUNG, Représentant de l'Ambassade de la République du Sud-Vietnam, la remise des cinquante trois détenus membres du Front National de Libération dont les noms figurent dans la liste jointe en annexe, capturés à l'intérieur du territoire du Cambodge au cours de la période allant du 4 Novembre 1968 au 3 Juin 1969 par les éléments des Forces Nationales de Défense Cambodgienne.

M. NGUYEN BA DUNG, Représentant de l'Ambassade de la République du Sud-Vietnam, déclare par la présente prendre en charge ces cinquante trois détenus membres du FNL qui sont en bonne santé et décharge le Gouvernement Royal du Cambodge toutes responsabilités à partir de cette date.

Fait à Phnom-Penh, le 29 Juillet 1969.

NGUYEN BA DUNG

BORUR NOUTH KIM SAN

គំរូមួយនៃសេចក្ដីរាយការណ៍ ៖ ខាងឆ្វេងចុះហត្ថលេខាដោយ ង្វៀង-បាឌុង និងខាងស្ដាំដោយលោកឌឿ-នុតគីមសាន (សព្វថ្ងៃលោកកំពុងរស់នៅឯសហរដ្ឋអាមេរិក ។

មួយខែបន្ទាប់ពីសន្និសិទសារពត៌មាន, សីហនុឈប់លាក់លៀមស្ងៀតរបស់គាត់ ដោយសារភាពទាំងឥតខ្មាស់អៀន នៅថ្ងៃទី២២មេសា១៩៦៩ថា ៖ «ពួកកុម្មុយនិស្តត្រូវតែទទួលស្គាល់ នូវរាល់អ្វីៗដែលគាត់បានបំពេញ ដើម្បីជួយពួកគេនៅកម្ពុជា ។ ជំនួយដល់យៀកកុងនិងយួនខាងជើង បានទទួលពីកម្ពុជា ស្ថិតនៅលើវិស័យទូតនិងវិស័យសម្ភារ: ។ កម្ពុជាបានផ្ដល់ការជ្រោមជ្រែងគ្រប់បែបផ្សេងៗទៀត ក្នុងបំណងឲ្យយៀកកុងមានលទ្ធភាពសំរាប់តស៊ូ ជាមួយចក្រពត្តិនិយមអាមេរិកាំង ដើម្បីដណ្ដើមយកដែនដីនិងឯករាជ្យរបស់គេមកវិញ» ។

ចំណុចខកចិត្តធំមួយទៀតគឺ «មហាមិត្តចិន» តែម្ដង ដែលចង់រំលំរាជាធិបតេយ្យខ្មែរ ហើយធ្វើកម្ពុជាឲ្យទៅជារដ្ឋកុម្មុយនិស្ត ។ ចិនប្រជាមានិតមានបំណងធ្វើឲ្យបដិវត្តន៍វប្បធម៌របស់គេ ក្លាយទៅជាទំនិញមួយសំរាប់នាំចេញទៅក្រៅប្រទេស

ហើយជនណាក៏ដោយ ដែលមិនមែនជាអ្នកម៉ៅនិយម ត្រូវបានចាត់ទុកជាជនប្រតិកិរិយា ។ ដោយសង្ឃឹមទាំងឥតអំពើ ដើម្បីកែប្រែទស្សនវិស័យរបស់ប៉េកាំង ក្នុងនាមនៃមិត្តភាព, សីហនុបានបញ្ជូនរដ្ឋមន្ត្រីក្រសួងការបរទេសទៅប៉េកាំង, នរោត្តម ភូរិស្សរា, ដែលបានជួបសន្ទនាជាមួយជូ-អេនឡាយ នៅថ្ងៃទី១៧សីហា១៩៦៤ ។ យោងតាមសេចក្តីរាយការណ៍របស់នរោត្តន-ភូរិស្សរាចំពោះសីហនុ, នាយករដ្ឋមន្ត្រីចិនបានបញ្ជាក់ដោយត្រង់ៗថា ៖

«មហាបដិវត្តន៍វប្បធម៌ ប្រហែលមានជះឥទ្ធិពលទៅលើអាណិកជនចិននៅកម្ពុជា ។ ជ្រួតជ្រាបដោយសេចក្តីស្នេហាចំពោះមាតុភូមិរបស់ខ្លួន, អាណិកជនចិនទាំងឡាយ បានបំពេញសកម្មភាពដោយឯងៗ ។ ជាអំពើដែលគេអាចទទួលព្រមបាន ។ សម្តេចនរោត្តម-សីហនុទ្រង់យល់ច្បាស់ហើយ ។ ប៉ុន្តែរដ្ឋាភិបាលចិន មិនដែលបានជំរុញអាណិកជនទាំងនេះ ឲ្យធ្វើអន្តរាគមន៍ទៅលើកិច្ចការផ្ទៃក្នុងរបស់កម្ពុជាទេ ។ ប្រសិនបើអាណិកជនចិនបានរំលោភច្បាប់ជាធរមានរបស់កម្ពុជា ក្នុងនាមជាប្រទេសមានអធិបតេយ្យភាព មានសិទ្ធិ ដើម្បីដោះស្រាយបញ្ហានេះ ។ ពេលត្រឡប់វិញ យើងសង្ឃឹមថា សកម្មភាពធម្មតារបស់អាណិកជនចិននៅកម្ពុជា និងសិទ្ធិរបស់គេ ព្រមទាំងផលប្រយោជន៍ស្របច្បាប់ និងបានទទួលកិច្ចការពារពីរាជរដ្ឋាភិបាលខ្មែរ» ។

ដោយមានបញ្ហាឲ្យបោះពុម្ពផ្សាយសេចក្តីរាយការណ៍ខាងលើនេះ, សីហនុបានសរសេរបន្ថែមដោយផ្ទាល់ដៃថា ៖ «មានចិនខ្លះ, ហ៊ឹះ, បានជ្រៀតជ្រែកដោយច្បាស់ក្រឡែតពេក នៅក្នុងដង្ហើមនៃនយោបាយរបស់ខ្មែរ, ហើយនៅក្នុងទឹកដីរបស់ខ្មែរ បានដឹកនាំសកម្មភាពខាងមនោគមវិជ្ជា ដែលមិនសមស្របជាមួយសិទ្ធិនានាដែលជនបរទេសក្នុងប្រទេសមួយ ប្រកបដោយអធិបតេយ្យភាព ហើយដែលមិនមែនជាប្រទេសរបស់ខ្លួនអាចទទួលយក, មិនសមស្របជាពិសេស ជាមួយមិត្តភាពឥតល្អក់កករ ដែលចងភ្ជាប់ប៉េកាំងនិងភ្នំពេញ តាំងពីឆ្នាំ១៩៥៦» ។

ប៉ុន្តែ, ដោយមូលហេតុនៃភាពសោះអង្គើយក្នុងការសន្ទនា រវាងជូ-អេនឡាយ និងនរោត្តម-ភូរិស្សរា, ខាងភាគីកម្ពុជា, គេបានទាំងនិយាយរហូតដល់ ការហៅអគ្គរាជទូតខ្មែរ ទ្រឿង-កាង និងបុគ្គលិកប្រចាំស្ថានទូតទាំងអស់នៅប្រទេសចិនកុម្មុយនិស្ត ឲ្យត្រឡប់មកភ្នំពេញវិញ ។ ប៉ុន្តែ, ទំនាក់ទំនងពុំត្រូវបានកាត់ផ្តាច់ទេ ហើយតាមការទទូចសុំផ្ទាល់ខ្លួនពីជូ-អេនឡាយ សីហនុយល់ព្រមទុកអគ្គរាជទូតនិងអង្គភាពទូតនៅប៉េកាំងដដែល ។ ប៉ុន្តែនៅចំពោះមុខគ្រោះថ្នាក់រីកដាលនៃវិទ្ធង្សនារបៀបម៉ៅនិយមនេះ, នៅថ្ងៃទី១កញ្ញា១៩៦៧, សីហនុបានសំរេចចិត្តដើម្បីរំលាយរាល់សមាគមមិត្តភាពចិននៅក្នុងប្រទេស ។ សីហនុបានបង្ហាញចំពោះមុខអ្នកសារពត៌មានអំពីមូលហេតុនៃដំណោះស្រាយនេះ ៖ «សមាគមទាំងនេះ បានក្លាយជាអង្គការសំរាប់ឃោសនា និងអង្គការសំរាប់រំលាយរបបដឹកនាំ...។ គេហ៊ានរហូតដល់បង្រៀន

យុវជន កម្មកររបស់យើង ឲ្យច្រៀងសរសើរលើកកិត្តិស័ព្ទរបស់បុគ្គលនេះ បុគ្គលនោះនៅបរទេស...» ។

គឺសកម្មភាពរបស់ចិនកុម្មុយនិស្តនិងការតាំងទីរបស់យៀកកុងដ៏មានគ្រោះថ្នាក់ក្នុងកម្ពុជានេះហើយ ដែលជាកត្តាសំរាប់រុញច្រានកម្ពុជាឲ្យស្វែងរកសម្ព័ន្ធភាពផ្លូវទូតឡើងវិញ ជាមួយសហរដ្ឋអាមេរិក នៅខែមេសា១៩៦៩ បន្ទាប់ពីត្រូវបានផ្តាច់នៅខែឧសភា១៩៦៥, ហើយបន្ទាប់ពីការផ្តាច់ទូតជាមួយកូរ៉េខាងត្បូង, ចិនហ្វ័រម៉ូស, យួនខាងត្បូង និងសៀម ។ ប៉ុន្តែ, ហួសពេលហើយ, ការស្នើររកជំនួយផ្នែកយោធាពីសហរដ្ឋអាមេរិក ត្រូវបញ្ជោសគ្នាជាមួយកម្មវិធីរបស់ និច-សុន ដែលប្រាថ្នាដកកងទ័ពអាមេរិកាំងចេញពីយួនខាងត្បូង តាំងពីឆ្នាំ១៩៦៨, ហើយការដកកងទ័ពនេះជានិមិត្តរូបនៃការថយចុះនូវឥទ្ធិពលរបស់អង្គការ សន្ធិសញ្ញាអាស៊ីអាគ្នេយ៍, សេអាតូ, ដែលសំរាប់ប្រឆាំងជាមួយឥទ្ធិពលរបស់កុម្មុយនិស្តនៅក្នុងភូមិភាគ ។

❑

# ការប្រឈមមុខរបស់រដ្ឋាភិបាល លន់-នល់ ជាមួយយៀកកុង និងយួនខាងជើង

ចាប់ពីឆ្នាំ១៩៦៧, ផ្ទុយពីការយល់ឃើញរបស់រាស្ត្រខ្មែរស្លូតត្រង់, កិត្យានុភាពផ្ទាល់របស់សីហនុ បានត្រឹមតែចុះថយបន្តិចម្តងៗ, ប៉ុន្តែតាមពិត ដើម្បីឈានទៅដល់ក៏រិតទាបបំផុត នៅរដូវក្តៅនៃឆ្នាំ១៩៦៩, ដែលគេឈប់រុញរាក្នុងការទិតៀនគាត់សូម្បីក្នុងទីសាធារណៈ ស្តីពីវត្តមាននៃពួកកុម្មុយនិស្តយួននៅកម្ពុជា ។ សីហនុបានទទួលស្គាល់ ដល់ការជ្រៀតចូលនិងការតាំងជាមូលដ្ឋាន ដែលជាមណ្ឌលសំរាប់សំរាកកាយ, ជំរំហ្វឹកហ្វឺន, មន្ទីរពេទ្យ, ឃ្លាំងសំរាប់តម្កល់អាវុធ និងស្បៀងអាហារជាដើម ។ សីហនុបានទាំងបោះពុម្ពផ្សាយក្នុងទស្សនាវដ្តី «សង្គរាស្ត្រនិយ» នៅខែមិថុនា១៩៦៩ នូវសេចក្តីស្រង់ អំពីការសន្ទនា ដែលបានប្រព្រិត្តទៅនៅថ្ងៃទី២៨ឧសភាឆ្នាំដដែល ហើយដែលតាមការណែនាំរបស់គាត់ រវាងរដ្ឋទូតនៃយួនខាងជើង ង្វៀង-ធឿង និងរដ្ឋទូតនៃរណសិរ្សយៀកកុង ង្វៀង-វ៉ាន់ហៀវ ជាមួយឧត្តមសេនិយ លន់-នល់ ។

យោងតាមសេចក្តីរាយការណ៍នេះ, ឧត្តមសេនិយ លន់-នល់, កាលនោះជាអនុប្រធាននៃក្រុមប្រឹក្សារដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការពារជាតិបានរាយការណ៍ជូនរដ្ឋទូតរបស់យួនទាំងពីរថា ៖ «តាំងពីមួយរយៈកាលមកហើយ យើងសង្កេតឃើញថា វត្តមាននៃពលទាហានរបស់លោក បានក្លាយជាការកាន់កាប់ពិតប្រាកដ

តាមតំបន់ជាច្រើនក្នុងទឹកដីរបស់យើង » ។ តាមរដ្ឋាភិបាលខ្មែរ, «ភូមិភាគនៅខេត្តស្ទឹងត្រែងនិងរតនគីរី អាចត្រូវចាត់ទុកថាកាន់កាប់តាមផ្លូវយោធានិងរដ្ឋបាល ដោយពលទាហានរបស់លោក», ជាពាក្យបន្ថែមរបស់ឧត្តមសេនិយលន់-នល់ដែលបានបញ្ជាក់ថា នៅតំបន់មណ្ឌលគីរី «ការកាន់កាប់ដោយពលទាហានរបស់លោកលើដែនដីមានច្រើនចំណុច ដែលមានខ្លះជាមូលដ្ឋានសំរាប់គ្រឿងភស្តុភារនិងកងទ័ពពិតៗ, ជាមជ្ឈមណ្ឌលផ្នែកសុខាភិបាលពិតៗ ហើយជាបញ្ជាការដ្ឋានសំរាប់ប្រតិបត្តិការពិតៗក៏មានដែរ» ។ លោកឧត្តមសេនិយលន់-នល់បានគូសបញ្ជាក់បន្ថែមទៀត ក្នុងពាក្យថ្លែងទៅកាន់អ្នកការទូតយួនកុម្មុយនិស្តថា នៅក្នុងតំបន់ទាំងនេះ «ពលទាហានរបស់លោក ដោយតាំងខ្លួនជាម្ចាស់ពិតៗលើតំបន់កាន់កាប់ បានចេញប្រើច្បាប់ទាំងឡាយ ដោយតម្រូវឲ្យអាជ្ញាធរស្របច្បាប់របស់យើង ទាំងរាស្ត្រសាមញ្ញ ទាំងយោធា ស្នើរកការយល់ព្រម ឬការអនុញ្ញាតជាមុនពីពលទាហានរបស់លោក ដើម្បីអាចឆ្លងកាត់តាមតំបន់ទាំងនេះ» ។

កាលពីពីរឆ្នាំមុន, ក្នុងនាមនៃរដ្ឋាភិបាលហាណូយ, ផាម-វ៉ាន់ដុងបានប្រកាសនៅក្នុងសារលិខិតមួយ ចុះថ្ងៃទី៨មិថុនា១៩៦៧ ចំពោះសីហនុថា រដ្ឋាភិបាលហាណូយ «សូមបញ្ជាក់ជាឧឡារិកថា ហាណូយសុខចិត្តទទួលស្គាល់និងគោរពបូរណភាពទឹកដីខ្មែរនៅក្នុងព្រំដែនបច្ចុប្បន្ន» ។ ប្រាំបីថ្ងៃមុននេះ, ថ្ងៃទី៣១ឧសភា១៩៦៧, គណៈកម្មាធិការមជ្ឈឹមនៃរណសិរ្សរំដោះយៀកកុង បានទទួលស្គាល់«ព្រំដែនបច្ចុប្បន្ននៃយួនខាងត្បូងនិងកម្ពុជា», ហើយនៅថ្ងៃទី៦មិថុនា១៩៦៧, ប្រធាននៃរណសិរ្សរំដោះយៀកកុង ង្វៀង-ហ៊ឺ ថ បានអះអាងអំពីការគោរពដល់ព្រំដែនខ្មែរចំពោះសីហនុ តាមសារលិខិតមួយ ដែលនៅក្នុងនោះ ប្រធាននៃរណសិរ្សរំដោះយៀកកុង បានបួងសួងឲ្យ «សម្តេច» និងរាជរដ្ឋាភិបាលខ្មែរ «ជួបប្រទះមហាជោគជ័យក្នុងការរក្សានូវអធិបតេយ្យភាព, ឯករាជភាព, អាព្យាក្រឹតភាព និងបូរណាភាពដែនដីប្រឆាំងនឹងសកម្មភាពឈ្លានពានរបស់ចក្រពត្តិនិយមអាមេរិកាំងនិងបរិវារ» ។ ដូច្នេះពួកកុម្មុយនិស្តយួន មានវិធីយ៉ាងពិសេសដោយឡែក សំរាប់គោរពនូវបូរណភាពដែនដីនៃប្រទេសជាមិត្តមួយ ។

សេចក្តីរាយការណ៍បានបញ្ជាក់ថា ឧត្តមសេនិយលន់-នល់បានបន្តការបរិយាយទៅអ្នកការទូតយួនកុម្មុយនិស្ត ដោយបញ្ជាក់ភស្តុតាងអំពី «ការកាន់កាប់ពិតប្រាកដ» របស់ពលទាហានយៀកកុង នៅក្នុងខេត្តកំពង់ចាម, ព្រៃវែង, ស្វាយរៀង ព្រមទាំងការតាំងមូលដ្ឋានទាំងឡាយ ។ មន្ត្រីក្រសួងការពារជាតិរបស់សីហនុបានបញ្ជាក់ទៅគូសន្ទនាយៀកកុងថា ជាច្រើនគ្រា ពលទាហានយួនខាងជើងនិងយៀកកុងបានបាញ់ទៅលើកងទ័ពខ្មែរ ដែលបានទៅស្នើរពួកគេ ឲ្យដកថយពីដែនដីខ្មែរហើ

យឲ្យឈប់ជួយ«ខ្មែរក្រហម»នៅក្នុងជួរទ័ព ដែលមានយួនយៀកកុង ដូចជាក្នុងខេត្តពោធិសាត់, កំពង់ស្ពឺ, កំពត, កំពង់ចាម និងឆ្លូង ។

រដ្ឋទូតរបស់យួនហាណូយបានឆ្លើយថា គេសោកស្ដាយចំពោះរាល់ឧប្បត្តិហេតុទាំងនេះ ដោយបញ្ជាក់ថា «គេពុំបានដឹងសព្វគ្រប់អំពីឧប្បត្តិហេតុទាំងនេះទេ» ។ ចម្លើយរបស់អង្គទូតយៀកកុង មាននៅក្នុងបន្ទាត់ធំៗ ដូចគ្នានឹងចម្លើយរបស់ង្វៀងធឿងខាងលើ ។ ប៉ុន្តែបើគេអានក្នុងសេចក្ដីរាយការណ៍របស់ឧត្ដមសេនិយលន់-នល់, អង្គទូតយៀកកុង ង្វៀង-វ៉ាន់ហៀវ បានរំលឹកអំពីឧប្បត្តិហេតុនៅព្រៃតាមោក្នុងខេត្តស្វាយរៀង ដែលតាម ហៀវ «កងយោធពលខេមរភូមិន្ទបានបើកប្រតិបត្តិការប្រឆាំងលើមន្ទីរពេទ្យយៀកកុង», ដោយទទួលស្គាល់របៀបនេះ អំពីការតាំងទីដែលខ្មែរបានចោទប្រកាន់ ។ ឧត្ដមសេនិយលន់-នល់បានសងសំដីទៅវិញថា ៖ ក្នុងករណីនេះ «ពុំមែនជាបញ្ហាស្ដីពីមន្ទីរពេទ្យទេ ប៉ុន្តែអំពីពលទាហានរបស់លោកដ៏ច្រើនសន្ធឹកសន្ធាប់ ប្រដាប់ដោយអាវុធគ្រប់គ្រាន់ ដែលតាំងលេណដ្ឋានតាំងពីយូរឆ្នាំនៅក្នុងតំបន់នេះ ។ កងយោធពលខេមរភូមិន្ទដែលចេញប្រតិបត្តិការ ដែលគ្រាន់តែបំពេញភារកិច្ចរបស់ខ្លួន ដោយស្នើឲ្យពលទាហានរបស់លោកដកថយពីដែនដីខ្មែរ ត្រូវបានវាយប្រហារអស់រយៈពេលច្រើនថ្ងៃ ដោយពលទាហានរបស់លោក ។ កងយោធពលខេមរភូមិន្ទនិងប្រជារាស្ត្រខ្មែរបានទទួលការខូចខាតយ៉ាងច្រើន ទាំងជីវិតមនុស្សទាំងសម្ភារ:» ។ នៅទីបំផុត ឧត្ដមសេនិយលន់-នល់បានប្រកាសចំពោះមុខគូសន្ទនាយួនកុម្មុយនិស្តថា ៖ «ស្ថានភាពក្នុងបច្ចុប្បន្នស្ថិតនៅត្រង់ចំណុចដែលរាស្ត្រខ្មែរទាំងអស់គ្នាងឿងឆ្ងល់ថា តើអ្នកណាជាម្ចាស់លើប្រទេសខ្មែរ រវាងអស់លោកនិងយើង ?» ។

ស្ដេចសីហនុពុំបានធ្វើអ្វីទេ ក្រៅពីផ្ដល់ការផ្សព្វផ្សាយទូលំទូលាយអំពីសេចក្ដីរាយការណ៍នេះ ។ ការតាំងនៅរបស់យៀកកុងនិងយួនខាងជើងបានកើនឡើងនៅក្នុងឆ្នាំនោះ ។ ពីពាក់កណ្ដាលទី១ទៅទី២នៃខែកញ្ញា១៩៦៩, ចំនួនសរុបនៃកងកម្លាំងយួនកុម្មុយនិស្តបានកើនឡើង ពី៣២,០០០នាក់ទៅ៤០,០០០នាក់, យោងតាមរបាយការណ៍ ដែលផ្ញើរដោយឧត្ដមសេនិយលន់-នល់ ពេលនោះជានាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងការពារជាតិ ទៅជូនសីហនុ ហើយដែលត្រូវបានបោះពុម្ពផ្សាយតាមទស្សនាវដ្ដី<សង្គមរាស្ត្រនិយម> នៅខែតុលា១៩៦៩ ។

នៅសម័យនោះដដែល, ត្រូវនឹងថ្ងៃទី២៥កញ្ញា១៩៦៩, សីហនុបានសំរេចកិច្ចព្រមព្រៀងខាងពាណិជ្ជកម្មនិងការបង់ប្រាក់ ជាមួយរណសិរ្សរំដោះយៀកកុង និងជាមួយរដ្ឋាភិបាលហាណូយ ។ តាមពិត, ជាកិច្ចព្រមព្រៀងមួយមានលក្ខណ:ផ្នែកយោធា, ពីព្រោះសីហនុបានអនុញ្ញាតដល់ការរក្សាទុក ៖ មូលដ្ឋានទាំងឡាយក្នុងដែ

នដីខ្មែរ, ការដឹកជញ្ជូននូវគ្រឿងអាវុធនិងយុទ្ធោបករណ៍ រហូតដល់«ទីជំរក» ហើយគាត់បានគ្រោងទុក ការផ្គត់ផ្គង់ស្បៀង ជាពិសេសអង្ករ ទៅកងទ័ពព្រៃវៀតកុងនិងកងឯកភាពយួនខាងជើង ។ រហូតដល់ខែមិនា១៩៧០, ជិត៨០%នៃយុទ្ធោបករណ៍ដែលប្រើប្រាស់ដោយពួកយួនកុម្មុយនិស្ត ត្រូវបានបញ្ជូនពីកំពង់ផែកំពង់សោម ជាទីដែលសម្ភារៈទាំងនេះត្រូវបានបញ្ចេញបីនាវាផ្ទុកទំនិញរបស់សូវៀត, ចិន, ប៉ូឡូញ រហូតដល់«ទីជំរក» ដែលតាំងនៅតាមព្រំដែនខ្មែរ-យួនខាងត្បូង ។

នៅថ្ងៃទី៨មករា១៩៧០, សីហនុបានចាកចេញពីក្រុងភ្នំពេញ ដោយគ្មានគ្រោងទុកមុន, ក្នុងសេចក្តីប្រកាសថា ដើម្បីព្យាបាលរោគនៅប្រទេសបារាំង ។ បន្ទាប់ពីការចេញដំណើររបស់សីហនុ, ស្ថានការណ៍មានលក្ខណៈកាន់តែធ្ងន់ធ្ងរឡើងក្នុងកម្ពុជា ។ នៅថ្ងៃទី១៧កុម្ភៈ១៩៧០, ឯពោធិចិនតុង, មានការចាប់បានជាផ្ទាំពេទ្យទម្ងន់១៦តោន ដែលត្រូវសំដៅទៅស្ថានទូតនៃរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្នវៀតកុងនៅភ្នំពេញ ។ ស្អែកឡើង, ថ្ងៃទី១៨កុម្ភៈ១៩៧០, ឧត្តមសេនិយលន់-នល់ ដែលជាប្រធានរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីនៃ«រដ្ឋាភិបាលស្រោចស្រង់ជាតិ» បានត្រឡប់មកដល់ភ្នំពេញវិញ បន្ទាប់ពីបានទទួលព្យាបាលរោគនៅប្រទេសបារាំង ។ នៅថ្ងៃទី៨មិនា១៩៧០, មានបាតុកម្មជាច្រើនរបស់សិស្ស ដែលប្រឆាំងជាមួយវៀតកុងនៅខេត្តស្វាយរៀង ។ បីថ្ងៃបន្ទាប់មក, ទី១១មិនា១៩៧០, នៅភ្នំពេញ, ស្ថានទូតយួនខាងជើងនិងស្ថានទូតវៀតកុង ត្រូវបានវាយកំទេចដោយប្រជារាស្ត្រខ្មែរ ដែលក្តៅក្រហាយដោយការកាន់កាប់របស់វៀតកុងនិងយួនខាងជើងលើទឹកដីខ្មែរ ។

នៅថ្ងៃទី១២មិនា១៩៧០, រដ្ឋាភិបាលលន់-នល់ បានស្នើឲ្យយួនហាណូយនិងវៀតកុងដកកងទ័ពរបស់ខ្លួនចេញពីទឹកដីខ្មែរជាកំហិត នៅថ្ងៃទី១៥មិនា១៩៧០ ។ ប៉ុន្តែ, សីហនុបានផ្ញើសារទូរលេខពីក្រុងប៉ារីសទៅក្សត្រីយានីកុសុមៈ ជាម្តាយ ដោយស្តីបន្ទោសដល់បាតុកម្មទាំងឡាយ ហើយផ្តន្ទាទោសដល់រដ្ឋាភិបាលនិងសភាជាតិ ពីហេតុគាំទ្រដល់បាតុកម្ម ដែលប្រឆាំងយួនកុម្មុយនិស្តនេះ ។ នៅថ្ងៃទី១៣មិនា១៩៧០ រដ្ឋាភិបាលលន់-នល់បានសំរេចបញ្ជូនបេសកជនពីររូបមកក្រុងប៉ារីស, អង្គម្ចាស់នរោត្តម-កន្តុល និងយែម-សំបូរ, ដើម្បីបំភ្លឺសីហនុ អំពីព្រឹត្តិការណ៍នៅកម្ពុជា ។ ប៉ុន្តែ, សីហនុបានឲ្យដឹងថា គាត់មិនទទួលជួបបុគ្គលទាំងពីរនេះទេ ។

នៅថ្ងៃទី១៦មិនា១៩៧០, ដោយពុំបានចម្លើយពីពួកយួនកុម្មុយនិស្ត សំរាប់ថ្ងៃទី១៥មិនា, រដ្ឋាភិបាលលន់-នល់បានចាប់ផ្តើមចរចាជាមួយតំណាងរបស់ទូតយួនហាណូយនិងវៀតកុង ។ គណប្រតិភូខ្មែរត្រូវបានដឹកនាំដោយនាយកខាងកិច្ចការផ្នែកនយោបាយនៃក្រសួងការបរទេស គី-សុទ្ធ ដែលចូលរួមដោយវរសេនិយត្រី គឹម អេង-គួរុនដេត, អនុសេនិយឯក នាង-សុន និងមន្ត្រីផ្នែកការទូត ម៉ែន-ស៊ុំផាវ ។

រដ្ឋាភិបាលបដិវត្តន៍បណ្ដោះអាសន្នយៀកកុងត្រូវបានតំណាងដោយ យ៉-អាញ់ទន់, ជាភារធារី និងអនុលេខាធិការពីររូបនៃស្ថានទូត ង្វៀង-បាឌុង និងង្វៀង-ហ៊្វាងគិញ ។ គណប្រតិភូយួនខាងជើងត្រូវបានតំណាងដោយភារធារី ត្រាន់-វ៉ាន់ទឹក ដែលត្រូវអមដោយអគ្គលេខាធិការនៃស្ថានទូត ង្វៀង-ដាងខា, អនុលេខាធិការពីររូប ផាម-ម៉ាញ់យៀម និងង្វៀង-វ៉ាន់ក្វាង ។

លោកគី-សុទ្ធបានបញ្ជាក់ថា កម្មវត្ថុនៃកិច្ចប្រជុំនេះ ៖ «ជាច់ខាតស្ដីអំពីការជម្លៀសចេញនៃពលទាហានយៀកកុងនិងយួនខាងជើងពីដែនដីខ្មែរ ដែលស្នើឡើងដោយរដ្ឋាភិបាល» ។ បន្ទាប់មក, វរសេនិយត្រី គួរុនដេត បានរំលឹកឡើងវិញថា ៖ «តែពីត្រឹមខែតុលា១៩៦៩ មកទល់ថ្ងៃទី១៥មិនា១៩៧០, ឧប្បត្តិហេតុ២៧៧ករណីបានត្រូវបង្កឡើងដោយពលទាហានយៀកកុងនិងយួនខាងជើង, ដែល២២០ករ-ណីក្នុងខេត្តរតនគីរី បានបណ្ដាលឲ្យខ្មែរស្លាប់១៥នាក់ និងរបួស១៣៧នាក់ ។ ក្នុងពេលថ្មីៗនេះទៀត, អាជ្ញាធរតាមព្រំដែនបានឲ្យដំណឹងពីការតាំងទីនៃពលទាហានយៀកកុងនិងយួនខាងជើងយ៉ាងសន្ធឹកសន្ធាប់ ព្រមតាំងឃ្លាំងតម្កល់នូវគ្រឿងអា-វុធ, ស្បៀងអាហារ និងគ្រាប់រំសេវ» ។

«បន្ទាប់ពីសំណើររកការដកថយនៃពលទាហានទាំងនេះ ដែលស្នើរឡើងដោយរដ្ឋាភិបាល, អាជ្ញាធរតាមព្រំដែនរបស់យើងបានឲ្យសញ្ញាថា នៅព្រឹកព្រលឹមថ្ងៃទី១៥មិនា១៩៧០, ពុំមានវិធានការណ៍ណាមួយបានត្រូវចាត់ចែង ចំពោះបញ្ហានេះដោយភាគីយួនទាំងពីរទេ, ហើយថាពលទាហានយួនខាងជើងនិងយៀកកុង នៅបន្តកាន់កាប់លើទីតាំងនោះដដែល» ។

«ដូច្នេះ, យើងប្រាថ្នាចង់ដឹងអំពីគោលជំហររបស់អស់លោកក្នុងបញ្ហានេះ ។ ហេតុអ្វីបានជាអស់លោកមិនបានធ្វើសោះ តាមកាលបរិច្ឆេទដែលត្រូវបានកំណត់ ហើយពេលណាទៅ ទើបអស់លោកលៃលកជម្លៀសពលទាហានចេញពីទឹកដីរបស់យើង?» ។

ចម្លើយរបស់យួនខាងជើង គ្មានជាប់ទាក់ទងបន្តិចណាសោះជាមួយកម្មវត្ថុនៃអង្គប្រជុំ ៖ ការដកទ័ពថយនៃពួកកុម្មុយនិស្តយួនចេញពីទឹកដីខ្មែរ ។ តាមធម្មតាភាពរបស់យួន ជាសាសន៍ឈ្លានពានទាប់ថោកមិនចេះអៀនខ្មាស់, អ្នកការទូតយួនខាងជើង ត្រាន់-វ៉ាន់ទឹក ត្រឡប់ជាផ្ដន្ទាទោស «នយោបាយឈ្លានពានរបស់ចក្រពត្តិនិយមអាមេរិកាំង», ហើយអះអាងតាមសំនៀងដ៏ឧឡារិកបំផុតក្នុងពិភពលោកនេះថា ៖ «ចំពោះកម្ពុជា, រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម បានបន្តជាប្រចាំនូវនយោបាយមិត្តភាព និងភាពជាអ្នកជិតខាងដ៏ត្រឹមត្រូវ ដោយផ្អែកទៅលើគោលការណ៍ទាំងប្រាំនៃការរួមរស់ដោយសន្តិភាព តាមកិច្ចព្រមព្រៀងនៅហ្សឺ

ណែវក្នុងឆ្នាំ១៩៥៤ស្តីពីឥណ្ឌូចិន ក្នុងកិច្ចគោរពទៅវិញទៅមកដល់ផលប្រយោជន៍នៃភាគីទាំងពីរ ហើយដោយគ្មានការជ្រៀតជ្រែកលើកិច្ចការផ្ទៃក្នុងរបស់ភាគីមួយទៀត ។ រដ្ឋាភិបាលវៀតណាមខាងជើងបានគោរពជានិច្ច នូវឯករាជភាព, អធិបតេយ្យភាព, អព្យាក្រិតភាព និងបូរណភាពដែនដីនៃរាជាណាចក្រកម្ពុជា នៅក្នុងព្រំដែនបច្ចុប្បន្ន ។

បន្ទាប់មក, ត្រាន់-វ៉ាន់ទឹកបានថ្លែងគោរពដល់«នយោបាយរបស់សីហនុដើម្បីឯករាជ្យ, សន្តិភាព និងព្យាក្រិតភាពខ្មែរ ដើម្បីរក្សានិងពង្រឹងចំណងមិត្តភាព និងភាពជាអ្នកជិតខាងល្អប្រសើរ ជាមួយសាធារណរដ្ឋប្រជាធិបតេយ្យយួន» ។ រួចហើយ, ត្រាន់-វ៉ាន់ទឹករំលឹកអំពីការវាយកំទេចស្ពានទូតយួនខាងជើង នៅថ្ងៃទី១១មិនា ថា «ជាការរំលោភលើច្បាប់អន្តរជាតិ ចំពោះអភ័យឯកសិទ្ធិរបស់តំណាងទូត», ហើយនិយាយថា «ឧប្បត្តិហេតុថ្មីៗនេះមានភាពធ្ងន់ធ្ងរបំផុតនិងផ្ទុយពីមិត្តភាព ដែលមេដឹកនាំនៃប្រទេសទាំងពីរបានប្រកាន់យកឥតឈប់ឈរ សំរាប់ផលប្រយោជន៍របស់ប្រជាជាតិផងខ្លួន» ។ ភារធារីយួនខាងជើងបានស្នើរជាបញ្ហាសឲ្យទទួលថា « រាល់បញ្ហាដែលបានកើតឡើង ក្នុងទំនាក់ទំនងរវាងប្រទេសទាំងពីរ នឹងត្រូវដោះស្រាយតាមការចរចា» ។ ស្តីពី «ឧប្បត្តិហេតុនៅថ្ងៃទី១១មិនា», ត្រាន់-វ៉ាន់ទឹកប្រាថ្នាចង់ដឹងអំពី«វិធានការណ៍ជាក់ស្តែងទាំងឡាយ» ដែលខ្មែរត្រូវចាត់ចែង ដើម្បីចៀសវាងបាតុកម្មថ្មីទៀត ដើម្បីផ្តន្ទាទោសពួកបាតុករ និងដើម្បី«សងជម្ងឺចិត្តនៃភាគីយួនដែលរងការខូចខាត» ។

បន្ទាប់មក, តំណាងខាងរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្នយៀកកុង យ៉-អាញ់ទន់ បានឡើងថ្លែង ដោយផ្ញូនពាក្យសំដីរបស់គណប្រតិភូហាណូយ ៖ ចំពោះអ្នកការទូតយៀកកុងនេះ ពុំមានការរៀបរាប់ណាមួយអំពីវត្តមាននៃពលទាហានរបស់ខ្លួនក្នុងទឹកដីខ្មែរទេ ។

យ៉-អាញ់ទន់ ប្រកាសថា ៖ «តាមធម្មតា, នយោបាយរបស់យើងចំពោះរាជាណាចក្រខ្មែរ មានលក្ខណៈច្បាស់លាស់ ហើយត្រូវបានបញ្ជាក់ជាឧឡារិកជាច្រើនលើក នៅក្នុងឯកសារជាគ្រឹះទាំងឡាយរបស់រណសិរ្សរំដោះជាតិ និងរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្នវៀតណាម ។ កន្លងមក, ក៏ដូចបច្ចុប្បន្ននិងទៅអនាគត, យើងគោរពអធិបតេយ្យភាព, ឯករាជភាព, ឯកភាព និងបូរណភាពដែនដីខ្មែរក្នុងព្រំដែនបច្ចុប្បន្ន ។ យើងចៀសវាងដាច់ខាត នូវការជ្រៀតជ្រែកលើកិច្ចការផ្ទៃក្នុងរបស់កម្ពុជា ហើយគោរពរបបនយោបាយរបស់កម្ពុជា ។ ខ្ញុំទទួលភារកិច្ចពីរដ្ឋាភិបាលមកដើម្បីបញ្ជាក់ជាថ្មីទៀតថា នយោបាយនេះគ្មានការកែប្រែ» ។

ដោយដើរតាមឧទាហរណ៍នៃសហសេវិកយួនខាងជើង, ភារធារីយៀកកុងបាន

រំលឹកពីការវាយកំទេចស្ថានទូតរបស់ខ្លួន នៅថ្ងៃទី១១មិនា, ហើយស្នើឲ្យ«រដ្ឋាភិបា-លលន់-នល់សងជម្ងឺចិត្ត ដល់ការខូចខាតក្នុងស្ថានទូត និងដល់អាណិកជនយួន» ម៉្យាងទៀត, យ៉-អាញ់ទន់មានបំណងឲ្យ «កិច្ចព្រមព្រៀងផ្នែកពាណិជ្ជកម្ម គឺកិច្ចព្រមព្រៀងទីមួយជាផ្លូវការ ដែលត្រូវបានសំរេចឡើងជាឧឡារិក រវាងរដ្ឋាភិបាលយៀកកុងនិងប្រមុខរដ្ឋខ្មែរ ស្ថិតនៅក្នុងការអនុវត្តន៍ជាបន្ត សំរាប់ផលប្រយោជន៍ប្រ-សើរបំផុតទៅវិញទៅមក» ។ កិច្ចព្រមព្រៀងនេះ ដែលត្រូវបានសំរេចយកនៅថ្ងៃទី២៥កញ្ញា១៩៦៩, ត្រូវបានរំលាយដោយរដ្ឋាភិបាលលន់-នល់ នៅខែមិនា១៩៧០ បន្តិចមុនការចរចានេះ ។

ប្រមុខនៃគណៈប្រតិភូខ្មែរបានទាមទារជាថ្មីទៀត «ដើម្បីដឹងពីវិធានការណ៍ដែ-លអស់លោកបានប្រកាន់យកនិងអនុវត្ត សំរាប់ជន្លៀសពលទាហានរបស់អស់លោក បន្ទាប់ពីសេចក្ដីតម្រូវជាផ្លូវការរបស់រដ្ឋាភិបាលខ្មែរ» ។

យ៉-អាញ់ទន់ ឆ្លើយតបថា ៖ «បន្ទាប់ពីឧប្បត្តិហេតុនៅថ្ងៃទី១១មិនា យើងអត់មានលទ្ធភាពដើម្បីធ្វើការបាន ។ ឧទាហរណ៍, ប្រព័ន្ធទូរស័ព្ទរបស់យើងត្រូវបានបំផ្លាញខ្ទេច ហើយយើងមិនអាចទាក់ទងជាមួយរដ្ឋាភិបាលបានទៀត» ។ យ៉-អាញ់ទន់ ប្រកាសថា ត្រៀមខ្លួនដើម្បីពិភាក្សាលើបញ្ហាដែលកើតមាន, ប៉ុន្តែដោយគ្មានទំនាក់ទំនង គេមានការលំបាកដើម្បីទទួលចម្លើយពីរដ្ឋាភិបាល ។

បន្ទាប់ពីការសំរាកអស់រយៈ៣០នាទី កិច្ចចរចាត្រូវចាប់បន្តឡើងវិញ ហើយលោកគី-សុទ្ធ, ប្រមុខនៃគណៈប្រតិភូខ្មែរបានត្រឡប់មករក «ភាពចាំបាច់ដែលយួនកុម្មុយនិស្តត្រូវអនុវត្ត តាមសំណើរពីរដ្ឋាភិបាលខ្មែរ ស្ដីពីការដកថយនៃពលទាហានយួនហាណូយនិងយៀកកុងពីដែនដីខ្មែរ» ។ ដោយហេតុថា ភាគីយួនទាំងពីរនៅតែរំលឹកឥតឈប់ឈរអំពីការធានា ក្នុងកិច្ចគោរពដល់អធិបតេយ្យភាពនិងបូរណ-ភាពដែនដីខ្មែរ ក្នុងក៏រិតព្រំដែននាបច្ចុប្បន្ន, អ្នកការទូតខ្មែរបានបន្ថែមថា «រដ្ឋាភិបាលខ្មែរប្រាថ្នាឲ្យ ការធានាអះអាងនេះលេចចេញជាសកម្មភាពជាក់ស្ដែង» ។

ពេលនោះ, គណៈប្រតិភូយួនកុម្មុយនិស្តទាំងពីរក្រុមស្នើឡើងថា ៖ «រាល់បញ្ហាដែលចោទឡើង នឹងត្រូវយកទៅដោះស្រាយតាមកិច្ចចរចា», វារកាលថ្ងៃទី១៦មិនាគ្រាន់តែជា«ជំហានទីមួយ», ហើយស្នើឲ្យមានវារកាលផ្សេងទៀត ។ ចំពោះគណៈប្រតិភូយួនហាណូយ, ការកំណត់កាលបរិច្ឆេទ ត្រូវឲ្យ«យូរបន្តិច» ដោយមូលហេតុនៃការលំបាកក្នុងទំនាក់ទំនង ឬក៏«កំណត់កាលបរិច្ឆេទនេះតាមផ្លូវទូត» ។ ចំណែកអ្នកតំណាងយៀកកុង ប្រាថ្នាយកកាលបរិច្ឆេទខ្លីជាង, ដើមសប្ដាហ៍បន្ទាប់, មានន័យថា ចាប់ពីថ្ងៃច័ន្ទទី២២មិនា១៩៧០ ។

ប៉ុន្តែ, ស្ដេចសីហនុត្រូវបានទម្លាក់ពីតំណែងជាប្រមុខរដ្ឋ ដោយសម្លេងឆ្នោត

ជាឯកច្ឆន្ទរបស់សភាជាតិ នៅថ្ងៃទី១៨មិនា១៩៧០, ហើយប្រធានសភា, ចេង-ហេង, ដែលបានកាន់តំណែងជាប្រមុខរដ្ឋស្ដីទីក្នុងអវត្តមានរបស់សីហនុ បានក្លាយជាប្រមុខរដ្ឋខ្មែរ ស្របតាមរដ្ឋធម្មនុញ្ញនៃរាជាណាចក្រ ។ នៅថ្ងៃទី២៥មិនា១៩៧០, ក្រសួងការបរទេសខ្មែរបានស្នើតាមសារលិខិតមួយ ទៅស្ថានទូតយួនខាងជើង « ដើម្បីបើកកិច្ចប្រជុំថ្មី នៅថ្ងៃសុក្រទី២៧មិនា១៩៧០ វេលាម៉ោង៩កន្លះ នៅទីស្នាក់ការនៃក្រសួងការបរទេស» ។ នៅថ្ងៃដដែល, រដ្ឋទូតនៃសាធារណរដ្ឋប្រជាមានិតប៉ូឡូញ បានបញ្ជូនមកមន្ត្រីនៃក្រសួងការបរទេសខ្មែរ នូវកំណត់ហេតុមួយ ដែលមិនត្រឹមតែប្រកាស អំពីការបដិសេធរបស់គណៈប្រតិភូយួនកុម្មុយនិស្ត នូវការបន្តកិច្ចចរចាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអំពីការចេញដំណើរទៅហាណូយវិញ នៅថ្ងៃទី២៧មិនា «របស់បុគ្គលិកប្រចាំស្ថានទូតនៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម និងស្ថានទូតនៃរដ្ឋាភិបាលបដិវត្តន៍បណ្ដោះអាសន្នយៀកកុង» ។ ទាំងនេះ ជាការដកថយពីដែនដីខ្មែរតែមួយគត់របស់ពួកយួនកុម្មុយនិស្តឈ្លានពាន ដែលរដ្ឋាភិបាលលន់-នល់ទើបនឹងបានដឹងឮ ។ រដ្ឋទូប៉ូឡូញ «ក្នុងក្របខ័ណ្ឌនៃការជួយជ្រោមជ្រែង» ត្រូវបានប្រគល់បន្ទុកសំរាប់បេសកកម្ម ដើម្បីជន្លៀសចេញនេះ ។

ពីរថ្ងៃបន្ទាប់មក, ទី២៩មិនា១៩៧០, ក្រោយពីបដិសេធចរចា, ហើយដោយ«គ្មានប្រកាសសង្គ្រាម», កងទ័ពយៀកកុងនិងយួនខាងជើង ដែលតាំងទីនៅក្នុងទឹកដីខ្មែរស្រាប់ បានបើកការវាយប្រហារយ៉ាងខ្លាំងក្លាទៅលើកងទ័ពខ្មែរ នៅតាមទីតាំងការពារខ្លួនក្នុងខេត្តជាច្រើន ហើយចាប់ធ្វើការវាយជំរុកសំដៅក្រុងភ្នំពេញ ។

ជីវិតនៃប្រជារាស្ត្រខ្មែរស្លូតត្រង់ ចាប់ផ្ដើមធ្លាក់ជាបន្តបន្ទាប់ ទៅក្នុងរណ្ដៅនៃភ្លើងសង្គ្រាម ដែលឆាបឆេះសន្ធោរសន្ធៅ ដោយសារនយោបាយឈ្លានពានរបស់ប្រទេសជាមហាមិត្តនៃរាជាណាចក្រកម្ពុជា ។

❑ ❑

❑

# អត្ថន័យនៃសង្គ្រាមនៅកម្ពុជាក្នុងឆ្នាំ១៩៧០

សង្គ្រាមបង្ហូរឈាម ដែលផ្ទុះឡើងរវាង«សាធារណរដ្ឋខ្មែរ» ដឹកនាំដោយឧត្តមសេនិយលន់-នល់ ជាមួយ«រណសិរ្សរួបរួមជាតិកម្ពុជា» ដឹកនាំដោយស្តេចនរោត្តម-សីហនុ មានអត្ថន័យច្រើនយ៉ាងដូចតទៅ ៖

១- ចំពោះសហរដ្ឋអាមេរិក ៖ ជាសង្គ្រាមសំរាប់ពង្រឹកដែនប្រតិបត្តិការរបស់កងទ័ពអាមេរិកាំង ដើម្បីដេញកំចាត់យៀកកុង ឬដើម្បីធ្វើឲ្យកម្លាំងយៀកកុងចុះទន់ខ្សោយ ក្នុងបំណងយកប្រៀបលើហាណូយ ដែលចូលចរចារកសន្តិភាព ឬក្នុងបំណងសំរួលដល់ការដកកងទ័ពអាមេរិកាំងពីយួនខាងត្បូង នៅក្នុងស្ថានភាពប្រកបដោយសន្តិសុខ ទៅតាមផែនការពិតៗរបស់និចសុន និងហង់រី-គីហ្ស៊ីងហ្គ័រ ដែលគ្មានសង្ឃឹម ដើម្បីយកឈ្នះសង្គ្រាមនេះ ដោយសារសភានិងប្រជារាស្ត្រអាមេរិកាំងធ្មើយណាយ ហើយប្រឆាំងជាមួយការបន្តសង្គ្រាម ។

២- ចំពោះសហភាពសូវៀត ៖ សង្គ្រាមនេះហុចឱកាសឲ្យសហភាពសូវៀតមានលទ្ធភាពកាន់តែច្រើន សំរាប់បណ្តេញវត្តមានរបស់លោកសេរីពីឥណ្ឌូចិន និងសំរាប់ពង្រីកឥទ្ធិពលរបស់ខ្លួននៅក្នុងកម្ពុជា តាមរយៈក្រុងហាណូយ ដើម្បីបង្កើតសហព័ន្ធឥណ្ឌូចិនមួយ សំរាប់បញ្ចូលទៅក្នុង«សហភាពសាធារណរដ្ឋសង្គមនិយមសូវៀតពិភពលោក», តាមកម្មវិធីរបស់«អង្គការកុម្មុយនិស្តអន្តរជាតិ», ដែលហូ-ជីមិញបានព្រមព្រៀងជាមួយសូវៀត តាំងពីជំនាន់ឆ្នាំ២០ ដើម្បីទទួលការគាំទ្រពីសូវៀត សំរាប់ប្រឆាំងជាមួយអាណានិគមបារាំង ហើយតាមកម្មវិធីដែលសូវៀតបានចាប់ផ្តើមធ្វើបន្តពីថ្ងៃទី៦មករា១៩៦១ ជាមួយយួនខាងជើង ដោយផ្តល់ជំនួយសំរាប់ធ្វើសង្គ្រាមប្រឆាំងសហរដ្ឋអាមេរិក ។

៣- ចំពោះចិនកុម្មុយនិស្ត ៖ ជាសង្គ្រាមសំរាប់កំចាត់ចក្រពត្តិនិយមអាមេរិកាំងពីឥណ្ឌូចិន ដើម្បីរក្សាការគង់វង់ជីវិតនៃរបបកុម្មុយនិស្តចិន និងដើម្បីឲ្យកម្ពុជាបានក្លាយជារដ្ឋកុម្មុយនិស្តមួយ នៅក្រោមរណបខ្លួន សំរាប់ត្រួតត្រាឥទ្ធិពលរបស់យួនដែលអាចត្រូវជំរុញជាយថាហេតុពីសហភាពសូវៀតនៅអនាគត ព្រមទាំងដើម្បីពង្រីកឥទ្ធិពលចិននៅអាស៊ីភាគអាគ្នេយ៍ ជាបឋមនៅប្រទេសសៀម រួចហើយភូមា, ម៉ាឡេស៊ី, ឥណ្ឌូណេស៊ី និងហ្វីល្លីពីន ។

៤- ចំពោះយួនកុម្មុយនិស្ត ៖ សង្គ្រាមនេះផ្តល់លទ្ធភាពឲ្យយួនខាងជើងនិងយៀកកុង មានវង់ប្រតិបត្តិការកាន់តែស្រួលទូលំទូលាយ ។ ខ្ញុំបាទដែលពីឆ្នាំ១៩-៧០ដល់១៩៧១ ធ្លាប់ជាប់ជាមួយគ្រួសារ ក្នុងតំបន់ដែលយៀកកុងកាន់កាប់ បាន

ឃើញព្រឹត្តិការណ៍នេះផ្ទាល់ភ្នែក ។ ខ្ញុំបានឃើញការសំរុកចូលដោយសេរីមកក្នុងខេត្តស្វាយរៀង នៃរាស្ត្រសាមញ្ញយួន និងកងទ័ពយៀកកុង-យួនខាងជើង, ដែលតាមមធ្យោបាយគ្រប់ជាក់បំផុត បានមកលួកគ្រប់ផ្លាំងបាយខ្មែរ បានមកដេកគ្រប់ផ្ទះខ្មែរ, បានមកសម្លាប់ខ្មែរសាធារណរដ្ឋយ៉ាងពេញដៃ, បានមកបង្ហាត់បង្រៀនខ្មែរក្រហម ឲ្យចេះសម្លាប់ខ្មែរគ្នាឯងយ៉ាងស្ទាត់ជំនាញ ហើយបានមកបន្ត «ដំណើរឆ្ពោះទៅទិសខាងលិច»ជាថ្មី តាមសន្ធិសញ្ញាជាផ្លូវការ រវាងសីហនុនិងផាម-វ៉ាន់ដុង នៅប៉េកាំងក្នុងខែមិនា១៩៧០ ។

៥- ចំពោះស្តេចនរោត្តម-សីហនុ ៖ ជាសង្គ្រាមសំរាប់បណ្តេញចក្រពត្តិនិយមអាមេរិកាំងនិងបរិវារពីកម្ពុជា ហើយក្នុងថ្ងៃទី១៥មេសា១៩៧០ នៅប៉េកាំង, បានថ្លែងនៅចំពោះអ្នកសារពត៌មានបរទេសមួយចំនួនថា ៖ «ក្នុងការតស៊ូដែលខ្ញុំករុណាបានប្តេជ្ញាដឹកនាំរហូតដល់ទីបញ្ចប់ ឬយ៉ាងហោចណាស់ រហូតដល់ខ្ញុំករុណាអស់ជន្មាយុជាយថាហេតុ នៅក្នុងព្រៃម៉ាគីស៍ ដែលខ្ញុំនឹងចូលរួមក្នុងរយៈពេលខ្លី និងបន្តជាមួយនេះ **នូវគោលបំណងផ្ទាល់ខ្លួនមួយ ៖ ខ្ញុំចង់និយាយថា ខ្ញុំចង់សងសឹក** ។ អំណើះតទៅ, ខ្ញុំករុណាចូលរួមតាមលក្ខណៈឥតប្រែប្រួល ក្នុងការប្រយុទ្ធ ។ ខ្ញុំផ្តល់អត្ថន័យដ៏ខ្ពង់ខ្ពស់ ចំពោះការប្រយុទ្ធនេះ ។ ខ្ញុំករុណាចង់ដឹកនាំការប្រយុទ្ធជាមួយក្រុមអ្នកស្មោះត្រង់របស់ខ្ញុំ និងជាមួយយុវជនជឿនលឿននិយមរបស់យើង ដើម្បីជំរុញយុវជនទាំងនេះ ទៅកាន់អំណាច ហើយថែមទាំងដើម្បីអនុញ្ញាតឲ្យពួកគេ សំរេចបានជារូបរាងឡើង នូវក្តីស្រមៃរបស់ពួកគេ ទៅរកយុត្តិធម៌ក្នុងសង្គម**និងរកលទ្ធិសង្គមនិយម**» ។

៦- ចំពោះឧត្តមសេនិយលន់-នល់ ៖ ជាសង្គ្រាមសំរាប់កំចាត់ពួកអ្នកឈ្លានពានកុម្មុយនិស្តយួន ពីសាធារណរដ្ឋខ្មែរ ។ ជាភ្លើងសង្គ្រាមដែលយៀកកុងនិងយួនខាងជើង បានចូលមកបង្កាត់ក្នុងទឹកដីខ្មែរ តាំងពីឆ្នាំ១៩៦៣ ដោយមាននរោត្តម-សីហនុ ជាអ្នកជួយរកអុស ហើយចិនកុម្មុយនិស្តនិងកូរ៉េខាងជើង ជាអ្នកជួយខាងបក់ផ្លិត ខាងផ្លុំភ្លើង រហូតទាល់តែបានឆេះសន្ធោរសន្ធៅឡើងនៅឆ្នាំ១៩៧០ ។

៧- ចំពោះសាឡូត-សរ ៖ សង្គ្រាមនេះ ប្រដូចបានទឹកបឹងទន្លេសាប ហើសាឡូត-សរជាក្រពើក្រៀមស្បែកមួយ ដែលត្រូវចិនប៉េកាំង, យួនហាណូយ និងស្តេចសីហនុ នាំគ្នាចាប់គ្រវែងទៅក្នុងបឹងនោះ ។

នៅឆ្នាំ១៩៧០, ភាគីទាំង៧សុទ្ធតែជាអ្នកសង្ឃឹមឈ្នះ ទៅតាមគំរោងការណ៍រៀងៗខ្លួន, ប៉ុន្តែចាប់ពីឆ្នាំ១៩៩០ ដែលសហភាពសូវៀតត្រូវរលំ មកទល់ឆ្នាំ១៩៩៧នេះ អ្នកឈ្នះពិតប្រាកដ នៅសល់តែមួយទេ គឺពួកយួនកុម្មុយនិស្ត ។

# ឱកាសល្អសំរាប់ឲ្យយួនកុម្មុយនិស្ត ចូលឈ្លានពានកម្ពុជាដោយចេញមុខ

នៅថ្ងៃទី១៨មិនា១៩៧០, ដែលជាថ្ងៃរដ្ឋប្រហារ, ស្ដេចសីហនុនិងបរិពារត្រូវរៀបចំដើម្បីចេញដំណើរ ពីមូស្គូទៅប៉េកាំង ។ គឺនៅថ្ងៃទី១៨មិនា, ក្នុងរថយន្តដែលដឹកសីហនុ ទៅកាន់អាកាសយានដ្ឋាននេះហើយ ដែល អាឡិចស៊ីស៍-កូស៊ីហ្គីនបានប្រាប់ទៅសីហនុថា «នៅភ្នំពេញ, តាមកិច្ចប្រជុំវិសាមញ្ញមួយ រដ្ឋសភាបានប្រកាសជាឯកច្ឆន្ទ ដើម្បីទម្លាក់រូបគាត់ពីតំណែងជាប្រមុខរដ្ឋខ្មែរអស់មួយជីវិត» ។

យោងតាមសីហនុ, កូស៊ីហ្គីនបានបន្ថែមថា ៖ «សម្ដេចនឹងបាបដឹងអំពីអ្វីដែលពួកចិននឹងនិយាយជាមួយសម្ដេច, រួចហើយចាំសម្ដេចត្រឡប់មកវិញ ។ យើងនឹងជួយសម្ដេច ។ សម្ដេចប្រាកដជាឈ្នះមិនខាន» ។

តាមគំនិតរបស់គាត់, សីហនុបានប្រាថ្នាស្នាក់នៅ ទាំងមូស្គូ ទាំប៉េកាំង ដើម្បីដឹកនាំតាមរយៈរដ្ឋធានីនៃប្រទេសកុម្មុយនិស្តទាំងពីរ នូវ«ចលនាតស៊ូ»ប្រឆាំងរដ្ឋាភិបាលនៅភ្នំពេញ ដែលរូបគាត់ផ្ទាល់ ជាអ្នកតែងតាំងនៅខែសីហា១៩៦៩ ។

ពេលទៅដល់ប៉េកាំង នៅថ្ងៃទី១៩មិនា១៩៧០, សីហនុគ្រាន់តែជាអង្គម្ចាស់ធ្លាក់បុណ្យម្នាក់ប៉ុណ្ណោះ, វង្វេងដោយក្រេវក្រោធ, ត្រៀមខ្លួនជាស្រេចដើម្បីដេកដួលទៅក្នុងដៃរបស់អ្នកដែលត្រកងយករូបគាត់មុនគេ ដើម្បីសងសឹក ។ គឺជាការបង្កើបឲ្យដឹងនៅពេលក្រោយពីសំណាក់«មិត្ត»ជូ-អេនឡាយរបស់គាត់ ដែលបានទទួលរូបគាត់ នៅពេលចុះពីយន្តហោះ ហើយដែលបានសួរទៅរូបគាត់ ក្រែងលោគាត់បំរុង «បន្តតស៊ូរហូតដល់ទីបញ្ចប់» ។ តាមចម្លើយជាវិជ្ជមានរបស់គាត់, នាយករដ្ឋមន្ត្រីចិនបន្ថែមថា ៖ «ប្រធានម៉ៅ-សេទុងបានផ្ដល់ការណែនាំមកខ្ញុំ ដើម្បីធានាជូនសម្ដេចថា យើងនឹងគាំទ្រសម្ដេចយ៉ាងពេញទំហឹង» ។

ជាបន្ទាន់នោះ, ជូ-អេនឡាយបាមសំដែងឲ្យអតីតមហាក្សត្រយល់អំពី ដែលកុម្មុយនិស្តលឿងបានប្រាថ្នាលើរូបគាត់ ៖ ដោយធ្វើឲ្យមានជំនឿ តាមការអបអរសាទរ និងតាមសកម្មភាពផ្ទាល់របស់គាត់, ថាប្រជារាស្ត្រខ្មែរក្រោកប្រឆាំង ជាមួយរដ្ឋាភិបាលនៅភ្នំពេញ ដើម្បីផ្ដល់កិច្ចការពារទៅពលទាហានយួនកុម្មុយនិស្ត ក្នុងសង្គ្រាមយូរអង្វែងរបស់គេ ។

នៅថ្ងៃទី២២មិនា១៩៧០, ក្នុងដំណើរមកពីហាណូយ, ផាម-វ៉ាន់ដុងបានមកដល់ទីក្រុងប៉េកាំង ជាទីដែលផាម-វ៉ាដុងបានសន្ទនាយ៉ាងយូរជាមួយសីហនុ ។

ហើយយោងតាមដេវីឌ ភី. ឆេនឡឺរ៍, តាំងពីដើមឆ្នាំ១៩៧០ សាឡុត-សរបានចេញដំណើរពីកម្ពុជាមកហាណូយ, ទំនងជាសាឡុត-សរបានរួមដំណើរជាមួយ ផាម-វ៉ាន់ដុង ដែលត្រូវបានកោះហៅដោយក្រុងប៉េកាំង, ទើបសាឡុត-សរបានទៅដល់ទីនោះដែរ ។

តាមបញ្ជីខ្មៅ, ម្តងនេះ, សាឡុត-សរមានជោគជ័យក្នុងការបញ្ចុះបញ្ចូលជូ-អេនឡាយ ដែលសីហនុត្រូវជ្រើសយកជាជំហរប្រឆាំងចំពោះលន់-នល់, ហើយដោយហេតុនេះចំពោះសហរដ្ឋអាមេរិកដែរ, ដោយត្រឡប់មករកនយោបាយប្រឆាំងចក្រពត្តិនិយមអាមេរិកាំងវិញ ដែលរូបគាត់បានបោះបង់ចោល កាលពីមួយឆ្នាំមុនដើម្បីដាក់ចំណងទូតជាថ្មីជាមួយអាមេរិក កាលពីខែមេសាឆ្នាំ១៩៦៩ ។

តាមប្រភពផ្សេងទៀត គឺផាម-វ៉ាន់ដុង ដែលបានលើកទឹកចិត្តសីហនុឲ្យតស៊ូដោយសន្យាយកអំណាចឲ្យគាត់វិញ «ក្នុងចន្លោះពេល៤៨ម៉ោង» ។ សំណើដែលសាឡុត-សរបានធ្វើចំពោះជូ-អេនឡាយដូច្នេះដូចគ្នាបេះបិត ជាមួយដំបូន្មានដែលផាម-វ៉ាន់ដុងបានផ្តល់ទៅសីហនុ ។ ដើម្បីកុំឲ្យសីហនុអាក់អន់ចិត្ត និងដើម្បីការពារអនាគតនៃកុម្មុយនិស្តខ្មែរ, មេដឹកនាំចិននិងយួនបានលាក់វត្តមានរបស់សាឡុត-សរនៅប៉េកាំងនេះ មិនឲ្យលេចឮដល់សីហនុ ដែលគាត់បានដឹងថា សាឡុត-សរជាមេដឹកនាំការប្រយុទ្ធនៅកម្ពុជា តែនៅរយៈពេលច្រើនឆ្នាំក្រោយមក (ដេវីដ ភី.ឆេនឡឺរ៍ «រៀមច្បងប៉ុលពត», ទំព័រ១៨៥) ។

បន្ទាប់ពីការសន្ទនាជាមួយផាម-វ៉ាន់ដុង, សីហនុ«បានសំដែងចេតនាក្នុងការបង្កើតរណសិរ្សរួបរួមរំដោះកម្ពុជា» ។ សីហនុបានប្រកាន់យកកលយុទ្ធដ៏សាមញ្ញបំផុតរបស់បក្សកុម្មុយនិស្តអន្តរជាតិ ៖ កលយុទ្ធនៃ«រណសិរ្ស» ។ ការដណ្តើមយកអំណាចរបស់ពួកកុម្មុយនិស្តប្រព្រឹត្តទៅ, បើដោយផ្ទាល់, តាមអំពើព្រៃផ្សៃ, ឬបើដោយប្រើពេលវេលាយូរអង្វែង, តាមអំពើវិទ្ធង្សនា ដែលត្រូវបានបង្កនិងដឹកនាំដោយអង្គការទាំងឡាយ ដែលប្រមូលផ្តុំគ្នានៅក្រោមការគាំពាររបស់«រណសិរ្ស»មួយ ដើម្បីបិទបាំងសកម្មភាពពិតប្រាកដរបស់បក្សកុម្មុយនិស្ត ដែលបានជ្រៀតចូលទៅក្នុងស្នូលនៃ«រណសិរ្ស» ប៉ុន្តែជាអ្នកកាន់កាប់មុខនាទីក្នុងបញ្ជាការ ។

លុះស្អែកឡើង, ថ្ងៃទី២៣មិនា១៩៧០, សីហនុបានថ្លែងតាមរលកធាតុអាកាសនៃវិទ្យុសម្លេងប៉េកាំង អំពីសេចក្តីប្រកាស៥ចំណុច ដែលនៅក្នុងនោះគាត់បានបញ្ជាក់ពីការរំលាយរដ្ឋាភិបាលភ្នំពេញ, ការអំពាវនាវដល់ជនរួមជាតិ ជាទីស្នេហាទាំងអស់នៅកម្ពុជា ក៏ដូចនៅបរទេស ឲ្យបដិសេធការគោរពចំពោះរដ្ឋាភិបាលនេះ, បានប្រកាសពីការបង្កើតលើកក្រោយ នូវ«រដ្ឋាភិបាលរួបរួមជាតិថ្មីមួយ ព្រមទាំងសភាសំរាប់ពិគ្រោះយោបល់បណ្តោះអាសន្ន», បានគ្រោងបង្កើត «កងទ័ពរំដោះជាតិ»,

ហើយទីបញ្ចប់បានស្នើទៅខ្មែរទាំងអស់ «ដែលរស់នៅក្នុងប្រទេសនិងក្រៅប្រទេ-ស, ព្រះសង្ឃ, គ្រហស្ថ, ទាហាន និងរាស្ត្រសាមញ្ញ, បុរសនិងស្ត្រី» ឲ្យរួបរួមគ្នាដើម្បី«បង្កើតរណសិរ្សរួបរួមមួយ តាមឈ្មោះជាផ្លូវការថា រណសិរ្សរួបរួមជាតិកម្ពុជា »។

ចំណែកខាងយួនយៀកកុងនិងយួនខាងជើង, ឱកាសល្អបានមកដល់ហើយ។ ដោយគ្មានប្រកាសសង្គ្រាម, កងទ័ពយួនកុម្មុយនិស្តបានចាប់ផ្ដើមការវាយប្រហារទៅលើទីតាំងនៃរដ្ឋាភិបាលខ្មែរ តាមតំបន់ជាច្រើន នៅថ្ងៃទី២៩មិនា១៩៧០ ។ កាលបរិច្ឆេទនេះកំណត់នូវការចាប់ផ្ដើមនៃសង្គ្រាមខ្មែរ, ជាដំបូងបំផុតគឺ «បន្ទាយសង្កាត់សឹករងកំពង់ត្រាច», ឈ្មោះថា«បន្ទាយរាចអ៊ាម» នៅស្រុករមាសហែកក្នុងខេត្តស្វាយរៀង, បានទទួលការវាយប្រហារពីយៀកកុង-យួនខាងជើង និងខ្មែរក្រហមមួយក្ដាប់តូច ដែលធ្លាប់បានធ្វើសកម្មភាពនៅក្នុងស្រុកនេះតាំងពីឆ្នាំ១៩៦៨ ។ លុះព្រឹកឡើង, ខ្ញុំបានបានទៅជិតបន្ទាយ ។ ជាលើកទីមួយដែលខ្ញុំបានឃើញ ពួកយៀកកុងពាក់ រូបស្ដេចសីហនុ នៅលើអាវ, ពួកគេប្រកាសថា មកជួយស្ដេចសីហនុ ហើយខ្ញុំបានឮគេនិយាយពាក្យថា <u>អង្គការ</u> ។ បន្ទាប់មក, ខ្ញុំបានឃើញថា អាណិកជនយួនជាច្រើន ដែលរស់នៅផ្សារកំពង់ត្រាច ដែលមានប្រាក់ចាយវាយដូចក្រដាស់ និងជិះទោចក្រយន្តយន្តចុះឡើង តាំងពីច្រើនឆ្នាំមកហើយ សុទ្ធជាភ្នាក់ងាររបស់យៀកកុងទាំងអស់ ។ ចំណែកទាហានក្នុងបន្ទាយ មិនបានតតាំងជាមួយយួនយៀកកុងទេ ព្រោះបានដឹងជាមុនថា មិនអាចយកឈ្នះលើយៀកកុងបាន ។ ជនរងគ្រោះដល់ស្លាប់តែម្នាក់គត់នៅក្នុងបន្ទាយនេះ គឺអនុសេនីយឯក សុខ-ជោត ដែលបន្ទាប់មកត្រូវបានដឹកចេញពី«បន្ទាយរាចអ៊ាម» ដោយកងអន្តរាគមន៍មកពីទីរួមខេត្តស្វាយរៀង នៅម៉ោង១៨រសៀល ។

សេចក្ដីអំពាវនាវរបស់ស្ដេចសីហនុ តាមវិទ្យុប៉េកាំង, កាលណោះបើតាមខ្ញុំគិតប្រហែលពុំសូវមានប្រសិទ្ធិភាពចំពោះខ្មែរអ្នកក្រុងទេ, ប៉ុន្តែបើតាមខ្ញុំឃើញផ្ទាល់មានឥទ្ធិពលចំពោះខ្មែរនៅតាមជនបទ ។ កំហឹងរបស់រាស្ត្រខ្មែរ ចំពោះការទម្លាក់ស្ដេចសីហនុពីតំណែង បានជំរុញនិងយុវជនអ្នកស្ម័គ្រចិត្តជាច្រើន ឲ្យចូលក្នុងព្រៃម៉ាគីស៍ ដើម្បីទទួលការហ្វឹកហ្វឺនពីពួកយៀកកុង ។ ប៉ុន្តែ, ខ្មែរមួយភាគបានត្រឡប់មករកគ្រួសារវិញ ដោយមិនអាចទ្រាំទ្របាន ជាមួយការវាយប្រហារពីកងទ័ពអាកាសអាមេរិកាំង នៅតាមព្រំដែនទៅលើជំរុំហ្វឹកហ្វឺន ។

នៅថ្ងៃទី១៤មេសា១៩៧០, ឧត្ដមសេនិយលន់-នល់បានប្រកាសថា ៖ «ខ្មែរព្រមទទួលរាល់ជំនួយពីបរទេសដោយឥតលក្ខខណ្ឌ ពីគ្រប់មជ្ឈដ្ឋាន, ដើម្បីមានលទ្ធភាពសំរាប់តស៊ូប្រឆាំងសត្រូវឈ្លានពាន» ។ ក្នុងរយៈពេលជាងមួយខែ កងទ័ពនិង

ប្រជាពលរដ្ឋខ្មែរត្រូវប្រឈមមុខតែឯកឯង ជាមួយកងឯកភាពយួនខាងជើងនិងយៀកកុង ដែលមានអាវុធទំនើបជាង និងការហាត់ហ្វឹកហ្វឺនស្ទាត់ជំនាញជាង ដើម្បីរារាំងការឈ្លានពានមកលើដែនដីខ្មែរ ។ នៅថ្ងៃទី២៣មិនា១៩៧០, ក្រោមបញ្ជាការរបស់ឧត្តមសេនីយ សុស្តែន-ហ្វេរណង់ដេស៍, កងទ័ពខ្មែរបានដណ្តើមយកបានទីក្រុងស្នួងមកវិញ ដែលស្ថិតនៅចម្ងាយ៣៣គ.ម.ពីទីក្រុងភ្នំពេញ ហើយបញ្ឈប់ការវាយលុករបស់បច្ចាមិត្រសំដៅរដ្ឋធានី ។

យោងតាម នីកូឡា-ឡាង, ជាអ្នកសង្កេតការណ៍ដ៏អង់អាចនិងសុចរិត, «មានព្រឹត្តិការណ៍គួររំភើបហើយឆោតល្ងង់ នៅក្នុងគណៈកម្មាធិការសំរាប់ទប់ទល់ជាមួយសត្រូវ, ដែលត្រូវបានបង្កើតឡើងតាមគ្រឹះស្ថានសិក្សា, តាមក្រសួងរដ្ឋ, តាមសង្កាត់ជាដើម, ដោយការប្រមូលផ្តុំនូវយុវជននិងយុវនារី ដែលមានឯកសណ្ឋានចំរុះពណ៌គ្នា ហើយដែលឈរកាន់អាវុធ ដើម្បីយាមនៅខាងក្រោយគំនរបាវខ្សាច់ ។ មានកង្វះការពិសោធន៍ នៅក្នុងសំណាក់នៃយុទ្ធជនចំណូលថ្មីទាំងនេះ ដែលហាត់ហ្វឹកហ្វឺនក្រោយម៉ោងធ្វើការនៅការិយាល័យ តាមសួនច្បារនិងទីលានសាធារណៈនៃក្រុងភ្នំពេញ ។ ប៉ុន្តែគេអាចគិតថា ទាហានជំនាន់ព្រេងនាយ ក៏មានលក្ខណៈឆោតល្ងង់, រទ្បិករទ្បក់, ខ្វះការពិសោធន)ដែរ, ហើយដូចទាហានទាំងនេះ, យុវជននិងយុវនារីខ្មែរបានចូលប្រឡូកដោយទឹកចិត្តរំភើបអង់អាចពិតៗ ក្នុងការប្រយុទ្ធប្រឆាំងសត្រូវ ដែលបណ្តាលឲ្យបាត់បង់ជីវិតរាប់រយរាប់ពាន់នាក់» ។

ពីថ្ងៃទី២៤ទៅ២៥មេសា១៩៧០, ដោយយកតាមគំនិតចាស់ពីឆ្នាំ១៩៦៥ និងដោយមានការជ្រោមជ្រែងពីប៉េកាំង, សីហនុបានស្នើបើក«សន្និសិទកំពូលរបស់ប្រជាជនឥណ្ឌូចិន» ហើយកិច្ចប្រជុំបានត្រូវកោះហៅតាមការផ្តួចផ្តើមរបស់សីហនុ ។ យោងតាមឯកសារនេះ, ប្រជាជនទាំងបីនៃឥណ្ឌូចិនត្រូវបានតំណាងដោយគណៈប្រតិភូបួន ៖ ខាងភាគីខ្មែរ ត្រូវបានដឹកនាំដោយសីហនុ ហើយចូលរួមដោយប៉ែន-នុត, ហួត-សម្បត្តិ, សារិន-ឆាក, ចៅ-សេង, ជួន-មុំ និង រឿង-ម៉ាច ។ ចំណែកខៀវ-សំផន, ហ៊ូ-យន់ និងហ៊ូ-នឹម ពុំបានចូលរួមទេ ។ ខាង«ប្រជាជនឡាវ»មានអង្គម្ចាស់ សុផានុវង្ស ជាប្រធាននៃគណៈកម្មាធិការមជ្ឈឹមរបស់រណសិរ្សស្នេហាជាតិលាវ, ព្រមទាំង ខាមសឹត-កែវឡា, ភូមិ-វង្សវិចិត្រ, ខាមផាយ-បុប្ផ និង អ៊ុំហឿន-ភួនសាវ៉ាត ។ ខាងរណសិរ្សយៀកកុងមាន ង្វៀង-ហ៊ឺ ថ ជាប្រធាន, ព្រមទាំងធិញ-ឌិញថាវ, លោកស្រីង្វៀង-ឌិញជី, ឡេ-ក្វាងចាញ់, ង្វៀង-វ៉ាន់ហៀវ និង យ៉ា-ដុងយ៉ាង ។ ខាងភាគីយួនខាងជើង មាននាយករដ្ឋមន្ត្រី ផាម-វ៉ាន់ដុង ជាប្រមុខព្រមទាំង ហ្វាង-កុកវៀត, ហ្វាង-មិញជាន, ង្វៀង-កូថាច់ និងង្វៀង-ធឿង ។

ក្រោយមក, អង្គម្ចាស់ សុផានុវង្ស បានអះអាងដោយផ្ទាល់ខ្លួនអំពីកិច្ចប្រជុំនេះ

នៅក្នុងបទសម្ភាសន៍មួយ ជាមួយអ្នកសារពត៌មានជាតិប៉ូឡូញឈ្មោះ ម៉ូនីកា-វ៉រណៅនស្កា ដែលគាត់បានយកមកចុះផ្សាយក្នុងពត៌មាន ទ្រីប៊ូណាលូឌូ នៅថ្ងៃទី២៣មិថុនា១៩៧០ ។ អង្គម្ចាស់ សុផានុវង្ស បានទទួលស្គាល់ថា កិច្ចប្រជុំនៃគណ:ប្រតិភូទាំងបួននេះ ពិតជាបានប្រព្រឹត្តទៅនៅក្រុងកង់តុង ដោយមានវត្តមានពីនាយករដ្ឋមន្ត្រីចិនជូ-អេនឡាយ ព្រមទាំងភរិយាផង ។ ក្នុងពិធីជប់លៀងបិទអង្គប្រជុំនៅថ្ងៃទី២៥មេសា១៩៧០, ជូ-អេនឡាយបានប្រកាសប្រាប់គណ:ប្រតិភូទាំងបួនថា ប្រទេសរបស់ពួកគេមានព្រំដែនជាប់ផ្ទាល់ជាមួយចិន, ទុកណាកម្ពុជាពុំមានព្រំដែនត្រង់ណាជាប់ជាមួយចិនក៏ដោយ ហើយថា«ដែនដីចិនដ៏ទូលំទូលាយ ជាបង្អែករឹងប៉ឹងសំរាប់ប្រទេសឥណ្ឌូចិនទាំងបី» ។

នៅក្នុងសង្កថាសំរាប់សម្ពោធពិធី, សីហនុបានសង្កត់ធ្ងន់ទៅលើការគាំទ្រពីចិនប្រជាមានិត ហើយចាត់ទុកថា «ជ័យជំនះរបស់ប្រជាជនឥណ្ឌូចិន ដែលបានគាំទ្រយ៉ាងខ្លាំងក្លាពីមហាប្រជាជនចិន និងពីប្រទេសដទៃទៀតក្នុងពិភពលោក» ជាជោគជ័យដែលទទួលបានរួចស្រេច ។

សេចក្តីជូនពត៌មានចុងក្រោយបញ្ជាក់ថា ៖ «ការតស៊ូរបស់ប្រជាជនទាំងបី ជាការតស៊ូរួម ហើយប្រជាជននិមួយៗត្រូវជួយគ្នាទៅវិញទៅមក គឺអ្វីដែលបានបើកចំហទ្វារ សំរាប់ឲ្យយៀកកុងនិងយួនខាងជើង ចូលឈ្លានពានកម្ពុជា លាវ ដោយសេរី» ។ ឯកសារអះអាងថា ៖ «ដោយប្រកាន់គំនិតតាមគោលការណ៍ថា ការរំដោះនិងការពារប្រទេសនិមួយៗ ជាភារកិច្ចរបស់ប្រជាជនខ្លួន, ភាគីនានាត្រូវធ្វើតាមរាល់លទ្ធភាពរបស់ខ្លួន ដើម្បីផ្តល់ការគាំទ្រទៅវិញទៅមក ទៅតាមចំណង់របស់ភាគីជាសាមីខ្លួន ហើយដោយផ្អែកលើការគោរពគ្នាទៅវិញទៅមក» ។

ដោយបញ្ជាក់ពីសាមគ្គីភាពរបស់គណ:ប្រតិភូទាំងបី, គណ:ប្រតិភូហាណូយបានកំណត់យកលក្ខណ:ផ្សេងគ្នាសំខាន់មួយ ។ សេចក្តីជូនពត៌មានបានបញ្ជាក់ជាចុងក្រោយថា ដោយការយល់ព្រមនិងដោយការគាំទ្រដល់គោលដៅរបស់ភាគីលាវ, ខ្មែរ និងយួនខាងត្បូង, «បញ្ហាស្តីពីឯករាជភាព, សន្តិភាព, អព្យាក្រឹតភាព, ការហាមឃាត់នូវរាល់វត្តមាននៃពលទាហានឬមូលដ្ឋានយោធាបរទេស នៅលើដែនដី, ការមិនចូលរួមក្នុងសម្ព័ន្ធភាពយោធាណាមួយ», គឺគោលការណ៍ដែលត្រូវចុះលក្ខខណ្ឌក្នុងកិច្ចព្រមព្រៀងនៅក្រុងហ្សឺណែវកាលពីឆ្នាំ១៩៥៤ ស្តីពីឥណ្ឌូចិន និងក្នុងកិច្ចព្រមព្រៀងនៅឆ្នាំ១៩៦២ ស្តីពីលាវ, គណៈប្រតិភូហាណូយមិនបានចុះហត្ថលេខា ជាការយល់ព្រមក្នុងកិច្ចប្រជុំទេ ។ ដោយចូលរួមក្នុងពិភពកុម្មុយនិស្ត, គណៈប្រតិភូហាណូយមិនអាចត្រូវចាត់ទុកថា អព្យាក្រឹតទេ គឺដំណោះស្រាយពីបទបញ្ជាក្នុងអង្គប្រជុំ ដែលហាណូយបានបដិសេធជាច្រើនលើក ក្នុងរយ:ប៉ុន្មានឆ្នាំចុងក្រោយ

នេះ ។ រយៈពេលជាងមួយឆ្នាំបន្ទាប់មក ពួកមេដឹកនាំនៃសន្និសិទកំពូលឥណ្ឌូចិន មិនបានរួមប្រជុំទៀតទេ, សន្និសិទនៅកង់តុងនេះ ដែលត្រូវបានផ្តួចផ្តើមដោយសីហនុ ហើយត្រូវបានបញ្ជាដោយជូ-អេនឡាយ, ទំនងមានឥទ្ធិពលយូរអង្វែង ។

តាមរយៈវិទ្យុសម្លេងប៉េកាំង, សីហនុអំពាវនាវឥតឈប់ឈរចំពោះប្រជាជាតិខ្មែរ, ប៉ុន្តែការអានអត្ថបទទាំងនេះ អាចឲ្យកត់សំគាល់ឃើញ អំពីវិធីនិងសំនៀងដែលប្រែប្រួលខុសទម្លាប់ប្រក្រតីពីគ្រាមុនរបស់សីហនុ ។ ប៉េកាំងពុំមែនមិនដឹងថាការអំពាវនាវរបស់គាត់ គ្មានឥទ្ធិពលខ្លាំងទៅលើប្រជារាស្ត្រខ្មែរទេ, ប៉ុន្តែគេនៅបន្តលើកទឹកចិត្តរបស់សីហនុ ឲ្យប្រកាសជាទៀងទាត់ ព្រោះទាំងនេះរួមចំណែកយ៉ាងសំខាន់ ក្នុងល្បែងនយោបាយចិន ។ មុខងាររបស់សីហនុនៅប៉េកាំង មានលក្ខណៈផ្សេងគ្នាពីបំណងរបស់គាត់ ។ ទុកជាមានពាក្យទ្រគោះយ៉ាងសាហាវ ដែលគាត់បានប្រកាសតាមវិទ្យុសម្លេងភ្នំពេញនៅឆ្នាំ១៩៦៧ ដើម្បីប្រឆាំងជាមួយអ្នកដឹកនាំនៃបដិវត្តន៍វប្បធម៌ចិន, មានន័យថាម៉ៅ-សេទុង។ លិន-ពាវ ជាដើម, ដល់ឥឡូវ, សីហនុបានមកស្ថិតលើអាសនៈជាផ្លូវការនៃទីលាន ទៀន-អានមិន, ក្បែរគ្នាជាមួយមេដឹកនាំនៃបដិវត្តន៍នេះដដែល ។

ពួកមេដឹកនាំចិនប្រាកដជាមិនទាន់ភ្លេច នូវភាសាផ្ទុយគ្នា រវាងស្តេចសីហនុនិងពួកគេទេ, ប៉ុន្តែសុទ្ធតែបានយល់ដោយគ្រប់គ្រាន់ ដើម្បីមិនទាញយកឱកាសដែលហុចឲ្យពួកគេ នៅថ្ងៃទី១៩មិនា១៩៧០ ក្នុងពេលសីហនុជាប្រមុខរដ្ឋ ដែលធ្លាក់ពីតំណែង បានមកដល់ទីក្រុងប៉េកាំង ។ ចំពោះប៉េកាំង ជាសារៈសំខាន់មួយដែលសេចក្តីប្រកាសទាំងឡាយ ស្តីពីនយោបាយចិនកុម្មុយនិស្ត ត្រូវធ្វើឡើងដោយជនបរទេសម្នាក់, ដោយជនជាតិអាស៊ីម្នាក់ ។

សីហនុ, ដែលត្រូវបានជូនដំណើរនៅពេលនោះ ក្នុងទស្សនកិច្ចជាបន្តបន្ទាប់ពាសពេញប្រទេសចិន, បានទៅទស្សនារហូតដល់កូរ៉េខាងជើង ព្រមទាំងហាណូយផង ។ នៅខែមិនា១៩៧០, សីហនុបានប្រកាសអំពីចំណង់ ដើម្បីធ្វើដំណើរទៅមជ្ឈិមបូព៌ា ហើយទៅយូហ្គោស្លាវីនៅនិទាឃរដូវបន្ទាប់, ប៉ុន្តែដំណើរទាំងនេះ មិនត្រូវបានអនុញ្ញាតពីប៉េកាំងទេ ។ ដោយគាប់ចិត្តឬមិនគាប់ចិត្ត, សីហនុត្រូវរស់នៅជិតបុគ្គលដែលគាត់ហៅថា «មិត្តដ៏ថ្លៃថ្លាបំផុត» ៖ ជូ-អេនឡាយ ។ ទោះជាដោយសារចំណងមិត្តភាពនេះ ដែលមកទល់ថ្ងៃនោះមានចំណាស់២៥ឆ្នាំ ក៏សីហនុប្រាកដជាគ្មានឥទ្ធិពលអ្វីទៅលើនយោបាយនៃប្រទេសចិនទេ ។ សីហនុថ្លែងដោយភាពប្រាកដក្នុងចិត្ត នូវអ្វីដែលគេខ្សឹបដាក់គាត់ ។ សីហនុមិនភ័ន្តច្រឡំទៀតទេ គាត់បានក្លាយជាអ្នកនាំពាក្យរបស់ប៉េកាំង ហើយគាត់ដឹងថាមុខនាទីរបស់គាត់នឹងត្រូវចប់កាលណាចិនកុម្មុយនិស្តចង់សំរេច ។

ខ្ញុំបាទលើកយកឯកសារចាស់មកលាតត្រដាងឡើងវិញនេះ មិនមែនក្នុងផលប្រ-យោជន៍ ដើម្បីទម្លាក់ទោស ឬរិះគន់ចំពោះរឿងរ៉ាវដែលកន្លងផុតទេ ប៉ុន្តែបើគេនិ-យាយអំពីការសម្លាប់រង្គាលរបស់ប៉ុល-ពត និងអំពីគុណាបំណាច់ដែលយួនមករំ-ដោះខ្មែរនៅឆ្នាំ១៩៧៩ សូមមេត្តាក្រឡេកមើល ដែលចិនប៉េកាំងនិងយួនហាណូយ បានរៀបចំទុកតាំងពីខែមិនា១៩៧០ផង ។

ដល់មកថ្ងៃទី៣០មេសា១៩៧០, កងទ័ពយួនខាងត្បូងនិងអាមេរិកាំង ចាប់ផ្តើមធ្វើអន្តរាគមន៍ប្រឆាំង«ទីជំរក»យៀកកុងនិងយួនខាងជើង នៅភូមិភាគបូព៌ានៃកម្ពុ-ជា ។ ក្នុងអំឡុងនៃសង្គ្រាមយួន, កងពលធំឧទ្ធម្ភាគចក្រលេខ១អាមេរិកាំង គ្មានសិទ្ធិដើម្បីវាយប្រហារ «ទីជំរក» យៀកកុងនិងយួនខាងជើង នៅក្នុងទឹកដីលាវនិងកម្ពុជាទេ ។ បំរាមនេះបានធ្វើឲ្យក្តៅក្រហាយដល់ពលទាហាននិងមេបញ្ជាការនៃកងពលធំឧទ្ធម្ភាគចក្រ ដែលរងការវាយប្រហារឥតឈប់ឈរ ពីកងកម្លាំងយៀកកុងនិងយួនខាងជើង ដែលលាក់ខ្លួនក្នុងទីជំរកទាំងនេះ ។ ថ្ងៃទី១ឧសភា១៩៧០, ជាទីបញ្ចប់នៃការហាមឃាត់ ។ កងពលធំឧទ្ធម្ភាគចក្រអាមេរិកាំង ចាប់ផ្តើមធ្វើប្រតិបត្តិការរួមគ្នា ជាមួយកងពលធំថ្មើរជើងយួនខាងត្បូង ដោយវាយសំរុកមកក្នុងទឹកដីខ្មែរ ។ យុទ្ធនាការនេះដែលមានរយៈពេល២ខែ បានរុករានទៅដល់ទីជំរកយួនខាងជើងនិងយៀកកុង ។ គោលដៅសំខាន់គឺជំរំនិងមូលដ្ឋានលួចលាក់ សំរាប់គ្រឿងអាវុធនិងស្បៀងអាហារ ដែលបានគំរាមដល់កងទ័ពអាមេរិកាំង និងសម្ព័ន្ធមិត្តយួនខាងត្បូង តាំងពីដើមដំបូងនៃជំនាន់ឆ្នាំ៦០ ។ ការវាយប្រហារនេះ ជាជោគជ័យមិនធ្លាប់មាន ។ ការរកឃើញធំបំផុតក្នុងយុទ្ធនាការ គឺតំបន់ដែលអាមេរិកាំងឲ្យឈ្មោះថា «ប៊ុរី» ។ ក្រុមស៊ើបការណ៍ប្រចាំកងពលធំឧទ្ធម្ភាគចក្រ បានរកឃើញជំរំសំរាប់ហ្វឹកហ្វឺន និងជំរំសំរាប់តម្កល់គ្រឿងអាវុធ ព្រមទាំងស្បៀងអាហារយ៉ាងសំខាន់ ដែលលាតសន្ធឹងលើផ្ទៃដី៣គ.ម.ក្រឡា ។ ក្រោយមកគេបានរកឃើញថែមទៀត នូវឃ្លាំងចំនួនជាង១៨០ អាគារ១៨ខ្នង ដែលជារោងប្រជុំ, កន្លែងរៀនសូត្រ, កន្លែងហ្វឹកហាត់ ហើយនិងព្រមទាំងកន្លែងសំរាប់ចិញ្ចឹមសត្វផង ។ កងទ័ពយៀកកុងនិងយួនខាងជើងបានជន្លៀសខ្លួនចេញអស់ពីតំបន់នេះ ប៉ុន្តែបញ្ជីសំរាប់ផ្តល់ភស្តុភារនិងពត៌មានផ្សេងទៀត អាចឲ្យដឹងបានថា តំបន់ត្រូវបានប្រើជាឃ្លាំងសំរាប់តំកល់ និងជាមូលដ្ឋានសំរាប់ហ្វឹកហ្វឺនដល់ពលទាហាន ដែលត្រូវបានបញ្ជូនពីយួនខាងជើង។ សម្ភារៈសឹកដែលត្រូវប្រមូលបានពីកន្លែងលាក់នេះមាន ៖ កាំភ្លើងដៃនិងកាំភ្លើងបាញ់យន្តហោះជាង១,៥០០ដើម, មីនប្រឆាំងមនុស្ស២២ហិប, គ្រាប់កាំភ្លើងត្បាល់និងគ្រាប់បែកដៃរាប់ពាន់គ្រាប់ និងអង្ករ៣០តោន ។ ការវាយសំរុកចូលទៅកម្ពុជា បានលទ្ធផលហួសពីការសង្ឃឹមទុក ហើយជាជោគជ័យធំបំផុតពុំធ្លាប់មានរបស់កងព-

លធំឧទ្ទាមគចក្រ ដែលធ្លាប់តែប្រតិបត្តិការតែនៅក្នុងដែនដីយួនខាងត្បូង ដែលជាការបំផុសឲ្យឃើញ នូវការលូកដៃរបស់រាជរដ្ឋាភិបាលខ្មែរក្នុងសង្គ្រាមនៅយួនខាងត្បូង ហើយនៅពេលប្រជារាស្ត្រខ្មែរស្លូតត្រង់ជួបប្រទះលើវិនាសកម្ម ក៏គេពុំដឹងថាមកពីហេតុអ្វី ។ ពួកនាយទាហានអាមេរិកាំងបញ្ជាក់ថា ប្រតិបត្តិការទាំងនេះបានប្រព្រឹត្តទៅដោយយឺតពេល បើគេអាចរារាំងការប្រមូលផ្តុំកម្លាំងទ័ពរបស់វៀតកុងនៅខាងក្រៅយួនខាងត្បូងបាន ច្រកចេញនៃសង្គ្រាមត្រូវមានលក្ខណៈប្រែប្រួលទៅផ្សេង ។

នៅប៉េកាំង, ក្នុងថ្ងៃទី៥ឧសភា១៩៧០, ចិនផ្តាច់ចំណងទូតពីភ្នំពេញ និងបានបង្កើត«រណសិរ្សរួបរួមជាតិកម្ពុជា» ។ រាជរដ្ឋាភិបាលនៃរណសិរ្សរួបរួមជាតិកម្ពុជាញ៉ី ត្រូវបានប្រកាសឡើងដែរ ។ បន្ទាប់មក សមាសភាពនៃគណរដ្ឋមន្ត្រីត្រូវបានប្រកាសជាផ្លូវការនៅប៉េកាំង ក្នុងថ្ងៃទី១៣ឧសភា១៩៧០ ។ នាយករដ្ឋមន្ត្រីជាវរជនជើងចាស់ដែលគាំទ្រសីហនុ, ប៉ែន-នុត, ឧបនាយករដ្ឋមន្ត្រី ជាសមាជិករបស់បក្សកុម្មុយនិស្តកម្ពុជា និងជាអតីតតំណាងរាស្ត្រក្នុងរាជរដ្ឋាភិបាល, ខៀវ-សំផន ។ គណរដ្ឋមន្ត្រីខ្មែរនៅប៉េកាំង ត្រូវបានផ្សំឡើងពីសមាសធាតុ ជាពួកសីហនុនិយម ។ ប៉ុន្តែ, ដល់ខែវិច្ឆិកា១៩៧៣, គ្រប់ក្រសួងរដ្ឋក្នុងរដ្ឋាភិបាលនៃរណសិរ្សរួបរួមជាតិកម្ពុជា ត្រូវបានផ្ទេរមកនៅក្រោមការកាន់កាប់របស់មេដឹកនាំឧទ្ទាមនៅកម្ពុជាវិញ ។

ចំណែកខាងភ្នំពេញ ការប្រឈមមុខផ្នែកនយោបាយ ដើម្បីទប់ទល់អំពើឈ្លានពានរបស់យួនកុម្មុយនិស្ត បានត្រូវឲ្យមានសន្និសិទមួយស្តីពីបញ្ហាខ្មែរ នៅហ្សាការតាក្នុងថ្ងៃទី១៦-១៧ឧសភា១៩៧០ ។ សេចក្តីថ្លែងការណ៍រួមនៃប្រទេសទាំង១២ បានតម្រូវឲ្យពលទាហានបរទេសទាំងអស់ដកថយពីកម្ពុជា, ប៉ុន្តែឥតអំពើ ។

នៅខែវិច្ឆិកា១៩៧០, បន្ទាប់ពីកិច្ចចរចា រវាងតំណាងយួនខាងជើងនិងតំណាងនៃបក្សកុម្មុយនិស្តកម្ពុជា ក្រុមទាំង១០នៃកម្មាភិបាលរបស់បក្សប្រជាជនបដិវត្តន៍កម្ពុជា គឺខ្មែរវៀតមិញប្រមាណ១,០០០នាក់ ដែលបានស្នាក់នៅហាណូយ តាំងពីឆ្នាំ១៩៥៤-១៩៥៥ ចាប់ផ្តើមត្រឡប់មកកម្ពុជាវិញ ។

នៅកម្ពុជា, វៀតកុងនិងយួនខាងជើង កាន់តែមានអនុភាពខ្លាំងឡើង ដោយការគាំទ្រពីប៉េកាំង ហើយជាពិសេសពីរាជរដ្ឋាភិបាលនៃរណសិរ្សរួបរួមជាតិកម្ពុជា ដែលមានសីហនុជាមគ្គុទ្ទេសក៍ដ៏ឆ្នើម ។ អំណើះតទៅ, សីហនុបោះបង់ទ្រឹស្តីមួយដែលថាក្រុមបក្សព័ន្ធរបស់គាត់ ឬរាស្ត្រខ្មែរទាំងមូលតស៊ូតែឯកឯង ប្រឆាំង«ចក្រពត្តិនិយមអាមេរិកាំងនិងពួកបរិវារ» ។

នៅថ្ងៃទី២៥មិថុនា១៩៧១, សីហនុបានសារភាពនៅចំពោះមុខនៃអ្នកតំណាងរបស់ទូរទស្សន៍កាណាដា អំពីវត្តមាននៅកម្ពុជា នៃ«គ្រួបង្កាត់យួនខាងជើងប្រមា-

ណា២,០០០នាក់ ដែលជួយជ្រោមជ្រែងដល់ក្រុមបក្សព័ន្ធរបស់គាត់» ។ ចំនួនពិតនៃកងទ័ពកុម្មុយនិស្តនៅកម្ពុជាក្នុងឆ្នាំ១៩៧១ ត្រូវបានផ្សំឡើងដោយពលទាហានយៀកកុងនិងយួនខាងជើង ចំនួន៩០% ។ ចំនួន១០%សេសសល់ជាខ្មែរក្រហមដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកខ្មែរកុម្មុយនិស្ត សាឡុត-សរ, ចំណែកអាតីតខ្មែរយៀកមិញប្រមាណ១,០០០នាក់ ដែលចេញដំណើរពីហាណូយតាមផ្លូវលំហូ-ជីមិញ, បានមកដល់ជាលើកទី១ក្នុងខេត្តក្រចេះ នៅខែកុម្ភៈ១៩៧១ ។ ក្រុមនេះត្រូវបានចាត់តាំងតាមមុខនាទីតូចតាច ដែលគ្មានភាពជាក់លាក់ នៅពាសពេញកម្ពុជា ដោយក្រុមរបស់សាឡុត-សរ ។

នៅថ្ងៃទី២០កញ្ញា១៩៧១, អៀង-សារីបានទៅដល់ក្រុងប៉េកាំង ក្នុងឋានៈជា«បេសកជនពិសេសនៃកងទ័ពរំដោះរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងរណសិរ្សរួបរួមជាតិកម្ពុជា» ។ ប៉ុន្តែការពិត, មុខនាទីរបស់គាត់គឺឃ្លាំមើលសកម្មភាពរបស់សីហនុ និងពង្រឹងទំនាក់ទំនងរវាងចិនជាមួយបក្សកុម្មុយនិស្តកម្ពុជា ។

ដល់ទៅចុងឆ្នាំ១៩៧១, ក្រុមសេអ៊ីអាអាមេរិកាំងប៉ាន់ប្រមាណថា កងទ័ពខ្មែរក្រហមកំពុងរីកធំធាត់, ផ្នែកយោធានិងនយោបាយ, ក្នុងចំណោមកងទ័ពយៀកកុង ។ ប្រព័ន្ធអំណាចរបស់រណសិរ្សរួបរួមជាតិនៅតំបន់រំដោះប្រែប្រួល ហើយពួកខ្មែរកុម្មុយនិស្តដែលប្រកាន់មាគ៌ាតឹងរ៉ឹងឥតព្រំដែន ចាប់ផ្តើម«ក្តោបក្តាប់» ។ ពាក្យថា«រំដោះ» និង «ស្តេច» ដែលទាំងពីនេះត្រូវបានផ្សំជាមួយសីហនុ, ពេលនោះត្រូវបានប្រើប្រាស់តិចជាងពេលមុន ។ បក្សកុម្មុយនិស្តកម្ពុជាចាប់ផ្តើមស្នើឲ្យយួនបញ្ឈប់សកម្មភាពផ្នែកនយោបាយក្នុងតំបន់រំដោះ ជាទីដែលកងកម្លាំងយៀកកុង នៅតែមានចំនួនច្រើនជាងខ្មែរក្រហម ។

នៅរដូវក្តៅនៃឆ្នាំ១៩៧២, ដោយមានសម្ពាធពីហង់រី-គីហ្ស៊ីហ្គ័រ ទៅលើភាគីយួន, ដំណើរបន្តបន្ទាប់នៃទំនាក់ទំនងនិងកិច្ចចរចាររវាងខ្មែរកុម្មុយនិស្តជាមួយយួន ជាពិសេសជាមួយផាម-ហ៊ុង មកពីតំបន់ណាមបូ ដែលនៅក្នុងនោះ យួនទទូចឲ្យខ្មែរក្រហមចរចាជាមួយលន់-នល់និងអាមេរិកាំង ដើម្បីសំរបសំរួលជាមួយកិច្ចចរចាយួន-អាមេរិកាំង ដែលកំពុងប្រព្រឹត្តនៅទីក្រុងប៉ារីស ។ តាមពិត, ការទទូចបង្ខំរបស់យួនកុម្មុយនិស្តទៅលើខ្មែរក្រហម គឺធ្វើយ៉ាងណាដើម្បីជំរុញសហរដ្ឋអាមេរិកឲ្យឆាប់ដកកងទ័ពពីយួនខាងត្បូង ។ ពីថ្ងៃទី២៤ទៅ២៦មករា១៩៧៣ មានការជួបគ្នាម្តងទៀត រវាងសាឡុត-សរនិងផាម-ហ៊ុង ដែលបានបង្ហាញទៅសាឡុត-សរនូវអត្ថបទថតចម្លងស្តីពីគំរោងនៃកិច្ចព្រមព្រៀង ដែលនឹងត្រូវសំរេចយកដោយការចុះហត្ថលេខានៅក្រុងប៉ារីស ក្នុងថ្ងៃទី២៧មករា១៩៧៣ ថា«កងទ័ពបរទេសទាំងអស់»ត្រូវដកថយពីដែនដីខ្មែរនិងលាវ ។

ខ្មែរក្រហមបានបដិសេធ ហើយចោទប្រកាន់ទាំងលិចិតល្ងង់ថា «យួនក្បត់» ព្រោះមិនយល់ដល់គំរោងរបស់យួនកុម្មុយនិស្តដែលគិតថា ៖ «បញ្ហាសំខាន់គឺយួនត្រូវធ្វើយ៉ាងណា ដើម្បីឲ្យសហរដ្ឋអាមេរិកឆាប់ដកថយពីឥណ្ឌូចិនសិន មិនខុសគ្នាពីគំរោងដែលចិននិងសូវៀតបានរៀបចំនៅឆ្នាំ១៩៥៤ឯក្រុងហ្សឺណែវ ដើម្បីដេញអាណានិគមបារាំងទេ» ។ ខ្មែរក្រហមចាប់ផ្ដើមធ្វើ «បាតុកម្មប្រជាជន» ដែលត្រូវបានរៀបចំឡើងដោយបក្សកុម្មុយនិស្ត នៅតាមតំបន់ដែលកាន់កាប់ដោយខ្មែរក្រហម ដើម្បីស្នើឲ្យឃោធភូមិយួនចាកចេញពីកម្ពុជា ។ បាតុកម្មទាំងឡាយនេះ ជាដំណើរចាប់ផ្ដើមនៃការពើបប្រយុទ្ធញឹកញាប់ រវាងខ្មែរក្រហមនិងយៀកកុង ដូចជាការប្រយុទ្ធទាំងឡាយដែលកើតមាននៅតំបន់ជុំវិញសៀមរាបជាដើម ។

នៅដំណាច់ខែកុម្ភៈ១៩៧៣, ដោយកាត់តាមផ្លូវលំហូ-ជីមិញ, សីហនុមកទស្សនា«តំបន់រំដោះ» ។ គាត់បានធ្វើដំណើរទៅតំបន់អង្គរក្នុងខេត្តសៀមរាប ហើយបានជួបថ្នាក់ដឹកនាំខ្មែរក្រហម ប៉ុន្តែគ្មានការជួបប្រាស្រ័យជាមួយប្រជាជនសោះឡើយ ។ ទន្ទឹមពេលគ្នា កងកម្លាំងយៀកកុងនិងយួនខាងជើង ដោយសំរបតាមកិច្ចព្រមព្រៀងនៅក្រុងប៉ារីស ចាប់ផ្ដើមជន្លៀសខ្លួនពីកម្ពុជា ហើយវិលត្រឡប់ទៅរកទីតាំងនៅតាមបណ្ដោយព្រំដែនខ្មែរវិញ ជាពិសេសនៅភូមិភាគព្យសាន ដែលយួនយៀកមិញចាប់ផ្ដើមតាំងនៅតាំងពីក្រោយសន្និសិទនៅក្រុងហ្សឺណែវក្នុងឆ្នាំ១៩៥៤ រហូតមកទល់រយៈកាលនៃសង្គ្រាមជាមួយអាមេរិកាំង ហើយដែលនឹងក្លាយទៅជាបុព្វហេតុនៃជម្លោះជាមួយរបបប៉ុល-ពត ក្រោយថ្ងៃទី១៧មេសា១៩៧៥ ។ ឧប្បត្តិហេតុជាមួយខ្មែរក្រហមកាន់តែកើតឡើងញឹកញាប់ ក្នុងពេលដកថយ ។

ក្នុងខណៈនោះ, បន្ទាប់ពីការផ្អាកនូវការទម្លាក់គ្រាប់បែកលើយួនខាងត្បូងនិងលាវ តាមកិច្ចព្រមព្រៀងនៅក្រុងប៉ារីស កងអាកាសចរណ៍អាមេរិកាំងបានបង្កើនការទម្លាក់គ្រាប់បែកនៅកម្ពុជា ដោយសារការរឹងរូសរបស់ខ្មែរក្រហម ដែលមិនព្រមធ្វើកិច្ចចរចា និងដើម្បីគាំទ្រដល់កងទ័ពនៃសាធារណរដ្ឋខ្មែរ ។ នៅថ្ងៃទី២០មិនា១៩៧៣, សមូហភាវូបនីយកម្មផ្នែកកសិកម្មនៅកម្ពុជា បានចាប់ផ្ដើមឡើងតាមតំបន់របស់ខ្មែរក្រហម ។ តំណែទម្រង់ខាងវិស័យកសិកម្ម បានជំរុញរាស្ត្រខ្មែរ៣០,០០០នាក់ ឲ្យរត់ទៅជ្រកនៅយួនខាងត្បូង, ហើយ២០,០០០នាក់ទៀត មករស់នៅក្រោមការគ្រប់គ្រងនៃរបបសាធារណរដ្ឋ ។ នៅ«តំបន់រំដោះ» មានការសរិតសំរាំងលើពួកសីហនុនិយម ទៅក្នុងចលនាប្រឆាំងជាមួយលន់-នល់ និងការបំបាត់គណមន្ត្រីសង្ឃ ។ ខ្មែរក្រហមសំដែងហឹង្សាចំពោះសីហនុ យួន និង«ខ្មែរហាណូយ» ដែលបានត្រឡប់មកកម្ពុជាវិញ នៅឆ្នាំ១៩៧០-១៩៧២ ។ ពួកខ្មែរយៀកមិញជើងចាស់ទាំងនេះ ត្រូវបានសរិតសំរាំងដោយស្ងៀមស្ងាត់, ប៉ុន្តែតាមប្រព័ន្ធច្បាស់លាស់, ចេញ

ពីបក្សកុម្មុយនិស្តកម្ពុជា ។ អ្នកខ្លះបានសំរេចចិត្តដើម្បីគេចខ្លួនពីការសំរិតសំរាំងនេះ ដោយត្រឡប់ទៅប្រទេសយួនវិញជាមួយយៀកកុង ដូចកាលពីឆ្នាំ១៩៥៤-១៩៥៥ ប៉ុន្តែភាគច្រើនត្រូវបានពិឃាត ដោយក្រុមរបស់សាឡុត-សរ ចំណែកខាងយួន ពួកគេកាត់បន្ថយយ៉ាងសន្ធឹកសន្ធាប់ នូវការបញ្ជូនអាវុធចំពោះខ្មែរក្រហម ។

នៅថ្ងៃទី១៥កក្កដា១៩៧៣ សភាអាមេរិកាំងបានបោះឆ្នោត ដើម្បីអនុម័តបញ្ឈប់ការទម្លាក់គ្រាប់បែកលើកម្ពុជា ។ តាំងពីឆ្នាំ១៩៦៩ គ្រាប់បែកប្រមាណជាង៥០ម៉ឺនតោន ត្រូវបានទម្លាក់លើកម្ពុជា ។ ជាងពាក់កណ្តាលនៃគ្រាប់នេះ ២៥៧,៤៦៥តោនត្រូវបានទម្លាក់ ចាប់ពីត្រឹមតែខែមករា១៩៧៣ មកទល់ខែកក្កដា១៩៧៣នេះ, ដើម្បីការពារក្រុងភ្នំពេញ ពីការវាយប្រហារផ្តាច់ព្រ័ត្ររបស់ក្រុមសាឡុត-សរនៅឆ្នាំ១៩៧៣ ។ ដល់មកថ្ងៃទី២៧សីហា១៩៧៣ ឧត្តមសេនីយ៍ស៊ីសុវត្ថិ-សិរីមត: បានផ្ញើរលិខិតចំហមួយទៅជូនសីហនុ ជាបងប្អូនជីដូនមួយ ដោយណែនាំសីហនុឲ្យដឹងខ្លួនចំពោះកំហុសទាំងឡាយ និងឲ្យដកខ្លួនពីពួកកុម្មុយនិស្តអាស៊ី ។

បន្ទាប់ពីការដកថយនៃកងទ័ពយៀកកុងនិងយួនខាងជើង, ខ្មែរក្រហមដែលមានពលទាហានកាន់តែច្រើន បានបើកការវាយលុកយ៉ាងធំទៅលើទីក្រុងកំពង់ចាម នៅថ្ងៃទី១កញ្ញា១៩៧៣ ដែលស្ថិតនៅចម្ងាយ១២០គ.ម.ខាងព្យសាននៃក្រុងភ្នំពេញ នាត្រើយខាងលិចនៃទន្លេមេគង្គ ។ ប៉ុន្តែពួកនេះ ត្រូវបានវាយរុញច្រានថយក្រោយវិញ ដោយទទួលការខូចខាតជាទម្ងន់ បន្ទាប់ពីការប្រយុទ្ធយ៉ាងសាហាវ អស់រយ:ពេលពីរសប្តាហ៍ ដែលនៅឱកាសនោះ កងនាវាចរណ៍ខ្មែរបានបំពេញមុខនាទីយ៉ាងសំខាន់ ។

ពីការប្រយុទ្ធនេះ, ខ្មែរក្រហមចង់បង្ហាញជំហរឯករាជ្យម្ចាស់ការរបស់ខ្លួន ។ ប៉ុន្តែតាមពិត ដូចជានៅថ្ងៃទី៤មិនា១៩៧៤, ឡេ-ឌឹកថូ បានទទួលលិខិតមួយពីសាឡុត-សរ ដែលនៅក្នុងនោះ សាឡុត-សរបានអះអាងអំពី«ភក្តីភាពនៃបក្សកុម្មុយនិស្តកម្ពុជា ចំពោះមិត្តភាព ភាតរភាព និងសាមគ្គីភាព រវាងប្រជាជនទាំងពីរ» ។

យ៉ាងណាក៏ដោយ, ការព្រួយបារម្ភរបស់សាឡុត-សរ ចំពោះឧបសគ្គទៅអនាគត និងចំពោះយួន ដែលតាំងខ្លួនជានិច្ចជាអ្នកត្រួតត្រា ឬជាអ្នកបណ្តុះបណ្តាល បានជំរុញសាឡុត-សរឲ្យព្យាយាមកំចាត់ពួកកម្មាភិបាលខ្មែរដែលត្រឡប់មកពីហាណូយ ត្រូវបានសម្លាប់ចោលស្ទើរតែទាំងអស់ ។

ប៉ុន្តែ, ចំពោះមុខយួន, សាឡុត-សរបន្តសំដែងមិត្តភាពដូចជាតាមលិខិត ដែលគណកម្មាធិការមជ្ឈិមនៃបក្សពលករយួនបានទទួលពីសាឡុត-សរ នៅថ្ងៃទី៣តុលា១៩៧៤ថា ៖ «បក្សរបស់យើងដើរតាមមាគ៌ានយោបាយត្រឹមត្រូវ, ប៉ុន្តែជ័យជំនះរបស់យើង មិនអាចត្រូវបំបែកចេញ ពីការឧបត្ថម្ភរបស់បក្សពលករវៀតណាម

និងប្រជាជនវៀតណាមបានឡើយ» ។ ហើយបន្ទាប់ពីការចាប់ផ្តើមនៃការវាយសំរុកផ្តាច់ព្រ័ត្រលើក្រុងភ្នំពេញ នៅថ្ងៃទី១មករា១៩៧៥, ឡេ-ឌឹកថូ បានទទួលលិខិតមួយច្បាប់ទៀតពីសាឡុត-សរដែលមានន័យថា ៖ «ជំនួយវៀតណាមបានរួមចំ-ណែកយ៉ាងធំធេង ក្នុងជ័យជំនះរបស់បក្សកុម្មុយនិស្តកម្ពុជា» ។

ការវាយសម្រុកនេះមានអមបន្ត ដោយការសម្លាប់រង្គាល ទៅលើរាស្ត្រសាម-ញ្ញតាមតំបន់ដែលស្ថិតនៅត្រើយខាងកើតនៃទន្លេមេគង្គ, ក៏ដូចជានៅភាគខាងជើង និងភាគខាងត្បូងនៃរដ្ឋធានីដែរ ។ ចាប់ពីថ្ងៃទី១៦កុម្ភៈ១៩៧៥, អាមេរិកាំងចាប់ផ្តើមធ្វើ«ស្ពានអាកាស» ដែលសំដៅផ្តល់ស្បៀងទៅក្រុងភ្នំពេញនិងកងកម្លាំងប្រយុទ្ធបន្ទាប់ពីផ្លូវគមនាគមន៍ជើងទឹកនិងជើងគោក ត្រូវបានកាត់ផ្តាច់អស់ ។

នៅថ្ងៃទី១២មិនា១៩៧៥, ឧត្តមសេនិយសុស្ថែន-ហ្វែរណង់ដេស៍, ជាអគ្គបញ្ជាការនៃកងយោធពលខេមរជាតិ, បានសុំលាពីតំណែង ដើម្បីជៀសវាងការជំទាស់ជាយថាហេតុ ក្នុងកិច្ចចរចាជាមួយខ្មែរក្រហម ។ រូបគាត់ត្រូវបានជំនួសដោយឧត្តមសេនិយសក់-ស៊ុតសាខន ដែលបានក្លាយជានាយអគ្គសេនាធិការថ្មី ។ ពីព្រោះចាប់តាំងពីខែមិនា១៩៧៤, ឯកអគ្គរដ្ឋទូតថ្មីនៃសហរដ្ឋអាមេរិក ជូន-ហ្កាន់ធើឌៀន, បានមកកាន់តំណែងនៅស្ថានទូតឯក្រុងភ្នំពេញ ។ ហ្កាន់ធើឌៀន បានសាកល្បងរកដំ-ណោះស្រាយស្តីពីវិបត្តិកម្ពុជាតាមកិច្ចចរចា, ដូចបានធ្វើរួចហើយ រវាងពួកប៉ាថេត-ឡាវនិងរដ្ឋាភិបាលលាវ។ រហូតដល់ចុងឆ្នាំ១៩៧៤, ហ្កាន់ធើឌៀនបានទាក់ទងជាមួយឯកអគ្គរដ្ឋទូតបារាំង, ម៉ាណាក់, ប្រចាំការនៅប៉េកាំង ជាទីដែលស្តេចសីហនុស្ថិតនៅទីនោះ ។ ម៉ាណាក់ និងអនុប្រធាន ម៉ាឡូ បានជួយជ្រោមជ្រែងហ្កាធើឌៀនឲ្យមានកិច្ចប្រជុំមួយនៅម៉ាទីនីក រវាងប្រធានាធិបតីបារាំង វ៉ាឡឺរី ហ្សីស្កាដ៍ ដេស្តាំងជាមួយប្រធានាធិបតីអាមេរិកាំង ហ្សេរ៉ាល់-ហ្វដ៍, ដែលទាំងពីរនាក់បានអញ្ជើញស្តេចសីហនុ ឲ្យត្រឡប់មកកាន់អំណាចវិញ ។ ប៉ុន្តែសីហនុបានឆ្លើយថា ៖ «ហួសពេលហើយ» (ប្រសាសន៍ផ្ទាល់របស់ចូន-ហ្កាន់ធើឌៀន, អតីតឯងអគ្គរដ្ឋទូតអាមេរិកាំងប្រចាំក្រុងភ្នំពេញ, ក្នុងភាពយន្តឯកសារ «ការរលំនៃក្រុងភ្នំពេញ») ។ ពិតហើយ, ព្រោះអនាគតនៃប្រជារាស្ត្រខ្មែរនិងប្រទេសខ្មែរ បានធ្លាក់ក្នុងកណ្តាប់ដៃចិននិងយួនតាំងពីយូរលង់ ហើយគោលបំណងនៃ«មហាមិត្តតាំងពីរ»របស់ស្តេចសីហនុ គឺកែប្រែកម្ពុជាឲ្យទៅជារដ្ឋកុម្មុយនិស្ត, ដូច្នេះការអនុញ្ញាតសីហនុ ឲ្យមកសោយរាជ្យវិញ ជារឿងឥតប្រយោជន៍ ។

ដោយសង្ឃឹមថា ការចេញដំណើររបស់លោក នឹងបើកចំហឲ្យមានការចរចាជាមួយខ្មែរក្រហម, សេនាប្រមុខលន់-លន់បានចាកចោលទីក្រុងភ្នំពេញ ទៅកាន់ហូណូលូលូ, កោះហាវ៉ៃ, តាមសំណូមពរពីរដ្ឋាភិបាល ។ ចំណែកឧត្តមសេនិយសូ

កាំខូយ, ជាប្រធានព្រឹទ្ធសភា, ត្រូវបានតែងតាំងជាប្រមុខរដ្ឋស្ដីទី ។ ក្នុងខណៈនោះ, ខ្មែរក្រហមដណ្ដើមយកបានទីក្រុងអ្នកលឿង ជាទីតាំងសំខាន់ចុងក្រោយ ដែលកាន់កាប់ដោយកងទ័ពសាធារណរដ្ឋតាមដងទន្លេមេគង្គ, នៅចម្ងាយ៦០គ.ម. ខាងអាគ្នេយ៍ទីក្រុងភ្នំពេញ តាមផ្លូវជាតិលេខ១ ។ នៅថ្ងៃទី១២មេសា១៩៧៥, កងឧទ្ធម្ភាគចក្រ ដែលចេញពីនាវាផ្ទុកយន្តហោះនៅឈូងសមុទ្រសៀម បានមកជន្លៀសសមាជិកនិងបុគ្គលិកនៃស្ថានទូតអាមេរិកាំង ។ ឧត្ដមសេនិយសូកាំខូយ ក៏បានចេញដំណើរក្នុងពេលនោះដែរ ។ នៅថ្ងៃទី១៥មេសា១៩៧៥, ខ្មែរក្រហមចូលកាន់កាប់ទីក្រុងតាខ្មៅ នៅចម្ងាយ១០គ.ម. ខាងត្បូងក្រុងភ្នំពេញ ហើយវាយសំរុកឆ្ពោះទៅស្ពានមុនីវង្ស ព្រមទាំងអាកាសយានដ្ឋានផង ។

ស្ដីពី«ជ័យជំនះ»របស់ខ្មែរក្រហម នៅថ្ងៃទី១៧មេសា១៩៧៥, តាមការអះអាងរបស់ វីល្លីយ៉ាម-ឌីយើ នៅក្នុងសៀវភៅ «ចិននិងវៀតណាម ៖ ឫសគល់នៃវិវាទ», បេឃើលី, កាលីហ្វ័រនៀ, ទំព័រ៦០, និងការអះអាងរបស់ អ៊ីសាក់ស៍ នៅក្នុងសៀវភៅឈ្មោះឈ្មោះ «ខ្វះកិត្តិយស», ទំព័រ២៧៦ «ពលទាហានយៀកកុង២កងពលធំបានចូលរួមក្នុងការវាយសំរុកផ្ដាច់ព្រ័ត្រលើក្រុងភ្នំពេញ» ។ ចំណែក ខេ ហ្គាហ្វ៍, អ្នកនិពន្ធសៀវភៅឈ្មោះ «ឫសកែវនៃរបបប៉ុល-ពតនៅកម្ពុជា», ១៩៨៧, ទំព័រ១៣៩, បានបញ្ជាក់ដោយផ្អែកទៅលើបទសម្ភាសន៍មួយនៅប្រទេសយួនថា ៖ «កាំភ្លើងធំរបស់យួនបានចូលរួម ក្នុងការវាយលុក ដើម្បីបំបែកក្រុងភ្នំពេញ» ។ អ្នកនិពន្ធចុងក្រោយ, ប៊ីរឆេត៍, ដែលបានសរសេរសៀវភៅ «ត្រីកោណចិន-កម្ពុជា-វៀតណាម» ទំព័រ១៩៩ បញ្ជាក់ថា ៖ «នៅចុងឆ្នាំ១៩៧៤, សាឡុត-សរបានធ្វើដំណើរទៅប៉េកាំងនិងហាណូយ ដើម្បីស្នើរកជំនួយយោធា ។ យួនខាងជើងបានផ្ដល់កាំភ្លើងធំធុនធ្ងន់ និងអ្នកបាញ់មួយចំនួន ។ ទស្សនកិច្ចនេះពុំត្រូវបានផ្សព្វផ្សាយឲ្យដឹងទេ, សាឡុតសរ-ប៉ុលពតតែងបដិសេធជានិច្ច នូវការចូលរួមណាមួយពីយួន នៅក្នុងជ័យជំនះជាប្រវត្តិសាស្ត្រ នៅថ្ងៃទី១៧មេសា១៩៧៥នេះ» ។

ប៉ុន្តែកត្តាធំៗដែលបានជំរុញសាឡុត-សរឲ្យសំរេចបាន «ជ័យជំនះជាប្រវត្តិសាស្ត្រ»នេះ មាន៦ចំណុចគឺ ៖

១- ដោយសារសភានិងប្រជារាស្ត្រអាមេរិកាំងឈប់គាំទ្រសង្គ្រាម ឈប់ផ្ដល់ជំនួយចំពោះសាធារណរដ្ឋខ្មែរ ។

២- ដោយសារសហភាពសូវៀត ប្រាថ្នាឲ្យកម្ពុជាក្លាយជារដ្ឋកុម្មុយនិស្ត នៅក្នុងសហព័ន្ធឥណ្ឌូចិន តាមគំរោងរបស់អង្គការកុម្មុយនិស្តអន្តរជាតិសូវៀត ។

៣- ដោយសារចិនកុម្មុយនិស្ត ចង់ឲ្យកម្ពុជារបស់ប៉ុល-ពត ក្លាយជាកូនសម្ព័ន្ធយរបស់គេ សំរាប់ទុកនៅក្រោយខ្នងយួន ដើម្បីទប់ទល់ជាមួយឥទ្ធិពលសូវៀត និ

ងសំរាប់ពង្រីកឥទ្ធិពលចិននៅក្នុងប្រទេសសៀម...។

៤- ដោយសារយួនកុម្មុយនិស្ត មានបំណងឲ្យផែនការយៀកមិញ ដែលពួកគេបានបង្កបង្កើតតាំងពីឆ្នាំ១៩៣០នៅកម្ពុជា បានទៅដល់ទីដៅ ដើម្បីឲ្យខ្មែរបានកាប់សម្លាប់គ្នាឯងជំនួសពួកគេ ទៅតាមលទ្ធិកុម្មុយនិស្តព្រៃផ្សៃ រួចហើយខ្មែរត្រូវនៅក្រោមរណបយួន ។

៥- ដោយសារនយោបាយដ៏វាងវៃនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងរណសិរ្សរួបរួមជាតិកម្ពុជារបស់សីហនុ ដែលមានអនុភាពខ្លាំងក្លាលើឆាកអន្តរជាតិ ។

៦- ដោយសារបញ្ញវ័ន្តខ្មែរមួយចំនួន ដែលជួបប្រទះអំពើពុករលួយ អំពើផ្តាច់ការ និងអំពើអយុត្តិធម៌ក្នុងសង្គមខ្មែរ ហើយនឹកមមៃដល់ភាពស្អាតស្អំ ស្មើភាពគ្នានៅក្នុងទ្រឹស្តីនៃលទ្ធិម៉ាក់ស៊ីស-ឡេនីនីស្ត ។

ភ្នំទាំងប្រាំមួយ ដែលសុទ្ធតែជាមធ្យោបាយសំរាប់សំរួលដល់អំពើឃ្លានពានរបស់សត្រូវយួន បានបាក់សង្កត់ព្រមគ្នាមកលើប្រជារាស្ត្រខ្មែរ នៅពេលដែលរាស្ត្រខ្មែរ ត្រូវបានបណ្តេញចេញពីផ្ទះសំបែង ពីទីក្រុង ដោយចោលទ្រព្យសម្បត្តិ ដោយបែកបាក់គ្រួសារ តាមរបៀបព្រៃផ្សៃរកទីបំផុតគ្មាន ។ អ្វីដែលខ្ញុំបាទបានឃើញច្បាស់ប្រាកដ គឺវិធានការណ៍៤ ក្នុងចំណោមវិធានការណ៍៥ ដែលសត្រូវយួនធ្លាប់បានប្រើ សំរាប់បំបាត់ពូជខ្មែរ នៅមុនសម័យអាណានិគមបារាំង, បានចាប់ផ្តើមដំណើរការជាស្វ័យប្រវត្តិដូចជា ៖

★ <u>វិធានការណ៍ទី១</u> ៖ «បំផ្លាញពុទ្ធសាសនា» ឬព្រលឹងខ្មែរ

• មានការចាប់ផ្សឹកព្រះសង្ឃ ទូទាំងប្រទេស ។
• ប្រមូលពុទ្ធបដិមាករបោះចោលក្នុងស្រះ ឬវាយកំទេចចោល តាមទ្រឹស្តីថា «ព្រះមួយអង្គ ស៊ីម៉ង់មួយបាវ» ។
• ដុតបំផ្លាញគម្ពីរ សាស្ត្រា និងសៀវភៅធម៌ ។
• រុះរើបំផ្លាញកុដិ វិហារ យកទៅធ្វើសំណង់ផ្សេងៗ ឬយកដែកសរសៃ ។

★ <u>វិធានការណ៍ទី២</u> ៖ «បំផ្លាញសម្បត្តិធម្មជាតិខ្មែរ» ឬសំណង់ក្នុងប្រទេស ឬសាច់ ឈាម សរសៃខ្មែរ ។

• កាប់បំផ្លាញព្រៃឈើ ធ្វើដីដំណាំថ្មី ដោយទុកដីស្រែចំការចាស់ចោលទំនេរ។
• ផលដំណាំត្រូវលិចលង់ដោយទឹកជំនន់ ដែលបណ្តាលពីទំនប់ ។
• សត្វពាហណៈគោក្របីត្រូវស្លាប់ ក្នុងក្បួនរទេះដឹកជញ្ជូន ឬដោយការភ្ជួររាស់ទាំងព្រឹកទាំងល្ងាច ។
• ផ្ទះសំបែង, សាលារៀន, អាគារនានា ត្រូវរុះរើយកទៅសង់មន្ទីរសំរាប់កម្មាភិបាលនៅក្នុងព្រៃ ។

• ផ្លូវថ្នល់ ស្ពានតូចធំ ត្រូវបានបំផ្លាញខ្ទេចអស់ តាំងពីពេលសង្គ្រាម ។
★ វិធានការណ៍ទី៣ ៖ «បំបាត់មេដឹកនាំខ្មែរ» ឬមាត់ ច្រមុះ ត្រចៀក ភ្នែក ខួរក្បាលខ្មែរ
• មន្ត្រី អ្នករដ្ឋការតូចធំ ខុំរដ្ឋការ ត្រូវបានប្រមូលទៅសម្លាប់ចោលទាំងក្រុម ។
• នាយទាហាន នាយទាហានរង គ្រប់បណ្តាស័ក្តិ ត្រូវបានប្រមូលទៅទទួល«សម្តេចឪ» ហើយត្រូវស្លាប់គរជើងគ្នា ។
• បញ្ញវ័ន្ត និស្សិត សិស្សថ្នាក់ទីបញ្ចប់ សុទ្ធតែត្រូវបានចាត់ទុកជាខ្សែសង្វាក់សេ.អ៊ី.អាអាមេរិកាំង ត្រូវស្លាប់ទាំងរណ្តៅ ។ ចំណែកសិស្សថ្នាក់បន្ទាប់ បានទទួលពាក្យណែនាំថា «បើចង់បានបាក់អង ឬបាក់ឌុប ត្រូវលើកទំនប់ ឬជីកប្រឡាយ» ។
★ វិធានការណ៍ទី៤ ៖ «បំបាត់ប្រជារាស្ត្រខ្មែរ» ឬដៃជើង អង្គប្រាណខ្មែរ

• ប្រជាជនថ្មីទាំងអស់ជាឈ្លើយសឹក ជាអ្នកចាញ់សង្គ្រាម និងជាខ្មាំង ព្រោះមិនបានចូលរួមជាមួយបដិវត្តន៍ឲ្យទាន់ពេល ។ កំហុសសូម្បីត្រឹមពាក្យមួយម៉ាត់ អាចត្រូវកាត់ទោសដោយចៅក្រមក្មេងៗ, អាចត្រូវប្រហារជីវិតដោយពេជ្ឈឃាតក្មេងៗ។ ទាំងអស់គ្នាត្រូវធ្វើ«ពលកម្ម» ដោយគ្មានពេលម៉ោងកំណត់ គ្មានសំលៀកបំពាក់, គ្មានចំណីអាហារ និងថ្នាំសង្កូវគ្រប់គ្រាន់ ។ ការបាត់បង់សេរីភាពទាំង១០០ភាគរយរបស់ប្រជារាស្ត្រខ្មែរ នៅជំនាន់នោះស្ថិតនៅត្រង់ ៖ «ឃ្លានមិនហ៊ានមាត់, ឈឺមិនហ៊ានថ្ងូរ និងស្លាប់មិនហ៊ានយំ» ។

ប្រជាជនចាស់មួយចំនួន ដែលដើរមិនទាន់«កងប្រវត្តិសាស្ត្រ» ក៏ត្រូវបានចាត់ទុកជា «ខ្មាំង» ដូចគ្នា ។

ចំណែក វិធានការណ៍ទី៥ គឺ «បញ្ចូលជនជាតិយួន» លោកអ្នកអាននឹងបានឃើញក្នុងដំណាក់មួយទៀត ក្រោយថ្ងៃទី៧មករា១៩៧៩ ។

នៅទីបំផុត, កម្មាភិបាលនិងយោធាដែលបានបំរើបដិវត្តន៍ ក៏ជាខ្មាំងដែរ, ព្រោះតែពាក្យចោទប្រកាន់ថា «ក្បាលយួនខ្លួនខ្មែរ» ឬ«អាយ៉ងយួន» ។ ប៉ុន្តែតាមពិត ក្នុងជួរខ្មែរក្រហមនិងជួររណសិរ្ស, ទាំងដើមចោទទាំងចុងចោទ, ពីថ្នាក់ទាបបំផុតដល់ថ្នាក់កំពូល សុទ្ធជា«អាយ៉ងយួន»ទាំងអស់, ព្រោះយួនជាអ្នកបណ្តុះបណ្តាល ជាអ្នកឲ្យដំបូន្មាន ក្នុងបំណងសំរាប់បំរើផលប្រយោជន៍របស់យួន ហើយមិនដែលឃើញខ្មែរទាំងអស់នេះ បានធ្វើចៅហ្វាយលើយួនទេ ។ ខ្មែរក្លាយជាសត្រូវរវាងខ្មែរគ្នាឯងពេញប្រទេស រហូតដល់សព្វថ្ងៃ ដោយសារនយោបាយរបស់ទមិឡ អន្យតិរ្ថិយកុម្មុយនិស្ត ដែលហូ-ជីមិញបានយកមកបង្រៀនដល់ខ្មែរ ដូចពាក្យស្លោកក្នុងពុទ្ធទំនាយថា ៖ «ក្អែកពាំផ្លែល្វា វាយគ្រប់ស្រុក តំណទៅមុខ អ្នកស្រុកស្រែកយំ»

ពិតហើយ, សត្វក្អែកគឺអ្នកដើរឃោសនា បញ្ចុះបញ្ចូល និយាយកោកកាក ដែលនិយមតែសំលៀកបំពាក់ផាឱបខ្មៅ ។ បន្ទាប់មកផ្លែល្វា គឺទ្រឹស្ដីកុម្មុយនិស្ដ ដែលអួតអាងអំពីភាពស្អាតស្អំ សំបូរបែប ស្មើភាព មហាអស្ចារ្យជាដើម, ប៉ុន្តែដូចពាក្យឧបទេសខ្មែរមួយឃ្លាទៀតថា ៖ «លោកថាល្វាផង សំបកក្រៅហោង ភ្លឺផ្លេកយល់យង់ រីឯក្នុងផ្លែ សឹងតែមមង់ ក្រាស់ក្រៃនៅក្នុង ន័យនោះសោតណា» ។ ចំណែកអ្នកស្រុកស្រែកយំនោះ ដោយហេតុអ្វី ? គឺដោយសារបុណ្យខ្មោចមួយ ដែលមានសាកសពជិតបីលាននាក់ ។

គ្មាននរណាម្នាក់ទទួលខ្លួនខុស ចំពោះមហាវិនាសកម្មនេះ ពុយ៉ាងហោចណាស់ ភ្ញាក់រលឹកអំពីកំហុស ហើយឆាប់ស្ទុះស្ទាររកនយោបាយ ដើម្បីបញ្ចប់អំពើឈ្លានពានរបស់យួនឡើយ ។ ដូចជាក្នុងបទសម្ភាសន៍មួយ ដែលហ្សង់-ឡាគូទៀរ៍ បានចោទសំនួរទៅនរោត្តម-សីហនុថា ៖ «នៅឆ្នាំ១៩៧០, ហេតុអ្វីបានជាសម្តេចជួយជ្រោមជ្រែងក្រុមប៉ុល-ពត ឲ្យទទួលបានជ័យជំនះ ដែលបានបណ្តាលឲ្យរាស្ត្រខ្មែរស្លាប់ជាងពីរលាននាក់ ?» ។ ចម្លើយ «ព្រោះខ្ញុំករុណាមិនដឹងថា ក្រុមប៉ុល-ពតសាហាចព្រៃផ្សៃដូច្នេះ» ។

ក្រោយ«ជ័យជំនះជាប្រវត្តិសាស្ត្រ»នៅថ្ងៃទី១៧មេសា១៩៧៥, ដោយបារម្ភឥតឈប់ឈរនឹងពួក«អាយ៉ងយួន», ប៉ុល-ពតសម្ងំលាក់មុខ ជាមួយការសំរិតសំរាំង «ខ្មាំង»នៅទួលស្លែង ឬត្រពាំងក្រឡឹងទី២, ដោយហេតុថា នៅក្នុងបក្សកុម្មុយនិស្តកម្ពុជា, នៅមុនឆ្នាំ១៩៦៦ មានឈ្មោះថា បក្សពលករកម្ពុជា, ហើយមុនសមាជបក្សលើកទី២ នៅឆ្នាំ១៩៦០ មានឈ្មោះថា បក្សប្រជាជនបដិវត្តន៍កម្ពុជា មានខ្មែរក្រហមពីរប្រភេទ ដែលតាំងខ្លួនជាអ្នកជាតិនិយមដូចគ្នា, ប៉ុន្តែមួយក្រុមជានិស្សិតកុម្មុយនិស្តមកពីប្រទេសបារាំងឬសៀមជំនាន់ឆ្នាំ៥០, មួយក្រុមទៀត ជាខ្មែរយៀកមិញជំនាន់ឆ្នាំ៤០ ។ ក្រោយជ័យជំនះ, ខ្មែរក្រហមជានិស្សិត ភាគច្រើនបានកាន់កាប់មុខតំណែងក្នុងមជ្ឈិមបក្សនៅភ្នំពេញ ដូចជាខៀវ-សំផន, សុន-សេន, អៀង-សារី, នួន-ជា, ប៉ុល-ពតជាដើម, ហើយខ្មែរក្រហមជំនាន់យៀកមិញ ភាគច្រើនចូលកាន់កាប់មុខនាទី ជាកម្មាភិបាលបក្ស នៅតាមភូមិភាគឬតំបន់ ដូចជា ជូ-ចិត្ត លេខាធិការនៅភូមិភាគបស្ចឹម, មូល-សម្បត្តិ (រស់-ញឹម) លេខាធិការនៅភូមិភាគពាយ័ព្យ, សោ-ភឹម លេខាធិការនៅភូមិភាគបូព៌ា, ណី-សារ៉ាន (យ៉ា) លេខាធិការនៅភូមិភាគឦសាន, ព្រំ-សម្បត្តិគណបញ្ជាការកងពលធំ១៧០, កែវ-មុនី, កែវ-មាសជាដើម។

វិបត្តិផ្ទៃក្នុងរបស់ខ្មែរក្រហម បានចាប់ផ្តើមនៅពេល ដែលទស្សនាវដ្តីយុវកក (យុវជនកុម្មុយនិស្តកម្ពុជា) របស់បក្ស បានចុះផ្សាយអត្ថបទ១០ទំព័រ ដើម្បីរំលឹកដល់ឆ្នាំខួបទី២៥របស់បក្ស ដោយបើកកកាយឡើងវិញ អំពីការបង្កបង្កើតបក្សប្រ-

ជាជនបដិវត្តន៍កម្ពុជានៅឆ្នាំ១៩៥១ ។ ចំណែកប៉ុល-ពតទើបនឹងឡើងលើនាវាហ៊្សាម៉ែក៍ នៅកំពង់ផែ ម៉ាសីយ៍ ក្នុងថ្ងៃទី១៥ធ្នូ១៩៥២ ដើម្បីត្រឡប់ទៅកម្ពុជាវិញ ហើយបានទៅដល់ភ្នំពេញ នៅពាក់កណ្តាលខែមករា១៩៥៣ ។ ចាប់ពីឆ្នាំ១៩៧៤, ឯកសារបក្សបានចាត់ទុកសមាជទី២របស់បក្សនៅឆ្នាំ១៩៦០ ដែលបានប្តូរឈ្មោះ<បក្សប្រជាជនបដិវត្តន៍កម្ពុជា> មកជា<បក្សពលករកម្ពុជា> ជាសមាជទី១ គឺអ្វីដែលបានប្រកាសពីការសេរីវិប្រវត្តិបក្ស ដែលផ្តល់មុខនាទីកាន់តែធំជាងទៅប៉ុល-ពត ។

ក្នុងសម័យប្រជុំនៅខែមិនា១៩៧៦, គណៈកម្មាធិការអចិន្ត្រៃយ៍បញ្ជាក់ថា ៖ «សូមកុំពោលដល់ឆ្នាំ១៩៥១, សូមកាត់ឫសគល់នេះចេញ» ។ នៅខែតុលា១៩៧៦, បន្ទាប់ពីការឃុំឃាំង កែវ-មាស និង ណី-សារ៉ាន នៅទួលស្លែង, អត្ថបទមាន៣១ ទំព័របញ្ជាក់ថា ៖ បក្សត្រូវបានបង្កើតឡើងនៅឱកាសសមាជ«ទី១» ក្នុងឆ្នាំ១៩៦០ ដោយបន្ថែមថា ៖ «យើងត្រូវកំណត់ប្រវត្តិបក្សឡើងវិញ, តាមលក្ខណៈដែលបក្សមានភាពបរិសុទ្ធនិងឥតខ្ចោះ», បានន័យថាគ្មានសមាសធាតុ «យួន» ដែលបាន «ឈាន»មុនប៉ុល-ពត ។

គឺសេចក្តីសំរេចរបស់ក្រុមប៉ុល-ពតនេះហើយ ដែលបានបង្កភាពទោមនស្សក្នុងមជ្ឈដ្ឋាននៃខ្មែរយៀកមិញ និងក្នុងសំណាក់យួនជា«គ្រូដើម», ដែលបានព្យាយាម ដើម្បីរុញច្រានពួកខ្មែរកុម្មុយនីស្តឲ្យទទួលបានជោគជ័យ ដើម្បីទុកជា«រណប»របស់គេ សំរាប់យកលេសដើម្បីប្រើសិទ្ធិក្នុងការត្រួតសង្កត់លើកម្ពុជា ដូចទម្លាប់របស់យួនជាហូរហែរក្នុងប្រវត្តិសាស្ត្រ ។ បក្សកុម្មុយនិស្តយួនកាន់តែយល់ច្បាស់ពីនិន្នាការរបស់ក្រុមប៉ុល-ពត ដែលពិតជាប្រែក្រឡះទៅរកប៉េកាំង ហើយយោលតាមវិបត្តិចិន-សូវៀតដែលឆេះធំ ជាគ្រោះថ្នាក់មួយចំពោះសន្តិសុខរបស់យួនបើកម្ពុជាមិននៅជា«រណប»របស់ហាណូយ ។ ដូច្នេះ ដោយផ្សំជាមួយផែនការរបស់សូវៀត ដែលចង់ពង្រីកឥទ្ធិពលមកលើកម្ពុជានៅក្រោយជ័យជំនះរបស់យួនខាងជើងទៅលើយួនខាងត្បូង នៅថ្ងៃទី៣០មេសា១៩៧៥ ព្រមទាំងគំនិតផ្ទាល់របស់ហាណូយដែលចង់លេបកម្ពុជាផង យួនចាំបាច់ត្រូវតែរំលំប៉ុល-ពត ដោយប្រើខ្មែរក្រហមយៀកមិញជាមធ្យោបាយ ។

ដោយមានភស្តុតាងដែលក្រុមប៉ុល-ពតចាប់បាន, ប៉ុល-ពតចាប់ផ្តើមការសំរិតសំរាំងលើកម្មាភិបាលជំនាន់យៀកមិញ តាំងពីក្នុងជួរនៃបក្ស រហូតដល់ភូមិភាគ, តំបន់, ស្រុក និងសង្កាត់ ដែលបានសន្មត់ជា«អាយ៉ងយួន» ។ ចំណែកកម្មាភិបាលខ្មែរក្រហម ទាំងជំនាន់ចាស់ ទាំងជំនាន់ថ្មីនៅតាមភូមិភាគ, តំបន់, ស្រុក និងសង្កាត់ទាំងនោះ ក៏ខំកំចាត់«ខ្មាំងវណ្ណៈ», «ខ្មាំងបដិវត្តន៍»ដែរ, បានន័យថា ប្រជារាស្ត្រសាមញ្ញទាំងចាស់ទាំងថ្មីដូចគ្នា, តាមវិធានការណ៍«ក្តៅ»នៃអាជ្ញាបញ្ជារបស់បដិវត្តន៍ដូច

គ្នា ។ រួមផ្សំជាមួយបរាជ័យនៃផែនការ «បីតោនមួយហិកតា» និងគំរោងសំរាប់អភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច «មហាលោតផ្លោះ» ផ្សេងៗទៀត, កម្មាភិបាលជាអ្នកទទួលខុសត្រូវដ៏ច្រើននិងប្រជារាស្ត្រ ជាអ្នកបង្កបង្កើតផល ត្រូវក្លាយជាកម្មវត្ថុនៃការសរិតសំរាំងរបស់ប៉ុល-ពត ។

លទ្ធិកុម្មុយនិស្តដែលហូ-ជីមិញបានយកមកសាបព្រួសនៅកម្ពុជា មានអនុភាពសក្តិសិទ្ធិមុតថ្លាជាងផ្លែដាវឬមុខលំពែងរបស់យួន នៅមុនសម័យអាណានិគមបារាំង ហើយខ្លាំងក្លាជាងគ្រាប់កាំភ្លើងដែលយួនមិនចាំបាច់យកមកបាញ់ ដើម្បីសម្លាប់ជីវិតខ្មែរដោយផ្ទាល់ដៃ ។ សូមជំរាបថា លទ្ធិកុម្មុយនិស្តដែលយួនបានបញ្ចូលមកកម្ពុជា «ជាលទ្ធិកុម្មុយនិស្ត-ឡេនីននិស្តដែលបរិសុទ្ធបំផុត តឹងរ៉ឹងបំផុត និងដាច់អហង្ការបំផុត ក្នុងយុគសម័យបដិវត្តន៍យើងនេះ» (ដេវីឌ-ភី ឆេនឡឺរ៍) ។ ចំណែកនៅប្រទេសនៃសត្រូវស្នួរពូជរបស់ខ្មែរវិញ ហូ-ជីមិញជាអ្នកកាន់លទ្ធិម៉ាកស៊ីស្ត ដែលលាយឡំជាមួយទ្រឹស្តីរបស់ទស្សនវិទូបុរាណចិន «ខុងជឺ» (Le Marxisme teinté de Confucianisme) ដោយធ្វើការកែប្រែឡើងវិញទៅតាមមូលដ្ឋាននៃវប្បធម៌ជាតិ, ប្រពៃណី, សីលធម៌ជាដើម ។ នៅកម្ពុជា, ខ្មែរយៀកមិញនិងបញ្ញវ័ន្តកុម្មុយនិស្តបានធ្វើបដិវត្តន៍ ដើម្បីសំដៅតែបំរើខ្មោច កាល៍ម៉ាក្ស៍, ឡេនីន, ម៉ៅ-សេទុង និងហូ-ជីមិញប៉ុណ្ណោះ គឺមិនមែនបំរើប្រជារាស្ត្រខ្មែរទេ ដោយយកជីវិតខ្មែររាប់លាននាក់ ដែលបក្សរំដោះបាន និងដែលត្រូវបានសន្មត់ថាជា «ឧបករណ៍» របស់បក្ស ធ្វើជាមធ្យោបាយ ដើម្បីសំរេចគំនិតយល់សប្តិរបស់ពួកខ្លួន ហើយដោយបោះបង់ព្រះពុទ្ធសាសនា ដែលជាព្រលឹងខ្មែរចោល ។ ក៏មិនខុសគ្នាប៉ុន្មានពីស្តេចខ្មែរមួយចំនួន ដែលខំច្បាំង ខំពឹងកម្លាំងពីបរទេស ឲ្យមកបង្ហូរឈាមខ្មែរស្លូតត្រង់ ដើម្បីតែរាជបល្ល័ង្កខ្មែរ ។

ពួកបញ្ញវ័ន្តឆ្វេងនិយមខ្មែរ ដែលត្រឡប់ពីបរទេសវិញ នាំគ្នាតាំងខ្លួនជាបញ្ញវ័ណ្ឌផាឱបខ្មៅ ហើយនាំគ្នាបង្អត់បាយដល់ប្រជារាស្ត្រស្លូតត្រង់ដែលជាម្ចាស់ស្រែម្ចាស់ស្រូវ ដែលធ្លាប់ផ្តល់អាហារូបករណ៍ជូនអស់លោក ដើម្បីទៅបន្តវិជ្ជាជាន់ខ្ពស់នៅបរទេស ហើយជាពិសេសដែលធ្លាប់ទទួលការជិះជាន់ តាំងពីរាប់សតវត្សមកហើយ ។ បន្ទាប់មក, បញ្ញវ័ណ្ឌកន្ទបផាឱបខ្មៅយើង មើលឃើញប្រជារាស្ត្រដែលហេវហត់ ស្រេកឃ្លាន ឈឺចាប់ ភ័យតក់ស្លុត ថាជា«ខ្មាំង» ដែលប្រឆាំងជាមួយនយោបាយអមនុស្សធម៌ ជាមួយបដិវត្តន៍ដ៏មហាលើលារបស់ពួកខ្លួន រួចក៏តាំងធ្វើទារុណកម្ម កាប់សម្លាប់ជាតិសាសន៍ឯងជំនួសយួន រហូតទាល់តែធ្លាក់ខ្លួនជាបញ្ញវ័ណ្ឌកនៅស្រុកលែងបាន, ទីបំផុតត្រូវទៅសម្ងំពួនអាទ្នានៅតាមព្រៃ ហើយក្លាយខ្លួនជាបញ្ញវ័ណ្ឌដើមឈើរហូតដល់សព្វថ្ងៃ ។ សរុបទៅ, ដោយរួមផ្សំជាមួយសង្គ្រាម

ដើម្បីដណ្ដើមយកអំណាច ដែលត្រូវបាត់បង់នៅឆ្នាំ១៩៧០, បដិវត្តន៍នៅកម្ពុជាដែលតស៊ូពីបាត<ដៃទទេ> បានសំរេចជោគជ័យនៅត្រឹម<ពោះទទេ> ហើយទីបញ្ចប់ហៀបនឹងបានឈានដល់<ដីទទេ> ។

ក្រៅពីវិបត្តិផ្នែកនយោបាយផ្ទៃក្នុង កម្ពុជាប្រជាធិបតេយ្យរបស់ប៉ុល-ពតមានវិបត្តិផ្នែកនយោបាយខាងព្រំដែនជាមួយយួន ។ រដ្ឋាភិបាលប៉ុល-ពត បានទាមទារឲ្យយួនប្រគល់ផែនសមុទ្រ, កោះ និងដែនដីខ្មែរនៅភូមិភាគឦសាន ដោយយួនចូលកាន់កាប់ដោយរំលោភមកខ្មែរវិញ ។ បីសប្ដាហ៍ក្រោយជ័យជំនះលើក្រុងភ្នំពេញ ពីថ្ងៃទី៤ទៅ១០ឧសភា១៩៧៥ កងទ័ពខ្មែរក្រហមបានវាយដណ្ដើមយកកោះត្រល់ និងកោះថូជូពីយួន ។ បន្ទាប់ពីបានវាយយកកោះទាំងពីរនេះហើយ កងនាវាចរណ៍យួន បានវាយយកកោះខ្មែរមួយបន្ថែមទៀត ។ នៅខែមិនា១៩៧៥ គណប្រតិភូកម្ពុជាប្រជាធិបតេយ្យ ដឹកនាំដោយសាឡុត-សរ, នួន-ជា និងអៀង-សារី បានទៅទស្សនាទីក្រុងហាណូយ ។ ភាគីខ្មែរបានស្នើរកសន្ធិសញ្ញាជាមិត្តភាព ប៉ុន្តែយួនមិនបានឆ្លើយតបទេ ទំនងជាយួនពេញចិត្តក្នុងការពង្រីកពង្រឹង «ទំនាក់ទំនងពិសេស» ដែលពួកគេខំយកចិត្តទុកដាក់ ដើម្បីបង្កបង្កើតជាមួយកម្ពុជាពីគ្រាមុន ។ ប៉ុន្តែ, ដល់ថ្ងៃទី៦សីហា១៩៧៥ យួនប្រគល់កោះអាចម៍សេះមកខ្មែរវិញ ក្នុងឱកាសទស្សនកិច្ចរបស់គណប្រតិភូនៃបក្សកុម្មុយនិស្តយួន ដឹកនាំដោយ ឡេ-យ៉ន់ ។ បន្ទាប់មក នៅថ្ងៃទី៩កញ្ញា១៩៧៥, ស្ដេចសីហនុត្រឡប់មកកម្ពុជាវិញ ក្រោយពីសម័យប្រជុំនៅអង្គការសហប្រជាជាតិ ដែលមានការតែងតាំង ជួន-ប្រសិទ្ធ ជាតំណាងខ្មែរនៅទីនោះ ។

នៅថ្ងៃទី១៥កញ្ញា១៩៧៥, រដ្ឋទូតយួនខាងជើង ផាម-វ៉ាន់បា ដែលបានដឹកនាំសាឡុត-សរឲ្យចូលក្នុងបក្សកុម្មុយនិស្តឥណ្ឌូចិននៅឆ្នាំ១៩៥៣ បានត្រឡប់មកតាំងស្ថានទូតនៅភ្នំពេញវិញ ។ ទោះបីយ៉ាងណា, ក៏ឧប្បត្តិហេតុរវាងកងទ័ពខ្មែរក្រហមនិងយួន បានកើតឡើងតាមបណ្ដោយព្រំដែននៃភូមិភាគឦសាន ។ មកដល់ថ្ងៃទី៤ទៅទី១៨ឧសភា១៩៧៦ មានការជួបប្រាស្រ័យរវាងមេដឹកនាំខ្មែរនិងយួននៅក្រុងភ្នំពេញ ដើម្បីរៀបចំសន្ធិសិទមួយ គ្រោងទុកក្នុងខែមិថុនា សំរាប់ដោះស្រាយបញ្ហាស្ដីពីព្រំដែន ។ គណប្រតិភូទាំងពីរមិនចុះសំរុងគ្នា ក្នុងបញ្ហាខាងព្រំដែនសមុទ្រ ។ គណៈកម្មាធិការចំរុះសំរេចចិត្ត ដើម្បីធ្វើទំនាក់ទំនងតាមបណ្ដោយព្រំដែន ។ ប៉ុន្តែកម្ពុជាប្រជាធិបតេយ្យបានបញ្ឈប់ការពិភាក្សា ហើយជំនួបប្រាស្រ័យសំរាប់ខែមិថុនា ពុំត្រូវបានប្រកាន់យក ។ ថ្ងៃទី១៨កញ្ញា១៩៧៦ ជាទិវានៃមរណភាពរបស់ម៉ៅ-សេទុង ។ ក្នុងសុន្ទរកថាផ្សាយតាមវិទ្យុភ្នំពេញ ជាកិច្ចកាន់មរណទុក្ខ, ប៉ុល-ពតប្រកាសថា «អង្គការ» ដើរតាមមាគ៌ាម៉ាកស៊ីស្ត-ឡេនីនិស្ត ហើយសោមនស្សលើធំ-

ណាង «ភាតរៈ»ជាមួយបក្សកុម្មុយនិស្តចិន ។

សញ្ញានៃការចាប់ផ្ដើមនូវវិបត្តិរវាងចិននិងយួន ប្រហែលកើតឡើងនៅថ្ងៃទី ១៩ធ្នូ១៩៧៦, ពីព្រោះក្នុងសមាជទី៤នៃបក្សពលករយួន ដែលត្រូវបានប្ដូរឈ្មោះទៅជាបក្សកុម្មុយនិស្តយួន, ទាំងគណប្រតិភូចិនឬគណប្រតិភូខ្មែរ ពុំបានទៅចូលរួមក្នុងពិធីនេះទេ ។ វត្ថុធាតុដែលនិយមខាងចិន ត្រូវបានជម្រុះចេញពីប្រព័ន្ធអំណាចនៃបក្សកុម្មុយនិស្តយួន ហើយទស្សនកិច្ចរបស់ឡេ-យ៉ង់ តាំងពីខែកញ្ញា១៩៧៥ នៅប៉េកាំង ពុំមានភាពកក់ក្ដៅពីចិនទេ ។

ចំពោះសកម្មភាពនៃការជ្រៀតចូលរបស់ចិនទៅក្នុងប្រទេសសៀម តាមរយៈប៉ុល-ពត គឺឧប្បត្តិហេតុធ្ងន់ធ្ងរជាច្រើនបានកើតមាន តាមព្រំដែនខ្មែរនិងសៀម ពៅថ្ងៃទី២២ធ្នូ១៩៧៧ ។ ក្នុងអំឡុងនៃរយៈកាលនេះ បក្សកុម្មុយនិស្តកម្ពុជាបានរៀបចំសហប្រតិបត្តិការសម្ងាត់ ជាមួយក្រុមទ័ពព្រៃបះបោរនៃបក្សកុម្មុយនិស្តសៀម ដែលបានអនុញ្ញាតឲ្យតាំងមូលដ្ឋាននៅក្នុងដែនដីខ្មែរ ។

វិបត្តិជាមួយយួនកើតមានជាបន្តបន្ទាប់ រហូតដល់ថ្ងៃទី៣១ធ្នូ១៩៧៧ ដែលភ្នំពេញបានសំរេចចិត្តផ្ដាច់ចំណងទូតពីយួន ដោយប្រកាសអំពីការវាតទីរបស់យួន និងគំរោងការរបស់យួនសំរាប់«សហព័ន្ធឥណ្ឌូចិន» ។ នៅដើមខែមករា១៩៧៨, ទោះជាពលទាហានយួន៦កងពលធំ ចូលធ្វើប្រតិបត្តិការក្នុងដែនដីខ្មែរ ត្រង់ព្រំដែនភាគខាងកើត ក៏កងទ័ពកម្ពុជាប្រជាធិបតេយ្យនៅតែបន្តជំរុលទៅភាគខាងត្បូង ។ នៅដើមឆ្នាំ១៩៧៨, ចិនបញ្ជូនរថពាសដែក មានកាំភ្លើងធំធុនធ្ងន់១៣០ម.ម. និងកាំភ្លើងប្រឆាំងរថក្រោះឲ្យភ្នំពេញ ។ មកទល់ពេលនោះ, កម្លាំងប្រយុទ្ធសរុបនៃភាគីទាំងពីរ កើនលើសពី៩០,០០០នាក់ ។ កងទ័ពខ្មែរវាយបកទៅវិញ ហើយយួនដកថយ ប៉ុន្តែការដកថយនេះ ត្រូវបានចាត់ទុកដោយវិទ្យុភ្នំពេញ នៅថ្ងៃទី៦មករា១៩៧៨ ជា«ជ័យជំនះទាំងស្រុង»របស់កងទ័ពប្រជាធិបតេយ្យ ហើយកម្ពុជាបន្តបាញ់ផ្គក់ដោយប្រើកាំភ្លើងធំ១៣០ម.ម. ទៅលើខេត្តចូវដុក និងតាយនិញ រហូតដល់ទស្សនកិច្ចរបស់យ៉-ង្វៀងយ៉ាប់នៅទីនោះ ក្នុងថ្ងៃទី១៩មករា១៩៧៨ ។

ចំណែកខាងប្រទេសសៀម ដើម្បីស្វែងរកភាពប្រក្រតីខាងទំនាក់ទំនងផ្លូវទូតរវាងប្រទេសទាំងពីរ រដ្ឋមន្ត្រីក្រសួងការបរទេសសៀម ឧប៉ាឌិត បានមកទស្សនាក្រុងភ្នំពេញ នៅថ្ងៃទី៣១មករា១៩៧៨ ហើយបន្ទាប់មក រដ្ឋាភិបាលសៀមអនុញ្ញាតឲ្យហាណូយបើកស្ថានទូតមួយនៅបាងកក ក្រោយពីកិច្ចចរចាអស់រយៈពេលច្រើនខែ ។ នៅថ្ងៃទី៥កុម្ភៈ១៩៧៨ យួនស្នើរកកិច្ចចរចាការដកកងទ័ពចេញពីតំបន់ព្រំដែន និងការត្រួតពិនិត្យព្រំដែនពីអន្តរជាតិ ។ ជាហូរហែរ យួនស្នើរកកិច្ចចរចាជានិច្ចមុនខ្មែរ ប៉ុន្តែអ្វីៗដែលយួនបានស្នើរ ជាលក្ខខណ្ឌរំលោភបំពានសំរាប់ផលប្រយោជន៍

របស់យួន ហើយដែលកម្ពុជាប្រជាធិបតេយ្យមិនអាចយល់ព្រមបាន ដូចជាភាពរឹងរូសរបស់យួន ក្នុងការកាន់កាប់លើតំបន់ព្រំដែននៅភាគឦសាននៃកម្ពុជាជាដើម ។ ក៏មិនខុសគ្នាពីដំបូន្មានរបស់ចិន ដែលឲ្យកម្ពុជាជួបចរចាជាមួយយួន ទៅតាមលក្ខខណ្ឌដែលយួនមិនត្រូវការគោរពដែរ ។

នៅដំណាច់ខែកុម្ភៈ១៩៧៨, គណកម្មាធិការនៃបក្សកុម្មុយនិស្តយួនបានសំរេចចិត្ត ដើម្បីប្រកាសអំពីការគាំទ្រដល់ក្រុមទ័ពប្រឆាំងប៉ុល-ពត ដែលស្ថិតនៅក្នុងដែនដីខ្មែរនៅឡើយ ។ តាមវិទ្យុហាណូយ យួនបានផ្សាយជាភាសាខ្មែរ ដោយអំពាវនាវឲ្យខ្មែរក្រោកបះបោរប្រឆាំងប៉ុល-ពត ហើយនៅដើមខែមិនា គាំទ្រដោយកងរថក្រោះ យួនវាយប្រហារលើខេត្តនៅតាមព្រំដែនមាន តាកែវ កំពត ព្រៃវែង និងស្វាយរៀង ។ បន្តិចក្រោយមក, នៅថ្ងៃទី៤មិនា១៩៧៨, ក្រុមថ្មីនានានៃអ្នកបច្ចេកទេសនិងទីប្រឹក្សាយោធាចិន បានមកដល់ទីក្រុងភ្នំពេញ ។ ពួកនេះមមាញឹកក្នុងសំណង់សំរាប់ផ្លូវរថភ្លើងថ្មី ដែលកាត់តម្រង់ពីភ្នំពេញទៅកំពង់សោម ។

ចាប់ពីថ្ងៃទី២៦ឧសភា១៩៧៨, មានការបះបោរនៅភូមិភាគបូព៌ា ។ ក្នុងបំណងដើម្បីស្រោចស្រង់បដិវត្តន៍ និងដើម្បីគេចខ្លួនពីការសំរិតសំរាំង មេដឹកនាំដែលនៅមានជីវិតក្រោយពេលបះបោរ ជឿជាក់លើសារសំខាន់នៃចំណងមិត្តភាពជាមួយយួន ។ មេដឹកនាំខ្លះ ដូចជាហេង-សំរិន បានសំរេចចិត្តភៀសខ្លួនពីកម្ពុជានៅដំណាច់ឆ្នាំ ក្នុងពេលដែលការសំរិតសំរាំងដ៏តឹងរ៉ឹងកំពុងកើតមានទូទាំងភូមិភាគបូព៌ា ។ លេខាធិការប្រចាំភូមិភាគនេះ, សោ-ភឹម, ធ្វើអត្តឃាត ។ កម្មាភិបាល១,០០០នាក់ត្រូវបានចាប់ចង, ១,០០០នាក់ទៀតត្រូវបានប្រហារជីវិត ។ ពលយោធារាប់ម៉ឺននាក់ ដែលធ្លាប់ប្រយុទ្ធតាំងពីឆ្នាំ១៩៧០ប្រឆាំងរបបសាធារណរដ្ឋ ត្រូវបានជម្លៀសទៅកាន់ខេត្តកំពង់ឆ្នាំង ។ ជាច្រើននាក់នៅក្នុងចំណោមនោះ ត្រូវបានប្រហារជីវិតតាមផ្លូវ ។ អ្នកផ្សេងទៀត តាមការអះអាងរបស់ប្រជារាស្ត្រខ្មែរ នៅភ្នំសន្ទុក ដែលខ្ញុំបានជួបផ្ទាល់ ក្នុងដំណើរស្វែងរកគ្រួសារនៅឆ្នាំ១៩៧៩ ត្រូវស្លាប់យ៉ាងវេទនាក្នុងសំណង់អាកាសយានយោធាមួយ នៅក្នុងស្រុកអាចម៍រមាសក្នុងខេត្តកំពង់ឆ្នាំង ។

នៅថ្ងៃទី២៨កក្កដា១៩៧៨ មន្ត្រីក្រសួងការពារជាតិ សឺន-សេន បានទៅទស្សនាទីក្រុងប៉េកាំង តាមកិច្ចអញ្ជើញពីរដ្ឋមន្ត្រីក្រសួងការពារជាតិចិន ។ មានភាពទំនងដែលចិនពន្យល់ថា ចិនគ្មានគំរោងការដើម្បីធ្វើអន្តរាគមន៍ដោយផ្ទាល់នៅក្នុងវិវាទខ្មែរ-យួនទេ ហើយបដិសណ្ឋារកិច្ចចំពោះសឺន-សេន មិនសូវមានភាពកក់ក្តៅ ។ ពេលត្រឡប់មកកម្ពុជាវិញ សឺន-សេនបង្កើតបញ្ជាការដ្ឋានមួយនៅតាសាញ់ ក្នុងខេត្តបាត់ដំបង មិនឆ្ងាយប៉ុន្មានពីសំឡូត ។ បញ្ជាការដ្ឋាននេះត្រូវបានទស្សនាដោយអ្នកសារពត៌មានចិននៅចុងឆ្នាំ ហើយត្រូវធ្លាក់ទៅក្នុងដៃយួននៅខែមេសា១៩៧៩ ។

នៅពេលនោះ ឯកសារទាំងឡាយដែលរាយលំអិតពីជំនួយចិនដល់កម្ពុជា ត្រូវបានដណ្តើមយកដោយកងទ័ពយួន ។

នៅថ្ងៃទី២៩កក្កដា១៩៧៨, វិទ្យុហាណូយពោលអះអាងថា អ្នកជំនាញការចិនកំពុងបង្ហាត់អាកាសយានិក, អ្នកបើករថក្រោះ និងអ្នកបាញ់កាំភ្លើងធំនៅកម្ពុជា ហើយថាពួកនេះកំពុងស្ថាបនាអាកាសយានដ្ឋានយោធាដ៏ធំមួយនៅជិតកំពង់ឆ្នាំង ។ ពីថ្ងៃទី៥ទៅ៩វិច្ឆិកា១៩៧៨, នៅកម្ពុជាមានទស្សនកិច្ចរបស់សមាជិកនៃការិយាល័យនយោបាយចិនពីររូប, ហ៊្វង-ដុងហ្សិន និងយូ-ស៊្យលី, ជាអ្នកទទួលខុសត្រូវខាងសន្តិសុខរបស់មេដឹកនាំចិន ដែលបានបង្ក្រាបពួកបាតុករជាអ្នកជាតិនិយម ជូ-អេនឡាយ នៅប៉េកាំង បន្ទាប់ពីមរណភាពរបស់គាត់នៅថ្ងៃទី៨មករា១៩៧៥ ។ ទីប្រឹក្សាទាំងនេះបានផ្តល់ឱវាទទៅកងទ័ពកម្ពុជាប្រជាធិបតេយ្យ ឲ្យត្រឡប់ទៅរកលក្ខន្តិកៈនៃសង្គ្រាមទ័ពព្រៃវិញ ។ ក្នុងឯកសារដែលមានជាប់ទាក់ទងដល់ការពិភាក្សា, ឈ្មោះថ្មីជាច្រើន, ប្រហែលជារហស្សនាម បានលេចឡើងនៅក្នុងបញ្ជីរបស់ប៉ុល-ពត ។

«អគ្គលេខាធិការរង»ថ្មីនៃរបបប៉ុល-ពត ឧទាហរណ៍ ង៉ួន-កង, ជារហស្សនាមរបស់តាម៉ុក ។ ចំណែកនួន-ជា ត្រូវបានបន្ថយលំដាប់អំណាច ។

នៅថ្ងៃទី៣ធ្នូ១៩៧៨, វិទ្យុហាណូយបានប្រកាសអំពីការបង្កើតក្នុងថ្ងៃទី២ធ្នូ១៩-៧៨ នូវរណសិរ្សបង្រួបបង្រួមមួយ ដើម្បីធ្វើជា «រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា» ដែលនៅក្រោមការដឹកនាំរបស់ហេង-សំរិន, ជា-ស៊ីម, ហ៊ុន-សែន, ប៉ែន-សុវណ្ណ ។

នៅដើមខែមករា១៩៧៩, ថ្នាក់ដឹកនាំនៃកម្ពុជាប្រជាធិបតេយ្យ បានសំរេចចិត្តតាមពិធីការ ដើម្បីបោះបង់រដ្ឋធានីភ្នំពេញ ហើយចាប់ផ្តើមសង្គ្រាមទ័ពព្រៃវិញ ។ ចំណែកខាងយួន «ដំណើរឆ្ពោះទៅទិសខាងលិច» និងគំរោងសំរាប់«សហព័ន្ធឥណ្ឌូចិន»របស់គេ ជាមួយសហភាពសូវៀត មានដំណើរការទៅមុខជានិច្ច ។

❑ ❑

❑